រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# នីតិវិធីស្តីពី
# ការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹងរបស់
# ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត

ខែវិច្ឆិកា ឆ្នាំ២០០៩

# មាតិកា


**ផ្នែកទី១ ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ........ ១**

១.១ គោលបំណងនៃការបង្កើតក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ........ ១

១.២ សមត្ថកិច្ចរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ........ ១

**ផ្នែកទី២ ពាក្យបណ្ដឹង និងការប្រមូលពាក្យបណ្ដឹង ........ ២**

២.១ សញ្ញាណពាក្យបណ្ដឹង ........ ២

២.២ តើការប្ដឹងត្រូវធ្វើដូចម្ដេច? ........ ៣

២.២.១ ការសសេរពាក្យបណ្ដឹង ........ ៣

២.២.២ ការប្ដឹងតាមមធ្យោបាយផ្សេងទៀត ........ ៣

២.៣ ការប្រមូលពាក្យបណ្ដឹង ........ ៦

២.៣.១ ការប្រមូលពាក្យបណ្ដឹងពីប្រអប់សំបុត្រគណនេយ្យភាព ........ ៦

២.៣.២ ការប្រមូលពាក្យបណ្ដឹងពីសមាជិក គ.គ.ខ និងមន្ត្រីជំនួយការ ........ ១០

២.៤ ការប្រគល់ ទទួលស្រោមសំបុត្រ និងកំណត់ហេតុ ........ ១០

**ផ្នែកទី៣ នីតិវិធីដោះស្រាយពាក្យបណ្ដឹង ........ ១៣**

៣.១ គោលការណ៍នៃការដោះស្រាយពាក្យបណ្ដឹង ........ ១៣

៣.២ ការដោះស្រាយពាក្យបណ្ដឹង ........ ១៣

ជំហានទី ១ : ការសម្រាំងពាក្យបណ្ដឹង ........ ១៤

ជំហានទី ២ : ការវាយតម្លៃពាក្យបណ្ដឹង ........ ១៨

ជំហានទី ៣ : ការរៀបចំផែនការស៊ើបអង្កេត ........ ២៧

ជំហានទី ៤ : ការស៊ើបអង្កេត ........ ៣១

ជំហានទី ៥ : ការធ្វើសេចក្ដីសម្រេច ........ ៥០

ជំហានទី ៦ : ការអនុវត្តសេចក្ដីសម្រេច និងតាមដាន ........ ៥៧

ជំហានទី ៧ : ការផ្ដល់ព័ត៌មានត្រឡប់ ........ ៦០

# ផ្នែកទី១
# ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត

## ១.១. គោលបំណងនៃការបង្កើតក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត

ការបង្កើតក្រុមការងារគណនេយ្យភាពរាជធានី ខេត្តមានគោលបំណងដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.អ.ប និងមូលនិធិឃុំ សង្កាត់ ព្រមទាំងរួមចំណែកក្នុងការពង្រឹងការអនុវត្តការងាររបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្របតាមគោលការណ៍ច្បាប់។

ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត ហៅកាត់ថា "**ក.គ.ខ**"។

## ១.២. សមត្ថកិច្ចរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត

ក.គ.ខ មានសមត្ថកិច្ចដោះស្រាយរាល់ភាពមិនប្រក្រតីពាក់ព័ន្ធនឹង ៖

**ក). ការប្រើប្រាស់ថវិកាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ៖**

ក.១. ថវិកាគ្រប់ប្រភពទាំងអស់ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

ក.២. ថវិកាទាំងឡាយណាដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.អ.ប។

ក.៣. មូលនិធិឃុំ សង្កាត់ និងថវិកាផ្សេងទៀត ដែលស្ថិតនៅក្នុងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**ខ). ការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៖**

ការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ កំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលស្របតាមច្បាប់ទាំង២ខាងលើនេះ រួមមាន ៖

ខ.១. ការបំពេញតួនាទី និងភារកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

ខ.២. ការបំពេញតួនាទី និងភារកិច្ចរបស់បុគ្គលិកមន្ទីរ អង្គភាព អាជ្ញាធរនានា ដែលបម្រើការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត

# ផ្នែកទី២
# ពាក្យបណ្តឹង និងការប្រមូលពាក្យបណ្តឹង

## ២.១. សញ្ញាណនៃពាក្យបណ្តឹង

**ពាក្យបណ្តឹង** សំដៅទៅលើរាល់ព័ត៌មានទាំងឡាយណាដែលប្រមូល និងទទួលបានពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដែលបានកំណត់ក្នុងចំណុច២.៣ (ការប្រមូលពាក្យបណ្តឹង) នៃផ្នែកនេះ។

***ភាពមិនប្រក្រតី*** សំដៅលើការអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំ ឬនីតិវិធីក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.អ.ប និងមូលនិធិឃុំ សង្កាត់ និងការអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំ ឬនីតិវិធីក្នុងការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

ពាក្យបណ្តឹងអាចពាក់ព័ន្ធនឹង :

**ក). ការប្រើប្រាស់ថវិកាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ :**

ក.១. ថវិកាគ្រប់ប្រភពទាំងអស់ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)។

ក.២. ថវិកាទាំងឡាយណាដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.អ.ប។

ក.៣. មូលនិធិឃុំ សង្កាត់ និងថវិកាផ្សេងទៀត ដែលស្ថិតនៅក្នុងថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

**ខ). ការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ :**

ការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ កំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតដែលស្របតាមច្បាប់ទាំង២ខាងលើនេះ រួមមាន :

ខ.១. ការបំពេញតួនាទី និងភារកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

ខ.២. ការបំពេញតួនាទី និងភារកិច្ចរបស់បុគ្គលិកមន្ទីរ អង្គភាព អាជ្ញាធរនានា ដែលបម្រើការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត

## ២.២. តើការប្តឹងត្រូវធ្វើដូចម្តេច?

ការប្តឹងអាចធ្វើឡើងតាមមធ្យោបាយពីរយ៉ាង :

- ទី១ : ការសរសេរពាក្យបណ្តឹង
- ទី២ : មធ្យោបាយផ្សេងៗទៀត ។

ជាការប្រសើរ ការប្តឹងឬការរាយការណ៍ត្រូវបរិយាយឱ្យបានច្បាស់ ថាតើលោកអ្នកចង់ប្តឹងឬរាយការណ៍អំពីអ្វី? បញ្ជាក់អំពីអត្តសញ្ញាណរបស់ជនត្រូវចោទ ទីកន្លែង ពេលវេលានៃភាពមិនប្រក្រតីដែលបានកើតឡើង អ្នកពាក់ព័ន្ធ សាក្សី អ្នកដឹងឮ និងសំណើសុំដោះស្រាយ ។

ការប្តឹងអាចធ្វើដោយបុគ្គលម្នាក់ៗ ជាក្រុម ឬក្នុងនាមមន្ទីរ អង្គភាព ។

### ២.២.១. ការសរសេរពាក្យបណ្តឹង

ប្រជាពលរដ្ឋ ឬបុគ្គលម្នាក់ៗអាចសរសេរពាក្យបណ្តឹងដោយប្រើប្រាស់ :

- សន្លឹកព័ណ្ណព័ត៌មានដែលមានដាក់នៅតាមប្រអប់សំបុត្រគណនេយ្យភាព ដោយសរសេរនៅផ្នែកខាងក្រោយនៃសន្លឹកព័ណ្ណព័ត៌មាន ដែលមានទុកចន្លោះសម្រាប់សរសេរ ឬ
- ក្រដាសសរសេរ ឬ
- ទម្រង់ពាក្យបណ្តឹងដែលបានរៀបចំដោយ ក.គ.ខ (ទម្រង់ទី១) ។

ក្នុងការសរសេរពាក្យបណ្តឹង ប្រជាពលរដ្ឋអាចសរសេរឈ្មោះ ឬមិនចាំបាច់សរសេរឈ្មោះ ។ ពាក្យបណ្តឹងនេះ អាចយកទៅដាក់ក្នុងប្រអប់សំបុត្រគណនេយ្យភាព ឬផ្តល់ជូនសមាជិក ក.គ.ខ ដោយផ្ទាល់ ។

ក្រុមគាំទ្រនៃ ក.គ.ខ ត្រូវថតចម្លងទម្រង់ពាក្យបណ្តឹងឱ្យបានគ្រប់គ្រាន់ដើម្បីប្រើប្រាស់ និងត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការប្រើប្រាស់ទម្រង់ពាក្យបណ្តឹងនេះ ។

ទម្រង់ទី១ : ពាក្យបណ្តឹង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

ខ្ញុំបាទ នាងខ្ញុំឈ្មោះ.............................................. សញ្ជាតិ.............. ឆ្នាំកំណើត............................
មុខរបរបច្ចុប្បន្ន.................................................................................. ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ..........
ផ្លូវលេខ.............. ក្រុមទី........... ភូមិ.......................................... ឃុំ សង្កាត់...........................................
ក្រុង ស្រុក ខណ្ឌ........................................ រាជធានី ខេត្ត............................................... ។

**សូមគោរពជូន**

**ប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត**..........................

**កម្មវត្ថុ:** ពាក្យបណ្តឹងអំពី.................................................................................................... ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំ សូមជម្រាបជូនថា :

១. ករណីបានកើតឡើង : (បរិយាយហេតុការណ៍បានកើតឡើង ដែលបានមើលឃើញ ឬដឹង)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

២. នៅពេលណា? កន្លែងណា? កើតឡើងដូចម្តេច?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៣. នរណាអ្នកប្រព្រឹត្ត? ឈ្មោះអ្វី? តួនាទី? អាសយដ្ឋាន?

..........................................................................................................................

..........................................................................................................................

៤. នរណាបានឃើញហេតុការណ៍នេះ? ឈ្មោះអ្វី? តួនាទី? អាសយដ្ឋាន?

..........................................................................................................................................................

..........................................................................................................................................................

៥. សូមបញ្ជាក់អំពីភស្តុតាង ដូចជាទីកន្លែង ឈ្មោះឯកសារ អ្នកកាន់កាប់ឯកសារ (បើដឹងអំពីភស្តុតាង ឬឯកសារ)

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

៦. សូមផ្តល់ឯកសារពាក់ព័ន្ធនឹងករណីខាងលើនេះ(ប្រសិនបើមាន)

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

អាស្រ័យហេតុនេះ សូមលោកប្រធានក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត មេត្តាជួយដោះស្រាយ ឬអន្តរាគមន៍តាមសំណើខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ នាងខ្ញុំ ។

ធ្វើនៅថ្ងៃទី.......... ខែ................ ឆ្នាំ.............

**ស្នាមមេដៃស្តាំអ្នកប្តឹង**

<u>បញ្ជាក់</u> : ក្រុមការងារគណនេយ្យភាពសូមរក្សាការសម្ងាត់ជូនប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដែលបានរាយការណ៍ ឬដាក់ពាក្យប្តឹង ។

### ២.២.២. ការប្តឹងតាមមធ្យោបាយផ្សេងៗទៀត

បុគ្គលនីមួយៗអាចប្តឹង ឬរាយការណ៍ដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទទៅសមាជិក ក.គ.ខ។ សមាជិករូបនោះត្រូវធ្វើកំណត់ហេតុដោយកត់ត្រាអំពីខ្លឹមសារទាំងស្រុងនៃការប្តឹង ឬការរាយការណ៍របស់បុគ្គលនោះ ហើយដាក់ក្នុងស្រោមសំបុត្របិទជិត រួចប្រគល់ឱ្យក្រុមគាំទ្រដើម្បីកត់ត្រាក្នុងទម្រង់ទី៣ (ការកត់ត្រាពាក្យបណ្តឹង)។ អ្នកធ្វើកំណត់ហេតុត្រូវសរសេរឈ្មោះរបស់ខ្លួន និងចុះកាលបរិច្ឆេទឱ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុ។ សមាជិក ក.គ.ខ ដែលបានធ្វើកំណត់ហេតុនោះត្រូវរក្សាការសម្ងាត់ចំពោះការប្តឹង ឬការរាយការណ៍នេះ។

កំណត់ហេតុខាងលើនេះ អាចសរសេរឈ្មោះរបស់បុគ្គលដែលបានប្តឹង ឬរាយការណ៍ដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទដោយត្រូវមានការឯកភាពពីបុគ្គលនោះ។

ក.គ.ខ ត្រូវចាត់ចែងបង្កើតខ្សែទូរស័ព្ទទាន់ហេតុការណ៍ (Hotline) ដើម្បីទទួលពាក្យបណ្តឹង ឬការរាយការណ៍ពីប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋមានសិទ្ធិប្តឹង ឬរាយការណ៍តាមរយៈខ្សែទូរស័ព្ទទាន់ហេតុការណ៍នេះ។

ក្រុមគាំទ្រត្រូវចាត់ចែងឱ្យមន្ត្រីជំនួយការទទួលខុសត្រូវក្នុងការទទួលពាក្យបណ្តឹង និងធ្វើកំណត់ហេតុពាក្យបណ្តឹង នៅពេលដែលប្រជាពលរដ្ឋបានប្រើប្រាស់បណ្តាញទូរស័ព្ទនេះ ហើយដាក់ក្នុងស្រោមសំបុត្របិទជិត។ មន្ត្រីជំនួយការត្រូវកត់ត្រាកំណត់ហេតុដែលទទួលបាននេះចូលទៅទម្រង់ការកត់ត្រាពាក្យបណ្តឹង។

## ២.៣. ការប្រមូលពាក្យបណ្តឹង

ពាក្យបណ្តឹងនឹងត្រូវបានប្រមូលពីប្រអប់សំបុត្រគណនេយ្យភាព និងពីសមាជិក ក.គ.ខ និងមន្ត្រីជំនួយការ។

### ២.៣.១. ការប្រមូលពាក្យបណ្តឹងពីប្រអប់សំបុត្រគណនេយ្យភាព

ក.គ.ខ ត្រូវធានាឱ្យមានការប្រមូលពាក្យបណ្តឹងជារៀងរាល់ខែ។ ដូច្នេះ ក.គ.ខ ត្រូវកំណត់កាលបរិច្ឆេទឱ្យបានច្បាស់លាស់នៅក្នុងខែនីមួយៗ ក្នុងរយៈពេលមួយឆ្នាំសម្រាប់ការប្រមូលពាក្យបណ្តឹង ហើយត្រូវផ្សព្វផ្សាយកាលបរិច្ឆេទនេះដល់អ្នកពាក់ព័ន្ធ។

ក្រុមគាំទ្រនៃ ក.គ.ខ ត្រូវទទួលខុសត្រូវក្នុងការធានាបើកប្រអប់សំបុត្រគណនេយ្យភាពឱ្យបានប្រចាំខែ។ ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី ខេត្ត និងជាលេខាធិការនៃ ក.គ.ខ ត្រូវធ្វើការណែនាំដល់ក្រុមសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឱ្យជួយដល់ក្រុមគាំទ្រនៃ ក.គ.ខ ក្នុងការប្រមូលពាក្យបណ្តឹងពីប្រអប់សំបុត្រគណនេយ្យភាពឱ្យបានជាទៀតទាត់រៀងរាល់ខែ។

អ្នកបើកប្រអប់សំបុត្រ និងអ្នកចូលរួមបើកប្រអប់សំបុត្រមិនអនុញ្ញាតឱ្យអានខ្លឹមសារនៅក្នុងពាក្យបណ្តឹងណាមួយឡើយ។

ក.គ.ខ ត្រូវកំណត់រយៈពេលនៃការប្រគល់ស្រោមសំបុត្រធំ និងកំណត់ហេតុមកឱ្យក្រុមគាំទ្រ។

ដើម្បីដំណើរការបើកប្រអប់សំបុត្រគណនេយ្យភាព ក្រុមសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដូចខាងក្រោម :

- ត្រូវមានស្រោមសំបុត្រធំ (ស្រោមសំបុត្រធំមួយប្រើសម្រាប់ច្រកពាក្យបណ្តឹងពីប្រអប់សំបុត្រគណនេយ្យភាពតែមួយប៉ុណ្ណោះ) និងបំពេញឈ្មោះក្រុង ស្រុក ខណ្ឌ លេខសម្គាល់ប្រអប់សំបុត្រ ទីតាំងប្រអប់សំបុត្រ និងកាលបរិច្ឆេទ នៅខាងខ្នងស្រោមសំបុត្រធំ
- ត្រូវបើកប្រអប់សំបុត្រគណនេយ្យភាពនៅចំពោះមុខអ្នកចូលរួម
- យកពាក្យបណ្តឹងទាំងអស់ពីប្រអប់សំបុត្រ ពិនិត្យស្ថានភាពពាក្យបណ្តឹង និងរាប់ចំនួនពាក្យបណ្តឹងទាំងនោះនៅចំពោះមុខអ្នកចូលរួម។ អ្នកបើកប្រអប់សំបុត្រ និងអ្នកចូលរួមបើកប្រអប់សំបុត្រ មិនអនុញ្ញាតឱ្យអានខ្លឹមសារនៅក្នុងពាក្យបណ្តឹងណាមួយឡើយ
- សរសេរកំណត់ហេតុបើកប្រអប់សំបុត្រ(ទម្រង់ទី២)។ ក្រុមសម្របសម្រួលមិនត្រូវដាក់បញ្ចូលកំណត់ហេតុបើកប្រអប់សំបុត្រទៅក្នុងស្រោមសំបុត្រធំទេ
- ច្រកពាក្យបណ្តឹងទាំងនោះចូលនៅក្នុងស្រោមសំបុត្រធំ
- បិទស្រោមសំបុត្រធំ និងចុះហត្ថលេខាលើគំរបស្រោមសំបុត្រធំ។

ទោះបីក្នុងពេលបើកប្រអប់សំបុត្រពុំមានពាក្យបណ្តឹងនៅក្នុងប្រអប់សំបុត្រគណនេយ្យភាពក៏ដោយ ក្រុមសម្របសម្រួលត្រូវមានកំណត់ហេតុបើកប្រអប់សំបុត្រគណនេយ្យភាព។

ការបើកប្រអប់សំបុត្រគណនេយ្យភាព ត្រូវមានសមាសភាពចម្រុះយ៉ាងតិច០៣ប្រភេទ។ សមាសភាពអ្នកចូលរួមបើកប្រអប់សំបុត្រត្រូវមាន :

**ក).** ករណីបើកប្រអប់សំបុត្រដែលស្ថិតនៅទីសាធារណៈ (ដូចជា សាលារៀន ទីផ្សារ វត្តអារាម..។ល។)

- តំណាងរដ្ឋបាលឃុំ សង្កាត់ (សមាជិកក្រុមប្រឹក្សា ឬស្មៀនឃុំ សង្កាត់) ឬតំណាងភូមិ (មេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិ)
- អ្នកសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា ប្រជាពលរដ្ឋ ឬសហគមមូលដ្ឋាន។

**ខ).** ករណីប្រអប់សំបុត្រស្ថិតនៅខាងមុខសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ :

- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- អ្នកសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា ប្រជាពលរដ្ឋ ឬសហគមមូលដ្ឋាន។

គ). ករណីប្រអប់សំបុត្រស្ថិតនៅការិយាល័យអង្គការមិនមែនរដ្ឋាភិបាល :

- តំណាងអង្គការមិនមែនរដ្ឋាភិបាលនៅទីនោះ
- អ្នកសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អ្នកពាក់ព័ន្ធផ្សេងទៀត ដូចជា ប្រជាពលរដ្ឋ ឬសហគមមូលដ្ឋាន។

អ្នកចូលរួមបើកប្រអប់សំបុត្រគណនេយ្យភាព ត្រូវចុះហត្ថលេខាលើកំណត់ហេតុ និងចុះហត្ថលេខាលើស្រោមសំបុត្រធំ។

អ្នកសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកស្រោមសំបុត្រធំ(ច្រកបណ្តឹង) និងកំណត់ហេតុបើកប្រអប់សំបុត្រគណនេយ្យភាពនេះមកប្រគល់ជូនក្រុមគាំទ្រនៃ ក.គ.ខ។

ទម្រង់ទី២ : កំណត់ហេតុបើកប្រអប់សំបុត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

# បើកប្រអប់សំបុត្រគណនេយ្យភាព

នៅវេលាម៉ោង.................... ថ្ងៃទី........... ខែ.................... ឆ្នាំ.............. យើងខ្ញុំទាំងអស់គ្នាដូចមានរាយនាមខាងក្រោម :

១. ........................................... តួនាទី................................. ហត្ថលេខា.................................

២. ........................................... តួនាទី................................. ហត្ថលេខា.................................

៣. ........................................... តួនាទី................................. ហត្ថលេខា.................................

៤. ........................................... តួនាទី................................. ហត្ថលេខា.................................

៥. ........................................... តួនាទី................................. ហត្ថលេខា.................................

បានបើកប្រអប់សំបុត្រគណនេយ្យភាពលេខ.................... ដែលដាក់នៅ(ទីតាំងប្រអប់សំបុត្រ):........................ ....................................ស្ថិតក្នុងឃុំ សង្កាត់ :................................ ក្រុង ស្រុក ខណ្ឌ :............................... រាជធានី ខេត្ត :.........................................។

លទ្ធផលនៃការបើកប្រអប់សំបុត្រមានដូចខាងក្រោម :

| ល.រ | ការបរិយាយ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | ពាក្យបណ្តឹងដែលដាក់ក្នុងស្រោមសំបុត្រ | | |
| ២ | ពាក្យបណ្តឹងដែលមិនដាក់ក្នុងស្រោមសំបុត្រ | | |
| **សរុប** | | | |

**សម្គាល់ :** ស្ថានភាពពាក្យបណ្តឹង (រហែក ដាមខូចដោយទឹកភ្លៀង) និងប្រអប់សំបុត្រ (ប្រអប់សំបុត្របែកបាក់ ច្រេះស៊ី ធ្លាយចូលទឹក សោរខូច...។ល។) ប្រសិនបើមាន សូមសរសេរខាងក្រោមនេះ :

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

យើងខ្ញុំទាំងអស់គ្នាបានបើកប្រអប់សំបុត្រដោយពិនិត្យ និងឯកភាពលើកំណត់ហេតុនេះទាំងស្រុង។

### ២.៣.២. ការប្រមូលពាក្យបណ្តឹងពីសមាជិក ក.គ.ខ និងមន្ត្រីជំនួយការ

ក្រុមគាំទ្រត្រូវធ្វើការទំនាក់ទំនងជាប្រចាំជាមួយសមាជិក ក.គ.ខ ទាំងអស់ ដើម្បីប្រមូលពាក្យបណ្តឹងដែលប្រជាពលរដ្ឋបានរាយការណ៍ដោយផ្ទាល់ចំពោះមុខ ឬតាមរយៈទូរស័ព្ទអំពីព័ត៌មានពាក់ព័ន្ធភាពមិនប្រក្រតី។

ក្នុងករណីដែលប្រជាពលរដ្ឋប្តឹង ឬរាយការណ៍តាមរយៈទូរស័ព្ទ(Hotline) មន្ត្រីជំនួយការត្រូវប្រគល់កំណត់ហេតុជូនក្រុមគាំទ្រ។

## ២.៤. ការប្រគល់ ទទួលស្រោមសំបុត្រ និងកំណត់ហេតុ

ក្រុមគាំទ្រត្រូវមានសៀវភៅកត់ត្រាពាក្យបណ្តឹងប្រចាំឆ្នាំដោយប្រើទម្រង់ទី៣។

អ្នកសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវប្រគល់ស្រោមសំបុត្រធំ និងកំណត់ហេតុបើកប្រអប់សំបុត្រទៅឱ្យក្រុមគាំទ្រ។

សមាជិក ក.គ.ខ ត្រូវប្រគល់កំណត់ហេតុពាក្យបណ្តឹង (កំណត់ហេតុដែលប្រជាពលរដ្ឋបានប្តឹង ឬរាយការណ៍ដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ) ទៅឱ្យក្រុមគាំទ្រសម្រាប់ធ្វើការកត់ត្រា។

នៅពេលដែលទទួលបានស្រោមសំបុត្រធំ និងកំណត់ហេតុបើកប្រអប់សំបុត្រ និងកំណត់ហេតុពាក្យបណ្តឹង ក្រុមគាំទ្រត្រូវកត់ត្រាដោយប្រើទម្រង់ទី៣ (ការកត់ត្រាពាក្យបណ្តឹង)។ ការកត់ត្រាពាក្យបណ្តឹងត្រូវមានការចុះហត្ថលេខាប្រគល់ ទទួលពីអ្នកសម្របសម្រួល ឬសមាជិក ក.គ.ខ។

ក្រុមគាំទ្រត្រូវរក្សាទុកសៀវភៅកត់ត្រាពាក្យបណ្តឹងឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព សម្រាប់រាយការណ៍ជូន ក.គ.ខ ឬការផ្សព្វផ្សាយ។

របៀបបំពេញទម្រង់ទី៣ មានដូចខាងក្រោម ៖

- កូឡោនទី១ ៖ សរសេរលេខរៀង ដោយចាប់ផ្តើមពី១, ២, ៣, . . .។
- កូឡោនទី២ ៖ ចុះថ្ងៃ ខែ ឆ្នាំ ដែលក្រុមគាំទ្រទទួលស្រោមសំបុត្រធំពីក្រុមសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងទទួលកំណត់ពាក្យបណ្តឹងពីប្រភពផ្សេងទៀត។
- កូឡោនទី៣ ៖ ចុះលេខប្រអប់សំបុត្រ ដែលបានសរសេរនៅលើស្រោមសំបុត្រធំច្រកពាក្យបណ្តឹង។ ករណីពាក្យបណ្តឹងដែលប្រជាពលរដ្ឋបានរាយការណ៍ផ្ទាល់ ឬតាមទូរស័ព្ទ សូមសរសេរ "**គ្មាន**"។
- កូឡោនទី៤ ៖ បញ្ជាក់ទីតាំងប្រអប់សំបុត្រ ឬប្រភពពាក្យបណ្តឹងដែលបានទទួល។
- កូឡោនទី៥ ៖ សូមគូស"✓" ប្រសិនបើពាក្យបណ្តឹងនោះទទួលបានតាមរយៈប្រអប់សំបុត្រ។
- កូឡោនទី៦ ៖ សូមគូស"✓" ប្រសិនបើពាក្យបណ្តឹងនោះទទួលបានតាមរយៈទូរស័ព្ទ។
- កូឡោនទី៧ ៖ សូមគូស"✓" ប្រសិនបើពាក្យបណ្តឹងនោះទទួលបានតាមរយៈការរាយការណ៍ផ្ទាល់។
- កូឡោនទី៨ ៖ សូមសរសេរលេខ "១" ប្រសិនបើពាក្យបណ្តឹងនោះទទួលបានតាមរយៈប្រអប់សំបុត្រ និងសរសេរលេខ "0" ប្រសិនបើពាក្យបណ្តឹងទទួលបានតាមរយៈរាយការណ៍ផ្ទាល់ ឬទូរស័ព្ទ។

- កូឡោនទី៩ ៖ កត់ត្រាចំនួនពាក្យបណ្តឹងជាក់ស្តែងដោយផ្អែកលើកំណត់ហេតុបើកប្រអប់សំបុត្រ និងពាក្យបណ្តឹងទទួលបានតាមរយៈរាយការណ៍ផ្ទាល់ ឬទូរស័ព្ទ ។
- កូឡោនទី១០ ៖ អ្នកប្រគល់ចុះឈ្មោះនៅក្នុងកូឡោននេះ ។
- កូឡោនទី១១ ៖ អ្នកប្រគល់ចុះហត្ថលេខានៅក្នុងកូឡោននេះ ។

ឧទាហរណ៍ : ទម្រង់ទី៣: ការកត់ត្រាពាក្យបណ្ដឹង

# ការកត់ត្រាពាក្យបណ្ដឹង

| ល.រ | ថ្ងៃ ខែ ឆ្នាំ ទទួល | លេខ ប្រអប់ | បរិយាយ | តាមរយៈ | | | កំណត់ហេតុ បើកប្រអប់ | ចំនួនពាក្យ បណ្ដឹង | ការប្រគល់ | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ប្រអប់ | ទូរស័ព្ទ | ផ្សេងៗ | | | អ្នកប្រគល់ | ហត្ថលេខា |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 |
| 1 | 05/05/09 | 001 | សាលារៀនក្រគរ ឃុំក្រគរ ស្រុកក្រគរ | ✓ | | | 1 | 20 | | |
| 2 | 05/05/09 | 002 | សាលាឃុំក្រគរ ស្រុកក្រគរ | ✓ | | | 1 | 10 | | |
| 3 | 05/05/09 | 003 | សាលាស្រុកក្រគរ | ✓ | | | 1 | 17 | | |
| 4 | 06/05/09 | គ្មាន | ពាក្យបណ្ដឹងទទួលពីសមាជិក ក.គ.ខ ឈ្មោះ ក.ច | | ✓ | | 0 | 2 | | |
| 5 | 09/06/09 | គ្មាន | ពាក្យបណ្ដឹងទទួលពីសមាជិក ក.គ.ខ ឈ្មោះ ប.ព | | | ✓ | 0 | 1 | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

# ផ្នែកទី៣
# នីតិវិធីដោះស្រាយពាក្យបណ្ដឹង

ក.គ.ខ មិនមានសមត្ថកិច្ចដោះស្រាយពាក្យបណ្ដឹងដូចសមត្ថកិច្ចតុលាការទេ។ ក.គ.ខ ត្រូវធ្វើការសិក្សាស្រាវជ្រាវលើករណីដែលបានលើកឡើង និងធ្វើការសម្រេចផ្ដល់ទៅឱ្យអង្គភាព ឬស្ថាប័នពាក់ព័ន្ធអនុវត្តវិធានការដាក់ទណ្ឌកម្ម ឬដោះស្រាយស្របតាមនីតិវិធីជាធរមាន។

## ៣.១. គោលការណ៍នៃការដោះស្រាយពាក្យបណ្ដឹង

គោលការណ៍នៃការដោះស្រាយពាក្យបណ្ដឹងមានដូចខាងក្រោម :

- ការដោះស្រាយពាក្យបណ្ដឹងត្រូវធ្វើឡើងក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ ក.គ.ខ
- ការដោះស្រាយពាក្យបណ្ដឹងដែលប្រមូលបានត្រូវធ្វើឡើងតាមរយៈការពិភាក្សា និងសម្រេចដោយកិច្ចប្រជុំរបស់ ក.គ.ខ តែប៉ុណ្ណោះ
- រាល់កិច្ចប្រជុំរបស់ ក.គ.ខ ក្នុងការដោះស្រាយពាក្យបណ្ដឹងត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។
- ការដោះស្រាយពាក្យបណ្ដឹងត្រូវធ្វើឡើងដោយមានតម្លាភាព
- ការពិភាក្សាត្រូវមានមូលដ្ឋានច្បាស់លាស់ដោយផ្អែកលើរបាយការណ៍នៃការស៊ើបអង្កេត ហើយការសម្រេចរបស់ ក.គ.ខ ត្រូវផ្អែកលើច្បាប់ ឬលិខិតបទដ្ឋានជាធរមាន
- មិនអនុញ្ញាតឱ្យសមាជិក ក.គ.ខ រូបណាដែលមានការពាក់ព័ន្ធក្នុងជម្លោះផលប្រយោជន៍ចូលរួមនៅក្នុងដំណើរការដោះស្រាយពាក្យបណ្ដឹងឡើយ
- ដើមបណ្ដឹង អ្នកផ្ដល់ព័ត៌មាន និងសាក្សី ត្រូវទទួលបានការការពារឱ្យផុតពីការគំរាមកំហែង និងការសងសឹកណាមួយ
- ធានាសុវត្ថិភាព និងជៀសវាងការទទួលរងផលប៉ះពាល់ចំពោះមន្ត្រីរាជការ ដែលបានដាក់ពាក្យបណ្ដឹងរាយការណ៍ ឬជួយផ្ដល់ព័ត៌មានអំពីការប្រព្រឹត្តដោយបុគ្គលណាម្នាក់ផ្សេងទៀត។

## ៣.២. ការដោះស្រាយពាក្យបណ្ដឹង

ការដោះស្រាយពាក្យបណ្ដឹងត្រូវដំណើរការតាមជំហានដូចខាងក្រោម :

- **ជំហានទី១ : ការសម្រាំងពាក្យបណ្ដឹង**
- **ជំហានទី២ : ការវាយតម្លៃ**
- **ជំហានទី៣ : ការរៀបចំផែនការស៊ើបអង្កេត**
- **ជំហានទី៤ : ការស៊ើបអង្កេត**
- **ជំហានទី៥ : ការធ្វើសេចក្ដីសម្រេច**
- **ជំហានទី៦ : ការអនុវត្តសេចក្ដីសម្រេច និងតាមដាន**
- **ជំហានទី៧ : ការផ្ដល់ព័ត៌មានត្រឡប់**

# ជំហានទី ១
# ការសម្រាំងពាក្យបណ្តឹង

## ១.១. គោលបំណង

ការធ្វើសម្រាំងពាក្យបណ្តឹង គឺដើម្បី :

- សិក្សាអង្គហេតុនៃពាក្យបណ្តឹងដែលប្រមូលបាន
- កំណត់ពាក្យបណ្តឹងណាខ្លះដែលត្រូវដោះស្រាយ និងចាត់អាទិភាពពាក្យបណ្តឹងដែលត្រូវដោះស្រាយ
- កំណត់ពាក្យបណ្តឹងណាខ្លះដែលមិនត្រូវដោះស្រាយ( បញ្ចប់សំណុំរឿង) ។

## ១.២. គោលការណ៍

ក.គ.ខ ត្រូវទទួលខុសត្រូវក្នុងការធ្វើសម្រាំងពាក្យបណ្តឹងជារៀងរាល់ខែ។ ពាក្យបណ្តឹងត្រូវធ្វើការសម្រាំងក្នុងរយៈពេលយ៉ាងយូរ០២សប្តាហ៍ បន្ទាប់ពីការប្រមូលពាក្យបណ្តឹងចប់សព្វគ្រប់នៅតាមខែនីមួយៗ។

ប្រធាន ក.គ.ខ ត្រូវចាត់តាំងសមាជិករបស់ខ្លួនយ៉ាងតិច០២រូប ដើម្បីត្រួតពិនិត្យ និងតាមដានការធ្វើសម្រាំងពាក្យបណ្តឹង។ ក្នុងចំណោមសមាជិកយ៉ាងតិច០២រូបនេះ សមាជិកមួយរូបត្រូវជាតំណាងពីអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកទទួលការ ឬប្រធានទីប្រឹក្សាគម្រោង PSDD ប្រចាំរាជធានី ខេត្ត និងសមាជិក ក.គ.ខ មួយចំនួនទៀតជាការចាត់តាំងរបស់ប្រធាន ក.គ.ខ។

ការធ្វើសម្រាំងពាក្យបណ្តឹងត្រូវធ្វើឡើងដោយក្រុមគាំទ្រនៃ ក.គ.ខ ដោយមានការជួយពីមន្ត្រីជំនួយការ និងស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យពីសមាជិក ក.គ.ខ ដែលបានតែងតាំងខាងលើ។

ក.គ.ខ ត្រូវប្រជុំពិនិត្យ និងសម្រេចសេចក្តីព្រាងរបាយការណ៍សម្រាំងពាក្យបណ្តឹង។

## ១.៣. ដំណើរការ

### ១.៣.១. ការសម្រាំងពាក្យបណ្តឹង

ការសម្រាំងពាក្យបណ្តឹងត្រូវដំណើរការដូចខាងក្រោម :

- សមាជិក ក.គ.ខ ដែលបានចាត់តាំង ត្រូវពិនិត្យស្ថានភាពស្រោមសំបុត្រធំ ហើយបើកស្រោមសំបុត្រធំដែលច្រកពាក្យបណ្តឹងទទួលបានពីប្រអប់សំបុត្រ និងស្រោមសំបុត្រកំណត់ហេតុពាក្យបណ្តឹង ( កំណត់ហេតុដែលប្រជាពលរដ្ឋបានប្តឹង ឬរាយការណ៍ដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ) ។ ការបើកស្រោមសំបុត្រធំត្រូវធ្វើម្តងមួយៗតាមលំដាប់លំដោយ។
- សមាជិក ក.គ.ខ ត្រូវប្រគល់ស្រោមសំបុត្រដែលបានបើករួចទៅឱ្យក្រុមគាំទ្រ។
- ក្រុមគាំទ្រត្រូវបង់លេខរៀងលើពាក្យបណ្តឹងនីមួយៗ។ ការបង់លេខរៀងពាក្យបណ្តឹងត្រូវអនុវត្តដូច

ខាងក្រោម ៖

– ករណីពាក្យបណ្ដឹងពីប្រអប់សំបុត្រគណនេយ្យភាព ៖ BBB /CCC/YY （ឧទា ៖ 001/001/09）

– ករណីពាក្យបណ្ដឹងពីទូរស័ព្ទ ឬរាយការណ៍ផ្ទាល់ ឬប្រភពផ្សេងទៀត ៖ CCC/YY（ឧទា ៖ 004/09）

**កំណត់សម្គាល់ ៖**

⇨ B ៖ លេខសម្គាល់ប្រអប់សំបុត្រគណនេយ្យភាព

⇨ C ៖ លេខរៀងពាក្យបណ្ដឹង

⇨ Y ៖ លេខឆ្នាំ

⇨ ការចុះលេខរៀងពាក្យបណ្ដឹងធ្វើឡើងសម្រាប់ឆ្នាំនីមួយៗ ។

- ក្រុមគាំទ្រត្រូវអានពាក្យបណ្ដឹងម្ដងមួយៗ ដែលបានដកចេញពីស្រោមសំបុត្រ ដោយពិនិត្យខ្លឹមសារនៃពាក្យបណ្ដឹង ដើម្បីសិក្សាអង្គហេតុដូចខាងក្រោម ៖

– តើនរណាជាដើមបណ្ដឹង?

– តើនរណាជាជនត្រូវចោទ?

– តើគេប្ដឹងអំពីអ្វី?

– តើព្រឹត្តិការណ៍កើតឡើងពេលណា? ទីកន្លែងណា?

– តើមានផលប៉ះពាល់លើអ្វីខ្លះ ឬនរណាខ្លះ?

– តើខ្លឹមសារនៃពាក្យបណ្ដឹងជាព័ត៌មាន ឬសំណូមពរផ្សេងៗ?

- បន្ទាប់មក ក្រុមគាំទ្រត្រូវពិចារណាលើករណីទាំងអស់នោះ ដើម្បីកំណត់ថាពាក្យបណ្ដឹងណាត្រូវដោះស្រាយ ឬមិនត្រូវដោះស្រាយ ។ ក្នុងការកំណត់ថាពាក្យបណ្ដឹងណាមួយត្រូវដោះស្រាយ ឬមិនត្រូវដោះស្រាយ ក្រុមគាំទ្រត្រូវធ្វើការពិចារណាអង្គហេតុដែលបានសិក្សាខាងលើ ដោយផ្អែកទៅលើចំណុចដូចខាងក្រោម ៖

– **ពាក្យបណ្ដឹងត្រូវដោះស្រាយ** ៖ រួមមានករណីទាំងឡាយណាដែល**ស្ថិតនៅក្នុងសមត្ថកិច្ច**របស់ ក.គ.ខ ដែលបានកំណត់ក្នុងចំណុច១.២（សមត្ថកិច្ចរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត）។

– **ពាក្យបណ្ដឹងមិនត្រូវដោះស្រាយ** ៖ រួមមានករណីទាំងឡាយណាដែល**មិនស្ថិតនៅក្នុងសមត្ថកិច្ច**របស់ ក.គ.ខ ដែលបានកំណត់ក្នុងចំណុច១.២ ។ ករណីទាំងនោះមានដូចជា ៖

+ សំណូមពរទូទៅ ឬ

+ ព័ត៌មានអំពីករណីបទល្មើសព្រហ្មទណ្ឌ រដ្ឋប្បវេណី ឬករណីផ្សេងៗទៀតពាក់ព័ន្ធរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ។

+ វិវាទទាំងឡាយណាដែលបានកំណត់ក្នុងច្បាប់ ឬលិខិតបទដ្ឋាននានាដែលតម្រូវឱ្យស្ថាប័ន ឬយន្តការជាក់លាក់ណាមួយទទួលបន្ទុកដោះស្រាយ ។

- បន្ទាប់មក ក្រុមគាំទ្រត្រូវធ្វើការចាត់អាទិភាពពាក្យបណ្ដឹងដែលត្រូវដោះស្រាយ ។ ការចាត់អាទិភាពត្រូវធ្វើការពិចារណាលើពាក្យបណ្ដឹងណាដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ និងចាំបាច់បន្ទាន់ដែលត្រូវដោះស្រាយ ។
- ក្រុមគាំទ្រត្រូវរៀបចំសេចក្ដីព្រាងរបាយការណ៍លទ្ធផលសម្រាំងពាក្យបណ្ដឹង ដោយប្រើទម្រង់ទី៤ ។ ក្រុមគាំទ្រត្រូវបំពេញទម្រង់ទី៤ ដូចខាងក្រោម ៖
  – កូឡោនទី១ ៖ សរសេរលេខរៀង ដោយចាប់ផ្ដើមពី ១, ២, ៣ . . . ។
  – កូឡោនទី២ ៖ សរសេរលេខសម្គាល់ស្រោមសំបុត្រ (លេខសម្គាល់ស្រោមសំបុត្រធំគឺជាលេខសម្គាល់ប្រអប់សំបុត្រ) ក្នុងករណីពាក្យបណ្ដឹងប្រមូលពីប្រអប់សំបុត្រ។ សូមសរសេរ "**គ្មាន**" នៅក្នុងកូឡោននេះ ក្នុងករណីពាក្យបណ្ដឹងរាយការណ៍ដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទ ។
  – កូឡោនទី៣ ៖ ចុះលេខរៀងពាក្យបណ្ដឹង (ឧទា ៖ 001/001/09) ឱ្យច្បាស់លាស់ដើម្បីងាយស្រួលស្វែងរកពាក្យបណ្ដឹងនីមួយៗនៅពេលក្រោយ ។
  – កូឡោនទី៤ ៖ សរសេរការបរិយាយអំពីខ្លឹមសារនៃពាក្យបណ្ដឹងដែលបានសិក្សា។ ចំពោះបណ្ដឹងខ្លះយើងពុំអាចបំពេញគ្រប់សំណួរនៅក្នុងកូឡោននេះបានទេ ។
  – កូឡោនទី៥ ៖ សូមគូស "✓" នៅក្នុងកូឡោននេះ បើពិនិត្យឃើញថាបណ្ដឹងនោះត្រូវដោះស្រាយ ។
  – កូឡោនទី៦ ៖ សូមគូស "✓" នៅក្នុងកូឡោននេះ បើពិនិត្យឃើញថាបណ្ដឹងនោះមិនត្រូវដោះស្រាយ ។
  – កូឡោនទី៧ ៖ ចាត់អាទិភាពទៅលើពាក្យបណ្ដឹងដែលត្រូវដោះស្រាយ ( ខ្ពស់ មធ្យម ទាប) និងសូមគូសខ្វែង ក្នុងករណីពាក្យបណ្ដឹងមិនត្រូវដោះស្រាយ ។

### ១.៣.២. ការពិនិត្យ និងសម្រេចលើការសម្រាំងពាក្យបណ្ដឹងដោយ ក.គ.ខ

- ក.គ.ខ ត្រូវធ្វើការប្រជុំដើម្បីពិនិត្យលើរបាយការណ៍លទ្ធផលសម្រាំងពាក្យបណ្ដឹង ។ នៅក្នុងកិច្ចប្រជុំ ក.គ.ខ ត្រូវមានវត្តមានសមាជិក ក.គ.ខ ដែលបានចាត់តាំងក្នុងការពិនិត្យមើលការសម្រាំងពាក្យបណ្ដឹង ។ សមាជិក ក.គ.ខ ដែលបានចាត់តាំងត្រូវរាយការណ៍ជូនអង្គប្រជុំ ក.គ.ខ អំពីលទ្ធផលសម្រាំងពាក្យបណ្ដឹង ។
- កិច្ចប្រជុំ ក.គ.ខ ត្រូវធ្វើការពិនិត្យលើគ្រប់ករណីបណ្ដឹងទាំងអស់នៅក្នុងរបាយការណ៍លទ្ធផលសម្រាំងពាក្យបណ្ដឹង ដែលក្រុមសម្រាំងបានរៀបចំដោយពិនិត្យទៅលើអង្គហេតុពាក្យបណ្ដឹងម្ដងមួយៗ ។ កិច្ចប្រជុំ ក.គ.ខ ត្រូវធ្វើការសម្រេចទៅលើ ៖
  – ករណីណាខ្លះដែលត្រូវដោះស្រាយ
  – ករណីណាខ្លះដែលមិនត្រូវដោះស្រាយ និងសម្រេចបញ្ចប់សំណុំរឿង
  – ករណីដែលត្រូវដោះស្រាយ (ត្រូវចាត់អាទិភាពបណ្ដឹងប្រភេទនេះ ដើម្បីធ្វើការស៊ើបអង្កេត) ។

ឧទាហរណ៍ : ទម្រង់ទី៤: របាយការណ៍សម្រាំងពាក្យបណ្តឹង

## របាយការណ៍សម្រាំងពាក្យបណ្តឹង

## សម្រាប់ខែ.................. ឆ្នាំ២០........

- សរុបពាក្យបណ្តឹងទាំងអស់ ចំនួន : ..០៤...ច្បាប់ (តាមរយៈប្រអប់សំបុត្រ :....០៣.....ច្បាប់ ទូរស័ព្ទ :.....០១....ច្បាប់ ផ្សេងទៀត :...០០....ច្បាប់)
- ពាក្យបណ្តឹងត្រូវដោះស្រាយ ចំនួន :..០៣.....ច្បាប់
- ពាក្យបណ្តឹងមិនត្រូវដោះស្រាយ ចំនួន :...០១....ច្បាប់

| ល.រ | លេខស្រោមសំបុត្រធំ | លេខរៀងពាក្យបណ្តឹង | ការពិពណ៌នាអង្គហេតុ | ត្រូវដោះស្រាយ | មិនត្រូវដោះស្រាយ | អាទិភាព |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 1 | 001 | 001/001/09 | យើងខ្ញុំជាប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិ ក សូមប្តឹងតវ៉ាចំពោះអ្នកម៉ៅការ ឈ្មោះ ម.ថ ដែលបានធ្វើស្ពាននៅក្នុងឃុំពុំមានគុណភាព។ | ✓ | | ខ្ពស់ |
| 2 | 001 | 001/002/09 | ជនពាលក្នុងភូមិបានឆក់ត្រី និងការកាប់បំផ្លាញជំរកត្រីពងអស់ ៣០ ហិចតា ក្នុងបឹងស្នោ នៅក្នុងឃុំ ក.ថ | ✓ | | ខ្ពស់ |
| 3 | 002 | 002/003/09 | សំណូមពរសុំសង់ស្ពានថ្មនៅឃុំ ឃ ។ | | ✓ | ☒ |
| 4 | គ្មាន | 004/09 | ស្មៀនឃុំ ខ.៣ មិនគោរពវិន័យការងារ ដោយតែងតែមកធ្វើការយឺតជារៀងរាល់ថ្ងៃ។ | ✓ | | មធ្យម |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# ជំហានទី២
# ការវាយតម្លៃ

## ២.១. គោលបំណង

ការវាយតម្លៃលើពាក្យបណ្តឹងមានគោលបំណងដើម្បី :

- សិក្សាអង្គច្បាប់ទៅលើករណីនីមួយៗ និងកំណត់ថាតើបានបំពានលើច្បាប់ ឬលិខិតបទដ្ឋានណាខ្លះ
- ធ្វើការសន្និដ្ឋានលើអង្គហេតុ ដើម្បីស៊ើបអង្កេត ឬសម្រេចបិទសំណុំរឿង
- ផ្តល់ព័ត៌មានត្រឡប់ទៅប្រជាពលរដ្ឋដើម្បីបង្កើនភាពជឿទុកចិត្ត និងការចូលរួមពីប្រជាពលរដ្ឋ។

## ២.២. គោលការណ៍

ការវាយតម្លៃត្រូវធ្វើឡើងដោយ ក.គ.ខ និងដោយមានជំនួយការពីក្រុមគាំទ្រ។

ការវាយតម្លៃលើពាក្យបណ្តឹងត្រូវអនុវត្តចំពោះបណ្តឹងដែល ក.គ.ខ បានសម្រេចថាត្រូវដោះស្រាយតែប៉ុណ្ណោះ។

ការវាយតម្លៃលើពាក្យបណ្តឹងត្រូវមានមូលដ្ឋានលើអង្គហេតុ និងអង្គច្បាប់ដែលបានរំលោភបំពាន។

សេចក្តីសម្រេចរបស់ ក.គ.ខ ក្នុងការស៊ើបអង្កេតលើពាក្យបណ្តឹងត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំ ក.គ.ខ។

## ២.៣. ដំណើរការ

### ២.៣.១. ដំណាក់កាលត្រៀមរៀបចំ

- ក្រុមគាំទ្រត្រូវពិនិត្យអង្គច្បាប់បឋមចំពោះពាក្យបណ្តឹងនីមួយៗដែល ក.គ.ខ បានសម្រេចថាត្រូវដោះស្រាយ ដោយផ្អែកលើលទ្ធផលនៃការធ្វើសម្រាំងពាក្យបណ្តឹងក្នុងជំហានទី១។ ការពិនិត្យអង្គច្បាប់នេះ គឺត្រូវពិនិត្យថាតើពាក្យបណ្តឹងនេះបានរំលោភបំពានទៅនឹងបទប្បញ្ញត្តិណាខ្លះនៃច្បាប់ ឬលិខិតបទដ្ឋានពាក់ព័ន្ធនានា។ ក្នុងករណីដែលការពិនិត្យអង្គច្បាប់បឋម ពុំអាចរកឃើញថាអង្គហេតុមានការរំលោភបំពានលើច្បាប់ ឬលិខិតបទដ្ឋានណាមួយ ក្រុមគាំទ្រត្រូវផ្តល់អនុសាសន៍បញ្ចប់សំណុំរឿង។
- ក្រុមគាំទ្រត្រូវធ្វើរបាយការណ៍វាយតម្លៃពាក្យបណ្តឹងសម្រាប់ដាក់ជូនកិច្ចប្រជុំ ក.គ.ខ ដោយផ្អែកទៅលើលទ្ធផលសម្រាំងពាក្យបណ្តឹង និងការពិនិត្យអង្គច្បាប់បឋមរបស់ខ្លួន។ ការធ្វើរបាយការណ៍នេះត្រូវប្រើប្រាស់ទម្រង់ទី៥(របាយការណ៍វាយតម្លៃពាក្យបណ្តឹង)។ ក្នុងករណីដែលការពិនិត្យអង្គច្បាប់បឋម ពុំអាចរកឃើញថាអង្គហេតុមានការរំលោភបំពានលើច្បាប់ ឬលិខិតបទដ្ឋានណាមួយ ក្រុមគាំទ្រត្រូវផ្តល់អនុសាសន៍បញ្ចប់សំណុំរឿងនៅក្នុងកូឡោនទី៨ (សេចក្តីសម្រេចដោយ ក.គ.ខ)។
- លេខាធិការនៃ ក.គ.ខ ត្រូវរៀបចំកិច្ចប្រជុំ ក.គ.ខ ដើម្បីធ្វើការវាយតម្លៃលើពាក្យបណ្តឹង។

### ២.៣.២. ការពិនិត្យអង្គច្បាប់ដោយកិច្ចប្រជុំ ក.គ.ខ

ការពិនិត្យអង្គច្បាប់ដោយក.គ.ខ តាមរយៈកិច្ចប្រជុំ ក.គ.ខ អនុវត្តដូចខាងក្រោម :

- លេខាធិការនៃ ក.គ.ខ ត្រូវអានអង្គហេតុនៃពាក្យបណ្តឹងនីមួយៗ សម្រាប់សមាជិក ក.គ.ខ ធ្វើការពិចារណា។
- អង្គប្រជុំ ក.គ.ខ ត្រូវពិភាក្សាលើអង្គហេតុ ហើយពិចារណាអំពីភាពពាក់ព័ន្ធទៅនឹងច្បាប់ ឬលិខិតបទដ្ឋាននានា និងឆ្លុះបញ្ចាំងអំពីការរំលោភបំពានទៅលើបទប្បញ្ញត្តិនៃច្បាប់ ឬលិខិតបទដ្ឋានពាក់ព័ន្ធ។
- ក.គ.ខ ធ្វើសេចក្តីសម្រេចដូចខាងក្រោម :
  - ករណីណាខ្លះ ដែលត្រូវស៊ើបអង្កេតពេញលេញ
  - ករណីណាខ្លះ ដែលត្រូវស៊ើបអង្កេតមិនពេញលេញ
  - ករណីណាខ្លះដែលត្រូវបញ្ចប់(បិទសំណុំរឿង) ដោយមូលហេតុមិនអាចរកការបញ្ជាក់ទៅលើអង្គច្បាប់បាន។

ក្នុងការពិចារណា ដើម្បីសម្រេចថាករណីណាមួយ ដែលត្រូវស៊ើបអង្កេតពេញលេញ ឬមិនពេញលេញ ក.គ.ខ ត្រូវផ្អែកទៅលើ :

⇨ ចំពោះសមត្ថកិច្ចរបស់ ក.គ.ខ ដែលចែងក្នុង **១.២** ចំណុច **ក** (ការប្រើប្រាស់ថវិកាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ) និងចំណុច **ខ.១** (ការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ) ករណីដែលពាក់ព័ន្ធនឹងសមត្ថកិច្ចនេះ **ត្រូវធ្វើការស៊ើបអង្កេតពេញលេញ**។

⇨ ចំពោះសមត្ថកិច្ចរបស់ ក.គ.ខ ដែលចែងក្នុង **១.២** ចំណុច **ខ.២** ( ការបំពេញតួនាទី និងភារកិច្ចរបស់បុគ្គលិកមន្ទីរ អង្គភាព អាជ្ញាធរនានា ដែលបម្រើការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់)។ ករណីនេះ **ត្រូវធ្វើការស៊ើបអង្កេតមិនពេញលេញ**។

តារាងខាងក្រោមនេះជាឧទាហរណ៍មួយចំនួនក្នុងការពិចារណា និងសម្រេចលើពាក្យបណ្តឹងស៊ើបអង្កេតពេញលេញ ឬមិនពេញលេញ ឬបញ្ចប់សំណុំរឿង។

| សេចក្តីសង្ខេបអង្គហេតុ | ការវិភាគបណ្តឹង | ការសម្រេច |
|---|---|---|
| ១. ស្មៀនឃុំ ព.ណ យកលុយរដ្ឋបាលឃុំប្រើប្រាស់ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩។ | បណ្តឹងនេះពាក់ព័ន្ធនឹងមូលនិធិឃុំ សង្កាត់ (ត្រង់ចំណុច ក.៣ នៃចំណុច ១.២ សមត្ថកិច្ចរបស់ ក.គ.ខ)។ | ស៊ើបអង្កេតពេញលេញ |
| ២. ស្មៀនឃុំ ច.ណ យកលុយថ្លៃសេវាចុះបញ្ជីកំណើតលើសតម្លៃកំណត់ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។ | បណ្តឹងនេះពាក់ព័ន្ធនឹងការបំពេញការងាររបស់ស្មៀន (ត្រង់ចំណុច ខ.១ នៃចំណុច ១.២ សមត្ថកិច្ចរបស់ ក.គ.ខ )។ | ស៊ើបអង្កេតពេញលេញ |

| សេចក្ដីសង្ខេបអង្គហេតុ | ការវិភាគបណ្ដឹង | ការសម្រេច |
|---|---|---|
| ៣. ថវិកាគម្រោងសាកល្បងនៅថ្នាក់ស្រុក ក.គ មិនបានផ្ដល់គ្រប់ចំនួនតាមការស្នើសុំ ដោយមានការកាត់ថវិកាក្រៅផ្លូវការ នៅខែកក្កដា ឆ្នាំ២០០៩។ | បណ្ដឹងនេះពាក់ព័ន្ធទៅនឹងការប្រើប្រាស់ថវិកាដែលស្ថិតនៅក្នុងផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប (ត្រង់ចំណុចក.១ នៃចំណុច១.២ សមត្ថកិច្ចរបស់ ក.គ.ខ)។ | ស៊ើបអង្កេតពេញលេញ |
| ៤. មន្ត្រីរតនាគារខេត្ត ក.ខ ឈ្មោះ ច.ជ បានទាមទារកម្រៃក្រៅផ្លូវការមិនស្របច្បាប់ពីគម្រោងឃុំនៅឆ្នាំ២០០៩។ | បណ្ដឹងនេះពាក់ព័ន្ធនឹងមូលនិធិឃុំ សង្កាត់ (ត្រង់ចំណុច ក.៣ នៃចំណុច ១.២ សមត្ថកិច្ចរបស់ក.គ.ខ)។ | ស៊ើបអង្កេតពេញលេញ |
| ៥. អ្នកទទួលការឈ្មោះ ច.ច បានឃុបឃិតជាមួយមន្ត្រីគាំទ្របច្ចេកទេសក្នុងការដេញថ្លៃធ្វើផ្លូវលំនៅឃុំ ព.ព នៅខែមីនា ឆ្នាំ២០០៩។ | បណ្ដឹងនេះពាក់ព័ន្ធនឹងការបំពេញការងាររបស់មន្ត្រីថ្នាក់ក្រោមជាតិ (ចែងចំណុច ខ.១ នៃចំណុច១.២ សមត្ថកិច្ចរបស់ ក.គ.ខ) | ស៊ើបអង្កេតពេញលេញ |
| ៦. ការឃុបឃិតគ្នារវាងមន្ត្រីគាំទ្របច្ចេកទេសឈ្មោះ ជ.ជ និងអ្នកទទួលការបានបញ្ជាក់ទទួលស្គាល់ថាស្ពានគ្មានគុណភាពនៅខែមិថុនា ឆ្នាំ២០០៩។ | បណ្ដឹងនេះពាក់ព័ន្ធនឹងការបំពេញការងាររបស់មន្ត្រីថ្នាក់ក្រោមជាតិ (ចែងចំណុច ខ.១ នៃចំណុច១.២ សមត្ថកិច្ចរបស់ ក.គ.ខ) | ស៊ើបអង្កេតពេញលេញ |
| ៧. បណ្ដឹងអំពីមន្ត្រីជលផលខេត្ត ប.ប ឃុបឃិតជាមួយឈ្មួញនេសាទត្រីខុសច្បាប់ នៅបឹង ទ.ន នៅខែមករា ឆ្នាំ២០០៩។ | ពាក់ព័ន្ធការអនុវត្តតួនាទី និងភារកិច្ចរបស់មន្ត្រីរដ្ឋបាលជលផលមិនត្រឹមត្រូវ (ចែងចំណុច ខ.២ ក្នុងចំណុច ១.២ សមត្ថកិច្ចរបស់ ក.គ.ខ)។ | ស៊ើបអង្កេតមិនពេញលេញ |
| ៨. បណ្ដឹងអំពីមន្ត្រីរដ្ឋបាលព្រៃឈើខេត្ត ល.ល មិនបានហាមឃាត់ការកាប់ព្រៃឈើរបស់ឈ្មួញនៅតំបន់អភិរក្ស ទ.ទ នៅខែកុម្ភៈ ឆ្នាំ២០០៩។ | ពាក់ព័ន្ធការអនុវត្តតួនាទី និងភារកិច្ចរបស់មន្ត្រីរដ្ឋបាលព្រៃឈើមិនត្រឹមត្រូវ (ចែងចំណុច ខ.២ ក្នុងចំណុច ១.២ សមត្ថកិច្ចរបស់ក.គ.ខ)។ | ស៊ើបអង្កេតមិនពេញលេញ |
| ៩. បណ្ដឹងអំពីមន្ត្រីមន្ទីររៀបចំដែនដីអនុញ្ញាតឱ្យប្រជាពលរដ្ឋសាងសង់សំណង់ខុសច្បាប់នៅសង្កាត់ ម.ម។ | ពាក់ព័ន្ធការអនុវត្តតួនាទី និងភារកិច្ចរបស់មន្ត្រីរូបនោះ (ចែងចំណុច ខ.២ ក្នុងចំណុច ១.២ សមត្ថកិច្ចរបស់ ក.គ.ខ )។ | ស៊ើបអង្កេតមិនពេញលេញ |
| ១០. សមាជិកក្រុមប្រឹក្សាយកលុយអភិវឌ្ឍន៍ចាយផ្ទាល់ខ្លួន។ | បណ្ដឹងនេះពាក់ព័ន្ធសមត្ថកិច្ច ក.គ.ខ ប៉ុន្តែគ្មានអង្គហេតុច្បាស់លាស់។ | បិទសំណុំរឿង |
| ១១. មន្ត្រីគម្រោងដៃគូអភិវឌ្ឍន៍ឃុបឃិតគ្នាយកលុយគម្រោងចាយ។ | បណ្ដឹងនេះពាក់ព័ន្ធសមត្ថកិច្ច ក.គ.ខ ប៉ុន្តែគ្មានអង្គហេតុច្បាស់លាស់។ | បិទសំណុំរឿង |

- ក.គ.ខ ត្រូវចាត់តាំងក្រុមស៊ើបអង្កេតដែលមានសមាជិកយ៉ាងតិច០៣រូប ដើម្បីធ្វើការស៊ើបអង្កេតទៅតាមទំហំការងារ និងចំនួនបណ្តឹង។

  ក្រុមស៊ើបអង្កេតត្រូវមានប្រធានមួយរូបដើម្បីដឹកនាំការស៊ើបអង្កេត។ មន្ត្រីនៃក្រុមគាំទ្រអាចត្រូវបានតែងតាំងជាសមាជិកក្រុមស៊ើបអង្កេត។ ក.គ.ខ ត្រូវចេញសេចក្តីសម្រេចស្តីពីការចាត់តាំងក្រុមស៊ើបអង្កេត (ទម្រង់ទី៦)។ ការដាក់ចេញសេចក្តីសម្រេចចាត់តាំងស៊ើបអង្កេតមានគោលបំណងដើម្បីឱ្យអ្នកពាក់ព័ន្ធត្រូវសហការ និងផ្តល់ជូនក្រុមស៊ើបអង្កេតនូវឯកសារនានា និងផ្តល់កិច្ចសម្ភាសន៍។ សេចក្តីសម្រេចតែងតាំងត្រូវចម្លងជូនគ្រប់មន្ទីរ អង្គភាពពាក់ព័ន្ធ និងចម្លងជូនអង្គការមិនមែនរដ្ឋាភិបាលដែលជាសមាជិក ក.គ.ខ ដើម្បីផ្សព្វផ្សាយដល់អង្គការផ្សេងៗទៀត។

- ក.គ.ខ ត្រូវចាត់ចែងក្នុងការផ្តល់ព័ត៌មានត្រឡប់ដល់សាធារណជន។ ខ្លឹមសារលិខិតផ្តល់ព័ត៌មានត្រឡប់ត្រូវបង្ហាញនូវ :
  - លទ្ធផលនៃការសម្រាំងពាក្យបណ្តឹង
  - លទ្ធផលនៃការវាយតម្លៃ។

### ២.៣.៣. បន្ទាប់ពីកិច្ចប្រជុំ ក.គ.ខ

- ផ្អែកលើលទ្ធផលរបស់កិច្ចប្រជុំ ក.គ.ខ ក្រុមគាំទ្រត្រូវកែសម្រួលរបាយការណ៍វាយតម្លៃ(ទម្រង់ទី៥) ដើម្បីប្រើប្រាស់សម្រាប់រៀបចំផែនការស៊ើបអង្កេត។
- ក្រុមគាំទ្រត្រូវរៀបចំសេចក្តីសម្រេចតែងតាំងក្រុមស៊ើបអង្កេត ដោយអនុវត្តទម្រង់សេចក្តីសម្រេច (ទម្រង់ទី៦)។
- ក្រុមគាំទ្រត្រូវរៀបចំលិខិតផ្តល់ព័ត៌មានត្រឡប់ដល់សាធារណជនតាមទម្រង់ទី៧ (ការផ្តល់ព័ត៌មានត្រឡប់) ដោយភ្ជាប់ជាមួយតារាងបូកសរុបចំនួនពាក្យបណ្តឹង។ ការផ្តល់ព័ត៌មានត្រឡប់នេះ ត្រូវគោរពតាមគោលការណ៍រក្សាការសម្ងាត់ ដោយមិនត្រូវបង្ហាញអត្តសញ្ញាណនៃគ្រប់ភាគីទាំងអស់នៅក្នុងខ្លឹមសារពាក្យបណ្តឹងនីមួយៗ។

**សម្គាល់ :** កិច្ចប្រជុំ ក.គ.ខ ក្នុងការសម្រាំងពាក្យបណ្តឹង និងការវាយតម្លៃអាចធ្វើក្នុងពេលជាមួយគ្នា។

ឧទាហរណ៍ : ទម្រង់ទី៥: របាយការណ៍វាយតម្លៃពាក្យបណ្តឹង

## លទ្ធផលវាយតម្លៃពាក្យបណ្តឹង

## សម្រាប់ខែ.................. ឆ្នាំ២០........

– សរុបពាក្យបណ្តឹងទាំងអស់ ចំនួន : .០៤......ច្បាប់ (តាមរយៈប្រអប់សំបុត្រ :....០៣......ច្បាប់ ទូរស័ព្ទ :......០១....ច្បាប់ ប្រភពផ្សេងទៀត :...០០....ច្បាប់)

– ពាក្យបណ្តឹងត្រូវដោះស្រាយ ចំនួន :..០៣.....ច្បាប់

– ពាក្យបណ្តឹងមិនត្រូវដោះស្រាយ ចំនួន :...០១....ច្បាប់

| ល.រ | លេខស្រោមសំបុត្រធំ | លេខរឿងពាក្យបណ្តឹង | ការពិពណ៌នាអង្គហេតុ | ត្រូវដោះស្រាយ | អាទិភាព | ពី និត្យអង្គច្បាប់បឋម | សេចក្តីសម្រេចដោយ គ.គ.ខ |
|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| 1 | 001 | 001/001/09 | យើងខ្ញុំជាប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិ ក សូមប្តឹងតវ៉ាចំពោះអ្នកទទួលការឈ្មោះ ម.ថ ដែលបានធ្វើស្ពាននៅក្នុងឃុំពុំមានគុណភាព។ | ✓ | ខ្ពស់ | - សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ (ចំណុច ៣.១២.៦ លក្ខខណ្ឌនៃកិច្ចសន្យាក្នុងប្រការ១)<br>- ប្លង់បទដ្ឋានបច្ចេកទេស | ស៊ើបអង្កេតពេញលេញ |
| 2 | 001 | 001/002/09 | ជនពាលក្នុងភូមិបានឆក់ត្រី និងការកាប់បំផ្លាញជំរកត្រីពងអស់ ៣០ហិចតា ក្នុងបឹងស្នោ នៅក្នុងឃុំ ក.ច | ✓ | ខ្ពស់ | | ស៊ើបអង្កេតមិនពេញលេញ |
| 3 | គ្មាន | 004/09 | ស្មៀនឃុំ ខ.ព មិនគោរពវិន័យការងារដោយតែងតែមកធ្វើការយឺតជារៀងរាល់ថ្ងៃ។ | ✓ | មធ្យម | | ស៊ើបអង្កេតពេញលេញ |
| | | | | | | | |
| | | | សរុប | | | | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត :..........

លេខ :..........

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងក្រុមស៊ើបអង្កេត

## ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត..........

- យោងសេចក្តីណែនាំលេខ ០១៤ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាព ខេត្ត ក្រុង
- យោងសេចក្តីសម្រេចលេខ......... ស.ស.រ/គ.ជ.អ.ប ចុះថ្ងៃទី..... ខែ........ ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្តីពីការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹងរបស់ការងារគណនេយ្យភាព
- ..................................................................................................................................។

## <u>សម្រេច</u>

**ប្រការ ១.-**

តែងតាំងក្រុមស៊ើបអង្កេតដែលមានសមាសភាពដូចខាងក្រោម :

១. លោក.............................. ជាប្រធាន

២. លោក.............................. ជាសមាជិក

៣. លោកស្រី........................... ជាសមាជិក

**ប្រការ ២.-**

ក្រុមស៊ើបអង្កេតដែលមានសមាសភាពខាងលើ ត្រូវចុះស៊ើបអង្កេតពាក្យបណ្តឹងលេខ.............................. ដែលប្តឹងដោយ....................... លើ........................ បានកើតឡើងនៅ....................................។

**ប្រការ ៣.-**

ក្រុមស៊ើបអង្កេតមានសិទ្ធិអំណាចដូចខាងក្រោម :

- ស្នើសុំឯកសារ
- ស្រាវជ្រាវរកឯកសារនៅកន្លែងធ្វើការជនត្រូវចោទ
- សម្ភាសន៍ជាមួយដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ
- ចុះពិនិត្យកន្លែងកើតហេតុ
- ពិគ្រោះយោបល់ជាមួយអ្នកជំនាញ
- ស្នើសុំអន្តរាគមន៍ពីអភិបាលរាជធានី ខេត្ត ក្នុងករណីមានការគំរាមកំហែងដល់សុវត្ថិភាពរបស់ក្រុមស៊ើបអង្កេត។

**ប្រការ ៤.-**

មន្ទីរ និងអង្គភាពដែលពាក់ព័ន្ធត្រូវសហការជាមួយក្រុមស៊ើបអង្កេតក្នុងដំណើរការស៊ើបអង្កេត។

**ប្រការ ៥.-**

លោក លោកស្រី ដូចមានចែងក្នុងប្រការ១ និងប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃទី........... ខែ............... ឆ្នាំ...........

**ជ.ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត**..........

**ប្រធាន**

<u>*ចម្លងជូន*</u>

- គ្រប់មន្ទីរ អង្គភាព
- គណៈអភិបាលរាជធានី ខេត្ត
- គណអភិបាលក្រុង ស្រុក ខណ្ឌ
- អង្គការមិនមានរដ្ឋាភិបាល(សមាជិក ក.ត.ខ)
- មេឃុំ ចៅសង្កាត់

  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ១

  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ទម្រង់ទី៧ : ការផ្តល់ព័ត៌មានត្រឡប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត :.........

លេខ :.........                                        ថ្ងៃទី.......... ខែ.............. ឆ្នាំ..........

**ជម្រាបជូន**
**ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត**.................

**កម្មវត្ថុ :** របាយការណ៍ពាក្យបណ្តឹងដែលទទួលបានគិតត្រឹមថ្ងៃទី.......... ខែ................ ឆ្នាំ២០.....។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបមកប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជ្រាបថា កន្លងមកក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត.............. បានទទួលពាក្យបណ្តឹងមានដូចខាងក្រោម :

- សរុបពាក្យបណ្តឹងដែលបានទទួល :..................
- ពាក្យបណ្តឹងដែលត្រូវដោះស្រាយ :..................
- ពាក្យបណ្តឹងដែលបិទសំណុំរឿង :..................

ចំពោះពាក្យបណ្តឹងនីមួយៗដែលត្រូវដោះស្រាយខាងលើនេះ ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត កំណត់រយៈពេលយ៉ាងយូរ០៣ខែ ដើម្បីធ្វើការចុះស៊ើបអង្កេត និងដោះស្រាយ ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ។

សូមលោក លោកស្រីទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

សូមភ្ជាប់មកជាមួយនូវបញ្ជីពាក្យបណ្តឹងដែលទទួលបាន ។

**ជ.ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត**.........

**ប្រធាន**

## បញ្ជីពាក្យបណ្តឹងដែលទទួលបាន

| លេខរៀង<br>ពាក្យបណ្តឹង | ការប្តឹងអំពីអ្វី? | ថ្នាក់រដ្ឋបាល/<br>អង្គភាពពាក់ព័ន្ធ | ត្រូវ<br>ដោះស្រាយ | បិទ<br>សំណុំរឿង |
|---|---|---|---|---|
| 001/002/09 | អ្នកទទួលការធ្វើស្ពានពុំមានគុណភាព។ | ឃុំ ក | ✓ | |
| 002/002/09 | ស្មៀនយកលុយឃុំចាយមិនត្រឹមត្រូវ។ | ឃុំ ខ | ✓ | |
| 003/002/09 | សំណូមពរសុំសង់ស្ពានថ្មនៅឃុំ គ ។ | ឃុំ គ | | ✓ |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# ជំពូកទី៣
# ការរៀបចំផែនការស៊ើបអង្កេត

ចំណុចគន្លឹះដើម្បីដំណើរការស៊ើបអង្កេតបានល្អ គឺត្រូវរៀបចំផែនការស៊ើបអង្កេត។ ផែនការស៊ើបអង្កេតបង្ហាញនូវសកម្មភាពស៊ើបអង្កេត ដែលជួយឱ្យអ្នកស៊ើបអង្កេតដឹងជាមុន ថាត្រូវធ្វើអ្វីខ្លះ និងតាមរបៀបណាដើម្បីប្រមូលបានភស្តុតាង ព្រមទាំងបង្ហាញអំពីពេលវេលាអនុវត្តសកម្មភាពស៊ើបអង្កេត។

## ៣.១. គោលបំណង

ការរៀបចំផែនការស៊ើបអង្កេត គឺដើម្បី :

- កំណត់ភស្តុតាងដែលត្រូវស្វែងរកលើករណីនៃអង្គហេតុនីមួយៗ
- កំណត់សកម្មភាព ពេលវេលា និងធនធានដែលត្រូវប្រើប្រាស់ក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព។

## ៣.២. គោលការណ៍

គ្រប់ពាក្យបណ្តឹងដែលត្រូវដោះស្រាយ ត្រូវមានផែនការស៊ើបអង្កេតមួយ។

ក្រុមស៊ើបអង្កេតត្រូវរៀបចំផែនការស៊ើបអង្កេតរបស់ខ្លួនឱ្យបានច្បាស់លាស់ ហើយផែនការនេះត្រូវរៀបចំឱ្យបានរួចស្រេចមុនពេលដំណើរការស៊ើបអង្កេត។

ក្រុមស៊ើបអង្កេតត្រូវគ្រោងសកម្មភាព និងកំណត់រយៈពេលមិនលើសពីមួយខែឡើយសម្រាប់ការស៊ើបអង្កេតចំពោះបណ្តឹងនីមួយៗ។

ការកំណត់សកម្មភាពស៊ើបអង្កេតត្រូវពិចារណាទៅលើលក្ខណៈពាក្យបណ្តឹងស៊ើបអង្កេតពេញលេញ ឬមិនពេញលេញ។

## ៣.៣. ដំណើរការ

ការរៀបចំផែនការស៊ើបអង្កេតមានសារៈសំខាន់ ដើម្បី :

⇨ ធានាថាសកម្មភាពស៊ើបអង្កេតអាចអនុវត្តតាមលំដាប់លំដោយ និងមានលក្ខណៈត្រឹមត្រូវ

⇨ ប្រមូលព័ត៌មានគ្រប់ប្រភពសំខាន់ៗ ឱ្យបានពេញលេញ និងផ្តល់ឱកាសតិចតួចឱ្យជនសង្ស័យ ឬជនត្រូវចោទអាចបំផ្លាញចោលនូវភស្តុតាង ឬគំរាមគំហែងសាក្សី។

ក្នុងការរៀបចំផែនការស៊ើបអង្កេត ក្រុមស៊ើបអង្កេតត្រូវអនុវត្តដូចខាងក្រោម :

- ផ្អែកលើលទ្ធផលនៃការសម្រាំង និងវាយតម្លៃពាក្យបណ្តឹង ក្រុមស៊ើបអង្កេតត្រូវសិក្សាលើអង្គហេតុដែលបានវាយតម្លៃ ហើយស្វែងយល់នូវចំណុចលម្អិតនៃអង្គហេតុតាមពាក្យបណ្តឹងនីមួយៗ (ដោយមិនគ្រាន់តែចម្លងចេញពីតារាងសម្រាំងពាក្យបណ្តឹងនោះទេ)។
- ផ្អែកលើទម្រង់វាយតម្លៃ ក្រុមស៊ើបអង្កេតត្រូវពិចារណាឡើងវិញ និងសិក្សាអំពីអង្គច្បាប់ដោយត្រូវស្វែងយល់ឱ្យបានច្បាស់លាស់អំពីបទប្បញ្ញត្តិណាខ្លះនៃច្បាប់ ឬលិខិតបទដ្ឋាននានាដែលត្រូវបានបំពាន។

- កំណត់ភស្តុតាងត្រូវបង្ហាញនានា ដោយផ្អែកលើភាពពាក់ព័ន្ធគ្នារវាងអង្គហេតុ និងអង្គច្បាប់។
- ត្រូវពិចារណាកំណត់សកម្មភាពអ្វីខ្លះ សម្រាប់ស្វែងរកភស្តុតាងនៅក្នុងករណីនៃបណ្តឹងនីមួយៗ។ ឧទាហរណ៍ ជួបសម្ភាសជាមួយសាក្សីជាដើម។ ក្រុមស៊ើបអង្កេតត្រូវមានភាពច្បាស់លាស់ថាតើការប្រមូលភស្តុតាងត្រូវអនុវត្តដោយវិធីណា និងចង់បានព័ត៌មានលម្អិតកម្រិតណា។

ក្នុងការកំណត់បណ្តុំសកម្មភាពសម្រាប់ការអនុវត្តការស៊ើបអង្កេត ក្រុមស៊ើបអង្កេតត្រូវពិចារណាអំពីករណីដែលត្រូវស៊ើបអង្កេតពេញលេញ ឬមិនពេញលេញដោយផ្អែកលើសមត្ថកិច្ចរបស់ ក.គ.ឧ។

**ក. ចំពោះសមត្ថកិច្ចរបស់ ក.គ.ឧ ដែលចែងក្នុង១.២ ចំណុច"ក"** (ការប្រើប្រាស់ថវិកាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ) និង**ចំណុចខ.១** (ការអនុវត្តមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ) ករណីដែលពាក់ព័ន្ធនឹងសមត្ថកិច្ចនេះ **ត្រូវធ្វើការស៊ើបអង្កេតពេញលេញ**។

ការស៊ើបអង្កេតពេញលេញត្រូវអនុវត្តដូចខាងក្រោម :

១). ការប្រមូលព័ត៌មាន :

- ប្រមូលឯកសារ រួមមានឯកសារជាលាយលក្ខណ៍អក្សរ (ដូចជារបាយការណ៍ សៀវភៅកត់ត្រា លិខិតស្នាម បញ្ជីគណនេយ្យ និងលិខិតស្នាមផ្សេងៗ) ខ្សែអាត់សំឡេងរូបភាព។ល។
- សម្ភាសជាមួយដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ
- ចុះពិនិត្យកន្លែងកើតហេតុ
- ពិគ្រោះយោបល់របស់អ្នកជំនាញ (ឧទាហរណ៍ គណនេយ្យករនៃប្រព័ន្ធហិរញ្ញវត្ថុ ជួបមេធាវីដើម្បីពិគ្រោះយោបល់ផ្អែកច្បាប់ ឬវិស្វករបច្ចេកទេសជាដើម)។

២). ការវិភាគព័ត៌មានដែលទទួលបាន

៣). ការធ្វើរបាយការណ៍ស៊ើបអង្កេត។

**ខ. ចំពោះសមត្ថកិច្ចរបស់ ក.គ.ឧ ដែលចែងក្នុង១.២ ចំណុចខ.២** (ការបំពេញតួនាទី និងភារកិច្ចរបស់បុគ្គលិករបស់មន្ទីរ អង្គភាព អាជ្ញាធរនានា ដែលបម្រើការងារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់)។ ករណីនេះ **ត្រូវធ្វើការស៊ើបអង្កេតមិនពេញលេញ**។

សកម្មភាពស៊ើបអង្កេតមិនពេញលេញរួមមាន :

១). ការប្រមូលព័ត៌មានអាចអនុវត្តនូវសកម្មភាព

- ប្រមូលឯកសារ (របាយការណ៍ កំណត់ហេតុ ...)
- ចុះពិនិត្យកន្លែងកើតហេតុ
- សាកសួរព័ត៌មាន។

២). ធ្វើរបាយការណ៍ស៊ើបអង្កេត។

- កំណត់ពេលវេលាសម្រាប់សកម្មភាពនីមួយៗ ដែលសកម្មភាពទាំងអស់ក្នុងដំណើរការស៊ើបអង្កេតទាំងមូល មិនត្រូវមានរយៈពេលលើសពីមួយខែនោះទេ។
- ការរៀបចំផែនការស៊ើបអង្កេតត្រូវធ្វើទៅតាមទម្រង់ផែនការស៊ើបអង្កេត (ទម្រង់ទី៨)។

**កំណត់សម្គាល់ :** នៅអំឡុងពេលចុះស៊ើបអង្កេតពាក្យបណ្ដឹង ក្រុមស៊ើបអង្កេតនឹងអាចរកឃើញអង្គហេតុមួយចំនួនថ្មី ឬសាក្សីដែលគ្រោងសំភាសក៏ចាកចេញពីទីនោះ។ ដូចនេះ ក្រុមស៊ើបអង្កេតចាំបាច់ត្រូវកែសម្រួលផែនការស៊ើបអង្កេតឡើងវិញ ដើម្បីឱ្យសមស្របតាមស្ថានភាពដែលបានប្រែប្រួល។

ឧទាហរណ៍ : ទម្រង់ទី៨ : ផែនការស៊ើបអង្កេត

## ផែនការស៊ើបអង្កេត

| លេខរៀងពាក្យបណ្ដឹង : 001/006/09 | ពាក្យបណ្ដឹងអំពី : អ្នកទទួលការមិនអនុវត្តតាមគំនូសប្លង់បច្ចេកទេស |
|---|---|

| ការពិពណ៌នាអង្គហេតុ | ពិនិត្យអង្គច្បាប់ដោយ ក.គ.ខ | ភស្តុតាងត្រូវបង្ហាញ | សកម្មភាពប្រមូលភស្តុតាង | ពេលវេលា |
|---|---|---|---|---|
| ① | ② | ③ | ④ | ⑤ |
| ប្រជាពលរដ្ឋនៅភូមិ ក បានប្ដឹងអ្នកទទួលការឈ្មោះ ច សាងសង់ស្ពានមិនត្រឹមត្រូវតាមប្លង់ និងបទដ្ឋានបច្ចេកទេសខុសពីកិច្ចសន្យា។ | ១. សៀវភៅណែនាំស្ដីពីការអនុវត្ត គម្រោងមូលនិធិឃុំ សង្កាត់ (៣.១២.៦ ល័ក្ខខ័ណ្ឌនៃកិច្ចសន្យា)<br>២. កិច្ចសន្យាការងារ | ១. សៀវភៅការដ្ឋាន<br>២. របាយការណ៍រីកចម្រើនរបស់មន្ត្រីត្រួតពិនិត្យបច្ចេកទេស<br>៣. កំណត់ហេតុប្រជុំគណៈកម្មការគម្រោង និងវត្តមានអ្នកចូលរួម<br>៤. ការបំភ្លឺនានា<br>- ដើមបណ្ដឹង<br>- អ្នកទទួលផលគម្រោង<br>- មន្ត្រីបច្ចេកទេស<br>- គណៈកម្មការគ្រប់គ្រងគម្រោង<br>- អ្នកពាក់ព័ន្ធ<br>- អ្នកទទួលការ និង<br>- អ្នកជំនាញ (វិស្វករ)។<br>៥. ការពិនិត្យ និងវាស់វែងដល់ទីតាំងគម្រោង (សាកសួរព័ត៌មានបន្ថែម) និងថតរូប។ | ១. ប្រមូលភស្តុតាង :<br>១.១. ប្រមូលឯកសារ<br>– ជួបអ្នកទទួលការដើម្បីសុំសៀវភៅការដ្ឋាន<br>– ជួបមេឃុំដើម្បីសុំរបាយការណ៍រីកចម្រើនរបស់មន្ត្រីត្រួតពិនិត្យបច្ចេកទេស និងកំណត់ហេតុប្រជុំគណៈកម្មការគ្រប់គ្រងគម្រោង បញ្ជីវត្តមាន និងកិច្ចសន្យាគម្រោង<br>– ជួបមន្ត្រីត្រួតពិនិត្យបច្ចេកទេសសុំរបាយការណ៍រីកចម្រើន<br>១.២. សម្ភាសជាមួយ :<br>– ដើមបណ្ដឹងឈ្មោះ ប.ភ<br>– អ្នកទទួលផលគម្រោង<br>– មន្ត្រីបច្ចេកទេស<br>– គណៈកម្មការគ្រប់គ្រងគម្រោង<br>– អ្នកទទួលការ<br>១.៣. ពិនិត្យ និងវាស់វែងដល់ទីតាំងគម្រោង(សួរព័ត៌មាន និងថតរូប)<br>១.៤. ពិគ្រោះយោបល់ជាមួយទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ ឬមន្ត្រីត្រួតពិនិត្យបច្ចេកទេសដែលទទួលខុសត្រូវឃុំផ្សេងទៀត<br>២. វិភាគព័ត៌មាន<br>៣. សរសេររបាយការណ៍ | ២០ កក្កដា ០៩<br>២០ កក្កដា ០៩<br>២៧ កក្កដា ០៩<br>២៩ កក្កដា ០៩<br>៣ សីហា ០៩<br>៤ សីហា ០៩<br>៦-៧ សីហា ០៩ |

# ជំពូកទី៤
# ការស៊ើបអង្កេត

ការស៊ើបអង្កេតគឺជាដំណើរការស្វែងរកភស្តុតាង ដើម្បីបញ្ជាក់ការពិត ឬមិនពិតចំពោះសេចក្តីថ្លែងដែលបានចោទប្រកាន់នៅក្នុងពាក្យបណ្តឹង ។

## ៤.១. គោលបំណង

ការស៊ើបអង្កេតលើបណ្តឹងដែលត្រូវដោះស្រាយមានគោលបំណងដើម្បី :

- រកឱ្យឃើញនូវភាពពិតប្រាកដនៃអង្គហេតុតាមរយៈភស្តុតាងដើម្បីបញ្ជាក់ថាពាក្យបណ្តឹងនោះ ពិត ឬមិនពិត
- រៀបចំរបាយការណ៍ស៊ើបអង្កេតសម្រាប់កិច្ចប្រជុំ ក.គ.ខ ពិនិត្យ និងសម្រេចលើករណីដែលបានរកឃើញ ។

## ៤.២. តួនាទី និងសិទ្ធិអំណាចក្នុងការស៊ើបអង្កេត

អ្នកស៊ើបអង្កេតត្រូវសិក្សាអំពីភស្តុតាងដែលត្រូវបង្ហាញ និងស្វែងរកភស្តុតាងពាក់ព័ន្ធអង្គហេតុ ។ អ្នកស៊ើបអង្កេតត្រូវស្វែងរកព័ត៌មាន (ឯកសារ រូបភាព ខ្សែអាត់សម្លេង ការបំភ្លឺ ...) ដើម្បីកសាងភស្តុតាងដែលបញ្ជាក់អំពីភាពពិតប្រាកដនៅក្នុងពាក្យបណ្តឹង ។ មានន័យថា អ្នកស៊ើបអង្កេតត្រូវរកឱ្យឃើញថាតើនរណាជាដើមបណ្តឹង? តើនរណាជាជនត្រូវចោទ? តើគេប្តឹងអំពីអ្វី? តើព្រឹត្តការណ៍កើតឡើងពេលណា? ទីកន្លែងណា? តើមានផលប៉ះពាល់លើអ្វីខ្លះ ឬនរណាខ្លះ? តើខ្លឹមសារនៃពាក្យបណ្តឹងជាព័ត៌មាន ឬសំណូមពរផ្សេងៗ? ។

អ្នកស៊ើបអង្កេតត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួនដោយធ្វើការវិភាគ និងសន្និដ្ឋានលើអង្គហេតុ ដោយផ្អែកលើមូលដ្ឋានភស្តុតាងដែលត្រូវបង្ហាញ និងភស្តុតាងដែលបានរកឃើញ ។

អ្នកស៊ើបអង្កេតត្រូវដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការស្នើសុំឯកសារ និងស្វែងរកប្រភពភស្តុតាងដែលអាចបញ្ជាក់អង្គហេតុ ។

អ្នកស៊ើបអង្កេតត្រូវស្នើសុំភស្តុតាងពាក់ព័ន្ធទៅនឹងបញ្ហាដែលលើកឡើងនៅក្នុងពាក្យបណ្តឹងតែប៉ុណ្ណោះ ។

ការស៊ើបអង្កេតរបស់ ក.គ.ខ មិនមែនជាការស៊ើបអង្កេតបែបព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទេ ហើយអ្នកស៊ើបអង្កេតមិនមានអំណាចដូចស្ថាប័នយុត្តិធម៌ ឬជាចៅក្រមស៊ើបសួរទេ ។

ក.គ.ខ ត្រូវចាត់តាំងក្រុមស៊ើបអង្កេត និងកំណត់សិទ្ធិអំណាចធ្វើការស៊ើបអង្កេតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

សិទ្ធិអំណាចនៃការស៊ើបអង្កេតរួមមាន :

- ស្នើសុំឯកសារ (ដូចជា របាយការណ៍ សៀវភៅកត់ត្រា លិខិតស្នាម បញ្ជីគណនេយ្យ និងលិខិតស្នាមផ្សេងៗ) ខ្សែអាត់សំឡេង រូបភាព ។ល ។
- ស្រាវជ្រាវរកឯកសារនៅកន្លែងធ្វើការជនត្រូវចោទ

- សម្ភាសជាមួយដើមបណ្ដឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ
- ចុះពិនិត្យកន្លែងកើតហេតុ
- ពិគ្រោះយោបល់ជាមួយអ្នកជំនាញ (ឧទាហរណ៍ ជួបមេធាវីដើម្បីពិគ្រោះយោបល់ផ្នែកច្បាប់ ឬវិស្វករដើម្បីពិគ្រោះយោបល់អំពីបញ្ហាបច្ចេកទេស ជួបគណនេយ្យករដើម្បីពិគ្រោះយោបល់បញ្ហាហិរញ្ញវត្ថុជាដើម)
- ស្នើសុំអន្តរាគមន៍ពីអភិបាលរាជធានី ខេត្ត ក្នុងករណីមានការគំរាមគំហែងដល់សុវត្ថិភាព របស់ក្រុមស៊ើបអង្កេត ។

អ្នកស៊ើបអង្កេតមិនមានសិទ្ធិអនុវត្តនូវសកម្មភាពដូចខាងក្រោមបានឡើយ :

- ធ្វើការអង្កេតសកម្មភាពរបស់បុគ្គល (តាមដានបុគ្គលដោយបំពាក់ម៉ាស៊ីនថតដោយសម្ងាត់)
- តាមដានទូរស័ព្ទ និងពិនិត្យមើលការប្រើប្រាស់អ៊ីម៉ែល និងអ៊ីនធឺណែតនានា
- ត្រួតពិនិត្យឯកសារ (Hard Disk) ក្នុងកុំព្យូទ័រ
- អ្នកស៊ើបអង្កេតមិនអាចធ្វើការឆែកឆេរផ្ទះសម្បែងប្រជាពលរដ្ឋ ការិយាល័យ និងគណនី ធនាគារផ្ទាល់ខ្លួនរបស់មន្ត្រីរាជការបានទេ លើកលែងតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសាមីខ្លួន ។ ការឆែកឆេរគណនីផ្ទាល់ខ្លួនអាចធ្វើបានមានតែស្ថាប័នតុលាការប៉ុណ្ណោះ ។

## ៤.៣. គោលការណ៍នៃដំណើរការស៊ើបអង្កេត

### ៤.៣.១. ឯករាជ្យភាពរបស់អ្នកស៊ើបអង្កេត

ការស៊ើបអង្កេតទាំងអស់ត្រូវធ្វើឡើងដោយមិនលំអៀង និងលក្ខណៈច្បាស់លាស់ ។ អ្នកស៊ើបអង្កេតត្រូវមានភាពអព្យាក្រិត ហើយមិនមែនធ្វើការក្នុងនាមជាតំណាងរបស់ដើមបណ្ដឹង ឬជនត្រូវចោទឡើយ ។ ការស៊ើបអង្កេតមិនមែនជាការគាំទ្រភាគីដើមបណ្ដឹងនោះទេ ។ ដើមបណ្ដឹងត្រូវមានការយល់ដឹងថាមានការពិតអ្វីខ្លះ ដែលអាចរកឃើញដោយសារការស៊ើបអង្កេតនេះ ។

ផ្អែកលើគោលការណ៍នេះ មិនអនុញ្ញាតឱ្យបុគ្គលណាមួយដែលមានទំនាស់ផលប្រយោជន៍ ឬដែលគេយល់ថាអាចមានទំនាស់ផលប្រយោជន៍ចូលរួមពាក់ព័ន្ធក្នុងការស៊ើបអង្កេតបានឡើយ ។

### ៤.៣.២. ការរក្សាការសម្ងាត់

អ្នកស៊ើបអង្កេតត្រូវរក្សាការសម្ងាត់នៃរាល់ព័ត៌មានទាំងអស់ ។ ការរក្សាការសម្ងាត់គឺធ្វើយ៉ាងណាមិនឱ្យលេចចេញមកខាងក្រៅនូវព័ត៌មានស៊ើបអង្កេត អត្តសញ្ញាណរបស់ដើមបណ្ដឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ ។

ប្រសិនបើដើមបណ្ដឹង សាក្សី និងអ្នកពាក់ព័ន្ធដែលស្គាល់ឈ្មោះ បានស្នើសុំមិនបញ្ចេញឈ្មោះរបស់គាត់ និងសុំរក្សាការសម្ងាត់ អ្នកស៊ើបអង្កេតត្រូវរក្សាការសម្ងាត់ទាំងនោះ ។ ប្រសិនបើមានការបញ្ចេញអត្តសញ្ញាណផ្ទុយពីការស្នើសុំឱ្យមានការរក្សាភាពសម្ងាត់ ហេតុការណ៍នេះនឹងធ្វើឱ្យប៉ះពាល់ដល់បូរណភាពបុគ្គល ។

អ្នកស៊ើបអង្កេត ត្រូវគោរពគោលការណ៍រក្សាការសម្ងាត់ចំពោះភាគីទាំងអស់ក្នុងដំណើរការស៊ើបអង្កេត។ ចំពោះជនត្រូវចោទ ឈ្មោះរបស់គាត់ត្រូវទទួលបានការរក្សាការសម្ងាត់នៅក្នុងដំណើរការស៊ើបអង្កេត ដោយសារមានហេតុផលពីរ ៖

- **ទីមួយ ៖** ការផ្សព្វផ្សាយពីឈ្មោះរបស់ជនត្រូវចោទពីការប្រព្រឹត្តបទល្មើសអ្វីមួយ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គល។ ខណៈពេលដែលមិនទាន់មានភស្តុតាងសមស្របណាមួយ ថាជនត្រូវចោទបានប្រព្រឹត្តអ្វីមួយ បុគ្គលនោះត្រូវសន្មតថាគ្មានទោស ហើយកិត្តិយសរបស់គាត់ត្រូវបានការពារ។
- **ទីពីរ ៖** ការផ្សព្វផ្សាយឈ្មោះរបស់ជនត្រូវចោទ នឹងធ្វើឱ្យជនត្រូវចោទដឹងខ្លួនមុនថាខ្លួនគាត់ជាគោលដៅនៃការស៊ើបអង្កេតចាប់ពីដំណាក់កាលដំបូង ដែលជាហេតុនាំឱ្យការស៊ើបអង្កេតបន្ថែមទៀតមិនអាចធ្វើទៅបាន។ ជនត្រូវចោទអាចបំផ្លាញភស្តុតាង និងនិយាយជាមួយជនណាផ្សេងទៀតដូចជាសាក្សី ឬអ្នកពាក់ព័ន្ធក្នុងបំណងមិនឱ្យការស៊ើបអង្កេតរកបាននូវភស្តុតាងពិតប្រាកដ។

## ៤.៣.៣. ការការពារដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ

នៅក្នុងដំណើរការស៊ើបអង្កេត ដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទត្រូវទទួលបានការការពារឱ្យផុតពីការគំរាមកំហែង ការបំភិតបំភ័យ សងសឹក ឬការប្រើឥទ្ធិពលណាមួយឡើយ។

ចំពោះមន្ត្រីដែលកំពុងបម្រើការងារនៅក្នុងក្របខ័ណ្ឌរដ្ឋ ដែលបានដាក់ពាក្យបណ្តឹង ឬរាយការណ៍ពីភាពមិនប្រក្រតី ការងាររបស់គាត់មិនត្រូវទទួលរងផលប៉ះពាល់នោះទេ ដូចជាមិនត្រូវបានគេបញ្ឈប់ ឬផ្អាកពីការងារ ការទម្លាក់តំណែង ការកាត់ប្រាក់ខែ ឬទទួលរងការគំរាមកំហែងនៅកន្លែងធ្វើការដោយសារតែពាក្យបណ្តឹង ឬការផ្តល់ព័ត៌មាននោះឡើយ។

## ៤.៣.៤. បរិហារកេរ្តិ៍

អ្នកស៊ើបអង្កេតមិនត្រូវនិយាយអ្វីដែលអាចចាត់ទុកថា មានន័យបង្ខូចកេរ្តិ៍ឈ្មោះដល់ដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ។

អ្នកស៊ើបអង្កេតមិនអនុញ្ញាតឱ្យសម្ភាស ដោយនិយាយពាក្យសំដីជេរប្រមាថនៅក្នុងអំឡុងពេលសម្ភាសន៍ឡើយ។

ក្នុងពាក្យបណ្តឹងអាចមានខ្លឹមសារដែលជះឥទ្ធិពលអវិជ្ជមានទៅលើកេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់បុគ្គលណាម្នាក់។ ដូច្នេះក្នុងការទំនាក់ទំនង និងការសម្ភាសជាមួយភាគីពាក់ព័ន្ធ អ្នកស៊ើបអង្កេតមិនត្រូវលើកឡើងនូវខ្លឹមសារដែលអាចនឹងចាត់ទុកថាជាការបង្ខូចកេរ្តិ៍ឈ្មោះនោះឡើយ។

បញ្ញត្តិច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងយ៉ាងច្បាស់អំពីការបរិហារកេរ្តិ៍។

**មាត្រា៦៣ ៖ ការបរិហារកេរ្តិ៍ និងការជេរប្រមាថ**

១. គ្រប់ការពោលអះអាង ឬគ្រប់ការទំលាក់កំហុសដោយអសុទ្ធចិត្តនូវអំពើជាក់លាក់ណាមួយ ដែលប៉ះពាល់ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំឱ្យកើតសៅហ្មងដល់ជននោះ គឺចាត់ជាការបរិហារកេរ្តិ៍។ ការផ្សាយដោយផ្ទាល់ ឬផ្សាយបន្តនូវការពោលអះអាងនោះ ឬការទម្លាក់កំហុសនោះ ត្រូវមានទោស ទោះបីសំដៅទៅលើជនណាមួយដោយមិនចេញ ឈ្មោះជាក់លាក់ក៏ដោយ ប៉ុន្តែភិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសុន្ទរកថា តាមសម្រែក តាមការគំរាមកំហែង តាមការសរសេរ ឬតាមការបោះពុម្ព តាមផ្ទាំងបដារ ឬប័ណ្ណប្រកាស តាមការផ្សាយសោតទស្សន៍ដែលជាប់ចោទ។ គ្រប់ការពោលអះអាង ឬការទំលាក់កំហុសដែលអ្នកនិពន្ធ អ្នកសារព័ត៌មាន អ្នកទទួលខុសត្រូវខាងការផ្សាយ អ្នកទទួលខុសត្រូវខាងបោះពុម្ពផ្សាយ នាយកកម្មវិធីដែលដឹងថាមិនពិតហើយនៅតែផ្សាយបោះពុម្ពផ្សាយ សរសេរ ឬផ្សព្វផ្សាយក្នុងបំណងបំផ្លាញបុគ្គលសាធារណៈណាមួយ អំពើដែលនាំឱ្យកើតសៅហ្មងដល់ជននោះគឺជាការបរិហារកេរ្តិ៍។

២. គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ ពាក្យមើលងាយ ឬពាក្យជេរដែលគ្មានការទម្លាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ។

៣. ការបរិហារកេរ្តិ៍ ឬការជេរប្រមាថ ប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា៥៩ នឹងត្រូវផ្តន្ទាទោសដាក់គុកពី៨ថ្ងៃ ទៅ១ឆ្នាំ ហើយត្រូវពិន័យជាប្រាក់ពី ១.០០០.០០០រៀល ទៅ១០.០០០.០០០រៀល ឬត្រូវផ្តន្ទាតែទោសណាមួយនៃទោសទាំងពីរនេះក៏បាន ។

៤. ម្យ៉ាងទៀតក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាឱ្យបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួននៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានមួយ ឬច្រើន ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយរហូតដល់កម្រិតច្រើនបំផុត ១០.០០០.០០០រៀល។ បណ្តឹងអាជ្ញាដែលទាក់ទងនឹងបទបញ្ញើម ដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងតាមវិធានដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណីជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច។

៥. ក្នុងករណីណាក៏ដោយនិយោជក អ្នកបោះពុម្ព ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់ឱ្យជនរងគ្រោះម្នាក់ ឬច្រើននាក់។

## ៤.៣.៥. កិច្ចសហការរបស់ដើមបណ្តឹង សាក្សី និងជនត្រូវចោទក្នុងដំណើរការស៊ើបអង្កេត

មន្ត្រីរាជការស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល មានកាតព្វកិច្ចផ្នែកច្បាប់ក្នុងការសហការជាមួយក្រុមស៊ើបអង្កេតតាមរយៈការជួយផ្តល់ព័ត៌មាន និងការផ្តល់ឯកសារដែលអាចរកបាន និងការបំភ្លឺក្នុងនាមជាសាក្សីជាដើម។ យោងមាត្រា៣៣ និងមាត្រ៣៤នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល មន្ត្រីដែលមិនសហការ និងមិនផ្តល់ព័ត៌មាន ផ្តល់ព័ត៌មានមិនពិត ឬរក្សាទុកព័ត៌មានពាក់ព័ន្ធណាមួយ នឹងត្រូវគេចាត់ទុកថារំលោភបំពានលើកាតព្វកិច្ចផ្នែកច្បាប់របស់ពួកគេ។

ចំពោះអ្នកទទួលការដែលបានចុះកិច្ចសន្យាអនុវត្តគម្រោង ត្រូវផ្តល់កិច្ចសហការជាមួយក្រុមស៊ើបអង្កេតរបស់ ក.គ.ខ។

ដោយឡែកប្រជាពលរដ្ឋ ដែលមិនមែនជាមន្ត្រីរាជការមានសិទ្ធិចូលរួមសហការក្នុងដំណើរការស៊ើបអង្កេត ។ ប្រជាពលរដ្ឋមានសិទ្ធិបដិសេធផ្តល់កិច្ចសហការនៅក្នុងដំណើរការស៊ើបអង្កេតរបស់ ក.គ.ខ។

**ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល**

**មាត្រា ៣៣.~**

អ្នករាជការរាល់រូបត្រូវតែគោរពអនុវត្តច្បាប់ និងបទបញ្ជា ហើយនិងការណែនាំថ្នាក់លើរបស់ខ្លួន។

អ្នករាជការត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលអាចធ្វើឱ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់ខ្លួន។

អ្នករាជការនៅក្នុងក្របខ័ណ្ឌទាំងអស់ ត្រូវតែគោរពបញ្ជាថ្នាក់លើដែលបានចាត់អោយទៅបំរើការងារទោះបីទីតំបន់ណាក៏ដោយទាំងក្នុង និងក្រៅប្រទេស ។

**មាត្រា ៣៤.~**

អ្នករាជការទាំងឡាយមិនអាចឈប់ធ្វើការដោយគ្មានបានទទួលការអនុញ្ញាតជាមុនពីថ្នាក់លើរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ។ ការឈប់ធ្វើការ ឬការខានទៅធ្វើការដោយគ្មានការអនុញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវ អាចបង្ខំឱ្យអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស អ្នករាជការនោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមាន ចែងក្នុងមាត្រា៤០នៃច្បាប់នេះ។

## ៤.៤. ដំណើរការស៊ើបអង្កេត

ផ្អែកតាមផែនការស៊ើបអង្កេតដែលបានរៀបចំ ក្រុមស៊ើបអង្កេតត្រូវប្រមូលភស្តុតាងទៅតាមសកម្មភាពនីមួយៗ និងពេលវេលាដែលបានកំណត់។ សកម្មភាពស៊ើបអង្កេតរួមមាន :

- ការប្រមូលភស្តុតាង :
  - ការប្រមូលឯកសារ
  - សម្ភាសន៍ជាមួយដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ
  - ការពិនិត្យកន្លែងកើតហេតុ
  - ការពិគ្រោះយោបល់អ្នកជំនាញ។
- ការវិភាគព័ត៌មាន និងភស្តុតាង
- ការរៀបចំរបាយការណ៍ស៊ើបអង្កេត។

ភស្តុតាង គឺជាព័ត៌មានគ្រប់ប្រភេទទាំងអស់ (រួមមានឯកសារជាលាយលក្ខណ៍អក្សរ ដូចជារបាយការណ៍ សៀវភៅកត់ត្រា លិខិតស្នាម បញ្ជីគណនេយ្យ និងលិខិតស្នាមផ្សេងៗ ព្រមទាំងខ្សែអាត់សំឡេង រូបភាព ។ល។) និងអ្វីៗដែលអាចបង្ហាញពីអត្ថិភាពនៃអង្គហេតុជាក់លាក់ ហើយនឹងត្រូវប្រើប្រាស់សម្រាប់ការធ្វើសេចក្តីសម្រេចរបស់ ក.គ.ខ ។

ជារួម ភស្តុតាងមានដូចជាវត្ថុតាង រូបភាពភស្តុតាង បន្ទាល់(ការបំភ្លឺ)របស់សាក្សី ផែនទី ដ្យាក្រាម ឯកសារផ្សេងៗ ។ល។ ភស្តុតាងត្រូវមានលក្ខណៈសមហេតុសមផលដែលបង្ហាញឱ្យឃើញថាអ្វីមួយពិត ឬមិនពិតទៅតាមផ្លូវច្បាប់ ។ ជាក់ស្តែងត្រូវការនូវភស្តុតាងជាច្រើនសម្រាប់ការដោះស្រាយពាក្យបណ្តឹងនីមួយៗ ។

ក្នុងដំណើរការស៊ើបអង្កេត ក្រុមស៊ើបអង្កេតត្រូវគោរពតាមគោលការណ៍ដែលបានកំណត់ក្នុងចំនុច៤.៣ខាងលើ ។

អ្នកស៊ើបអង្កេតត្រូវកំណត់ និងស្វែងរកភស្តុតាងដែលមានលក្ខណៈគតិយុត្តិ ។ ភស្តុតាងដែលមានលក្ខណៈគតិយុត្តិ ត្រូវមានលក្ខណៈបីយ៉ាងគឺ **ភាពជាសម្ភារ ភាពជឿជាក់** និង**ភាពផ្ទៀងផ្ទាត់** ។

- **ភាពជាសម្ភារៈ (Materiality) :** មានន័យថាភស្តុតាងមានការពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬសកម្មភាពនានាក្នុងអង្គហេតុ ។ នៅក្នុងអង្គហេតុអាចមានព្រឹត្តិការណ៍ ឬសកម្មភាពមួយ ឬច្រើន ។
- **ភាពជឿជាក់ (Credibility) :** ភស្តុតាងបង្ហាញនូវអង្គហេតុនោះកើតឡើងប្រាកដ ឬមិនកើតឡើង ។ ផ្អែកលើភស្តុតាងដែលបានរកឃើញ គេអាចមានភាពជឿជាក់លើអង្គហេតុថាមានបញ្ហាពិត ឬមិនពិត ។
- **ភាពផ្ទៀងផ្ទាត់ (Verifiability) :** ភស្តុតាងដែលគ្មានប្រភពព័ត៌មានណា ឬមាននរណាម្នាក់បញ្ជាក់បដិសេធទៅនឹងភស្តុតាងនោះ ។ ភស្តុតាងត្រូវតែមានលក្ខណៈគួរឱ្យទុកចិត្ត ។

**ឧទាហរណ៍ពាក្យបណ្តឹង**

យើងខ្ញុំជាមន្ត្រីនៅអង្គភាព **ស្វាយ** ស្នើសុំឱ្យ ក.គ.ខ ពិនិត្យលើភាពមិនប្រក្រតីក្នុងការផ្គត់ផ្គង់សម្ភារៈការិយាល័យ ដោយសារឈ្មោះ ក បានឃុបឃិតជាមួយអ្នកផ្គត់ផ្គង់សម្ភារៈការិយាល័យដែលផ្តល់តុឈើគ្មានគុណភាព តាមស្តង់ដារកំណត់ចំនួន៧០ក្នុងចំណោមតុចំនួន១០០ កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ លើគម្រោងដេញថ្លៃសម្ភារៈការិយាល័យចំនួន ៧.០០០ដុល្លារ បានប្រកាសដេញថ្លៃកាលពីថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០៩ ។

ខ្ញុំបានពិនិត្យព័ត៌មាននៅលើឯកសារសេចក្តីបរិយាយលម្អិតអំពីសម្ភារៈបរិក្ខារដែលត្រូវផ្គត់ផ្គង់ និងសេចក្តីប្រកាសកាលបរិច្ឆេទដេញថ្លៃ ។ ចំនួនតុ ប្រភេទតុ និងលក្ខណៈតុ ត្រូវបានកំណត់ច្បាស់លាស់ក្នុងសេចក្តីបរិយាយលម្អិតអំពីសម្ភារៈបរិក្ខារដែលត្រូវផ្គត់ផ្គង់ ។ ឯកសារនៃការផ្គត់ផ្គង់តុចំនួន៧០ បានបង្ហាញអំពីភាពមិនឆ្លើយតបទៅនឹងតម្រូវការនៃល័ក្ខខ័ណ្ឌដេញថ្លៃ ។

ជាងនេះទៅទៀត ខ្ញុំបានសាកសួរអ្នកផ្គត់ផ្គង់ ហើយគាត់បានសារភាពថា គាត់មិនអាចរកប្រភេទសម្ភារៈតាមល័ក្ខខ័ណ្ឌតម្រូវការនោះបាន ដោយសារតម្លៃឡើងថ្លៃខុសពីតម្លៃឯកសារបានដាក់ដេញថ្លៃ ។ ការរកឃើញខាងលើបញ្ជាក់ថាករណីផ្គត់ផ្គង់សម្ភារៈនេះមានភាពមិនប្រក្រតីមែន សូមលោកប្រធាន ក.គ.ខ មេត្តាចាត់វិធានការដោះស្រាយផង ។

ការផ្ទះបញ្ចាំងភស្តុតាងដែលមានលក្ខណៈគតិយុត្តិ ៖

ភស្តុតាងក្នុងអង្គហេតុនេះរួមមាន ៖ តុចំនួន៧០ ឯកសារនៃការផ្គត់ផ្គង់តុចំនួន៧០ទាំងនោះ ។

– ភាពជាសម្ភារៈ (Materiality) ៖ ចំនួនតុ៧០ ដែលបានផ្គត់ផ្គង់ដោយឈ្មោះ ក ជាអ្នកផ្គត់ផ្គង់សម្ភារៈការិយាល័យ ដោយមានឯកសារផ្គត់ផ្គង់តុចំនួន៧០ទាំងនោះ ដែលបង្ហាញភាពមិនឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌតម្រូវការនៃផ្គត់ផ្គង់សម្ភារៈ ។
– ភាពជឿជាក់ (Credibility) ៖ លិខិតប្រគល់ទទួលតុដែលចុះកាលបរិច្ឆេទ និងហត្ថលេខា ប្រគល់ទទួល និងការផ្ទៀងផ្ទាត់រវាងល័ក្ខខ័ណ្ឌនៃការផ្គត់ផ្គង់តុ និងឯកសារបរិយាយប្រភេទ និងលក្ខណៈនៃតុចំនួន៧០នោះ ។
– ភាពផ្ទៀងផ្ទាត់ (Verifiability) ៖ សំដីសារភាពរបស់អ្នកផ្គត់ផ្គង់ចំពោះអ្នកស៊ើបអង្កេតបញ្ជាក់អំពីភាពមិនឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌតម្រូវការនៃការផ្គត់ផ្គង់ ។ សំដីសារភាពនេះបានឆ្លុះបញ្ចាំងអំពីភាពទុកចិត្តនៃការប្រគល់តុចំនួន៧០មិនត្រូវតាមប្រភេទ និងលក្ខណៈតុ ដែលត្រូវផ្គត់ផ្គង់ ។

## ៤.៤.១.ការប្រមូលភស្តុតាង

អ្នកស៊ើបអង្កេតមានតួនាទីស្វែងរកភស្តុតាងពាក់ព័ន្ធអង្គហេតុ ។ ភស្តុតាងអាចត្រូវរកបានតាមរយៈការប្រមូលឯកសារ ការសម្ភាសជាមួយដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ ការចុះពិនិត្យកន្លែងកើតហេតុ និងការផ្តល់យោបល់ពីអ្នកជំនាញ ។

### ក). ការប្រមូលឯកសារ

ការប្រមូលឯកសារ គឺការស្វែងរកឯកសារដែលរួមមានឯកសារជាលាយលក្ខណ៍អក្សរ (ដូចជារបាយការណ៍ សៀវភៅកត់ត្រា លិខិតផ្លូវការ បញ្ជីគណនេយ្យ និងលិខិតស្នាមផ្សេងៗ) ខ្សែអាត់សំឡេង រូបភាព ។ល។ ក្នុងការប្រមូលឯកសារ ក្រុមស៊ើបអង្កេតត្រូវ ៖

- ជូនដំណឹងដល់បុគ្គលដែលត្រូវស្នើសុំឯកសារ
- បង្ហាញលិខិតតែងតាំងក្រុមស៊ើបអង្កេតនៅក្នុងពេលដំណើរការប្រមូលឯកសារ
- ពន្យល់បុគ្គលដែលត្រូវស្នើសុំឯកសារ អំពីគោលបំណងនៃតម្រូវការឯកសារទាំងនោះ និងគោលការណ៍សំខាន់ពាក់ព័ន្ធដែលកំណត់នៅក្នុងចំណុច៤.៣ខាងលើ ដូចជាឯករាជ្យភាព រក្សាការសម្ងាត់ជាដើម ។

**កំណត់សម្គាល់ ៖**

– ក្រុមស៊ើបអង្កេតត្រូវស្វែងរកឯកសារភស្តុតាងដែលពាក់ព័ន្ធទៅនឹងបញ្ហា ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងតែប៉ុណ្ណោះ ។ ក្រុមស៊ើបអង្កេតអាចទាមទារឯកសារ ឬចូលស្រាវជ្រាវនៅកន្លែងធ្វើការរបស់បុគ្គលណាម្នាក់ក្នុងដំណើរការស៊ើបអង្កេត ។
– ការប្រមូលឯកសារអាចធ្វើឡើងនៅមុនពេលចុះសម្ភាសន៍ ក្នុងអំឡុងពេលសម្ភាសន៍ ឬក្រោយពេលសម្ភាសន៍ ។
– ក្រុមស៊ើបអង្កេតត្រូវរំពឹងទុកថា មានការពិតអ្វីខ្លះដែលអាចទទួលបានពីការស៊ើបអង្កេតនេះ ។

## ខ). ការសម្ភាសជាមួយដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ

### ខ.១. ដំណាក់កាលត្រៀមរៀបចំ

#### ខ.១.១. ការកំណត់បុគ្គលដែលត្រូវសម្ភាស

ក្រុមស៊ើបអង្កេតត្រូវធ្វើការជ្រើសរើសថាជនណាមួយត្រូវសម្ភាសមុនគេ និងជនណាត្រូវសម្ភាសបន្តបន្ទាប់។ ក្នុងការកំណត់ថាបុគ្គលដែលត្រូវសម្ភាស ក្រុមស៊ើបអង្កេតត្រូវពិចារណាដូចខាងក្រោម :

- ការសម្ភាសដំបូងគេត្រូវធ្វើឡើងចំពោះដើមបណ្តឹង ប្រសិនបើបណ្តឹងនោះមានឈ្មោះដើមបណ្តឹង។
- បន្ទាប់មកត្រូវធ្វើការសម្ភាសតាមលំដាប់លំដោយជាមួយភាគីពាក់ព័ន្ធ ដែលជាអ្នកដឹងព័ត៌មានគន្លឹះច្រើនជាងសាក្សី ជាពិសេសអ្នកណាដែលស្គាល់ជនត្រូវចោទ។ បន្ទាប់មកទៀតត្រូវសម្ភាសសាក្សី។ ជាចុងក្រោយក្រុមស៊ើបអង្កេតត្រូវសម្ភាសនឹងជនត្រូវចោទ។
- ការសម្ភាសអ្នកពាក់ព័ន្ធផ្សេងទៀត ដូចជាប្រជាពលរដ្ឋអាចធ្វើការសម្ភាសជាក្រុម ប៉ុន្តែត្រូវគ្រប់គ្រងការសម្ភាសឱ្យហ្មត់ចត់ ជៀសវាងមនុស្សម្នាក់មានឥទ្ធិពលលើអ្នកដទៃ។

#### ខ.១.២. ការកំណត់ពេលវេលា និងទីកន្លែងសម្រាប់ធ្វើការសម្ភាស

- ក្រុមស៊ើបអង្កេតកំណត់ពេលវេលា និងទីកន្លែងដោយប្រុងប្រយ័ត្នសម្រាប់ធ្វើការសម្ភាស ដើម្បីធានាថាក្នុងអំឡុងពេលសម្ភាសនឹងមិនមានការរំខាន ប៉ះពាល់ដល់ការរក្សាការសម្ងាត់ និងមានឱកាសគ្រប់គ្រាន់សម្រាប់អ្នកដែលត្រូវសម្ភាសអាចចូលរួមបាន។
- ការណាត់ជួបសម្ភាសជាមួយជនត្រូវចោទត្រូវធ្វើឱ្យបានឆាប់ជាការប្រសើរ ព្រោះជៀសវាងទុករយៈពេលយូរអាចឱ្យបុគ្គលរូបនោះមានឱកាសបំផ្លាញភស្តុតាង។
- ការធ្វើការសម្ភាសនៅកន្លែងកើតហេតុអាចជួយឱ្យសាក្សីចងចាំពីព្រឹត្តិការណ៍ និងបង្ហាញជាក់ស្តែងនូវអ្វីដែលបានកើតឡើង និងជួយឱ្យអ្នកស៊ើបអង្កេតបានឃើញទីកន្លែងជាក់ស្តែង និងយល់ពីដំណើររឿងដែលសាក្សីបានរៀបរាប់។

#### ខ.១.៣. ការរៀបចំបញ្ជីសំណួរ

- បញ្ជីសំណួរ ឬពាក្យពេជន៍សម្រាប់ចោទសួរ ត្រូវរៀបចំជាមុនឱ្យបានស្រេចដើម្បីធានាស្វែងរកគ្រប់ព័ត៌មានពាក់ព័ន្ធទាំងអស់។ ជាទូទៅសំណួរត្រូវរៀបចំឱ្យមាន**លក្ខណៈចំហ** ដើម្បីឱ្យបុគ្គលដែលត្រូវសម្ភាសអាចរៀបរាប់ដំណើររឿងរបស់ខ្លួនផ្ទាល់។ ក្នុងការរៀបចំបញ្ជីសំណួរជាដំបូងត្រូវរៀបចំសំណួរចំហ មិនគួរប្រើ**សំណួរបញ្ឆោត** និង**សំណួរនាំមុខ** នៅពេលសួរសំណួរដំបូងទេ។
- សម្រាប់ពាក្យបណ្តឹងនីមួយៗ ក្រុមស៊ើបអង្កេតត្រូវពិចារណារៀបចំបញ្ជីសំណួរផ្សេងៗគ្នាទៅតាមបុគ្គលដែលត្រូវជួបសម្ភាស។ តាមបទពិសោធន៍ជាក់ស្តែង ក្រុមស៊ើបអង្កេតអាចសួរសំណួរបន្ថែម ដើម្បីរកភស្តុតាងមិនបានរំពឹងទុក ឬភស្តុតាងបន្ថែមពីសាក្សីផងដែរ។

- ក្រុមស៊ើបអង្កេតត្រូវត្រៀមរៀបចំទុកជាមុននូវឧបករណ៍ ឬសម្ភារៈសម្រាប់ប្រមូលព័ត៌មាន ដោយគិតថាតើត្រូវទទួលព័ត៌មានសម្ភាសផ្ទាល់មាត់នេះដោយរបៀបណា។ ព័ត៌មានអាចត្រូវកត់ត្រា ដោយសរសេរផ្ទាល់ដៃ ឬត្រូវថតសំឡេង។

**ប្រភេទសំណួរ**

១. **សំណួរចំហ** : ជាទូទៅសំណួរចំហប្រើពាក្យសំណួរដូចជា ដូចម្តេច? ហេតុអ្វី? នរណា? កន្លែងណាមួយ? មានរឿងអ្វី?។ សំណួរទាំងនេះអាចឱ្យអ្នកត្រូវសម្ភាសឆ្លើយបំភ្លឺបញ្ហានានា និងអាចរៀបរាប់រឿងរ៉ាវផ្ទាល់របស់គេ ព្រមទាំងមិនមានការកំណត់ទិសដៅដល់អ្នកត្រូវសម្ភាស។
*ឧទាហរណ៍ : តើរឿងនេះកើតឡើងដូចម្តេច?*

២. **សំណួរបញ្ជាក់** : ជាសំណួរមិនអាចធ្វើឱ្យអ្នកត្រូវសម្ភាសធ្វើការរៀបរាប់បាន។ ដោយតម្រូវឱ្យឆ្លើយថា ពិត ឬមិនពិត ឬមែន ឬមិនមែន។ សំណួរទាំងនោះប្រើនៅពេលព័ត៌មានទាំងអស់ប្រមូលបានហើយ។ *ឧទាហរណ៍ : បន្ទាប់មកលោកឱ្យឈ្មោះ "ក" ចូលក្នុងបន្ទប់ពិតមែនទេ?* ។

៣. **សំណួរនាំមុខ** : ជាប្រភេទសំណួរដែលអ្នកសម្ភាសបានប្រាប់ព័ត៌មាន ជាមុនដល់អ្នកត្រូវសម្ភាស។
*ឧទាហរណ៍ : អ្នកបានចូលក្នុងបន្ទប់ថតឯកសារនៅពេលបាយថ្ងៃត្រង់ទេ?*

### ១.១.៤. ការជូនដំណឹង

ក្រុមស៊ើបអង្កេតត្រូវជូនដំណឹងដល់បុគ្គលដែលត្រូវសម្ភាស ដោយបញ្ជាក់ឱ្យច្បាស់លាស់អំពីពេលវេលា និងទីកន្លែងសម្រាប់ត្រូវសម្ភាស។

## ១.២. ដំណាក់កាលសម្ភាសន៍

ក្នុងពេលជួបសម្ភាស ក្រុមស៊ើបអង្កេតត្រូវដំណើរការដូចខាងក្រោម :

- នៅមុនពេលចាប់ផ្តើមធ្វើការសម្ភាស ដំបូងក្រុមស៊ើបអង្កេតត្រូវបង្ហាញសេចក្តីសម្រេចតែងតាំងក្រុមស៊ើបអង្កេត ហើយត្រូវណែនាំខ្លួន។
- បន្ទាប់មកត្រូវជម្រាបអំពីគោលបំណង និងគោលការណ៍សំខាន់ពាក់ព័ន្ធមួយចំនួន (គោលការណ៍ដែលមានកំណត់ក្នុងចំណុច៤.៣) ដើម្បីឱ្យបុគ្គលដែលត្រូវសម្ភាសមានការទុកចិត្ត និងបានដឹងអំពីសិទ្ធិរបស់គាត់។
- នៅមុនពេលចាប់ផ្តើមសួរសំណួរ ក្រុមស៊ើបអង្កេតត្រូវបែងចែកការងារដោយត្រូវមានអ្នកសួរសំណួរ និងអ្នកកត់ត្រាដើម្បីធ្វើកំណត់ហេតុ។ អ្នកកត់ត្រាត្រូវចាប់ផ្តើមកត់ត្រាភ្លាមនូវព័ត៌មាន ដូចជាម៉ោង កាលបរិច្ឆេទ ទីកន្លែងសម្ភាស និងឈ្មោះអ្នកដែលត្រូវសម្ភាស។
- នៅពេលសួរសំណួរអ្នកសម្ភាសន៍ត្រូវប្រើបញ្ជីសំណួរដើម្បីធ្វើការសម្ភាស។ ជាក់ស្តែងក្នុងពេលធ្វើសម្ភាសអាចមានការស្នើសុំពីអ្នកដែលត្រូវសម្ភាសនូវការអនុញ្ញាតនាំសមាជិកគ្រួសារ មិត្តភ័ក្រ្ត អ្នកផ្តល់ប្រឹក្សា ឬមេធាវីចូលរួមក្នុងដំណើរការសម្ភាសន៍ ក្រុមស៊ើបអង្កេតអាចអនុញ្ញាតលុះត្រាតែអ្នកមកជាមួយនោះ

ត្រូវជាមនុស្សទុកចិត្តបាន ហើយដែលធ្វើឱ្យអ្នកត្រូវគេសម្ភាសន៍មានភាពកក់ក្តៅក្នុងចិត្តព្រមទាំងធ្វើឱ្យការសម្ភាសមានដំណើរការកាន់តែងាយស្រួល។ អ្នកសម្ភាសន៍ត្រូវជម្រាបអ្នកមកជាមួយថា ពួកគាត់គ្រាន់តែជាអ្នកសង្កេតការណ៍ ហើយមិនអាចធ្វើអន្តរាគមន៍ក្នុងដំណើរការនៃការសម្ភាស ឬជួយឆ្លើយដល់អ្នកត្រូវគេសម្ភាសន៍បានឡើយ និងត្រូវគោរពការរក្សាភាព សម្ងាត់នៅក្នុងការសម្ភាសន៍។

អ្នកស៊ើបអង្កេតត្រូវគ្រប់គ្រងការសម្ភាស ដើម្បីឱ្យការសម្ភាសទទួលបានព័ត៌មានគ្រប់គ្រាន់ និងត្រូវប្រុងប្រយ័ត្នចំពោះការរក្សាការសម្ងាត់។

អ្នកកត់ត្រាត្រូវកត់ត្រាគ្រប់ចម្លើយ និងការបំភ្លឺទាំងអស់។ ចម្លើយ និងការបំភ្លឺអាចរៀបរាប់អំពីព្រឹត្តិការណ៍នានាដែលពាក់ព័ន្ធបញ្ហាទាំងឡាយដូចជា តើនរណាធ្វើអ្វីខ្លះ? ទីកន្លែងណា? មានរឿងអ្វីកើតឡើង ?

អ្នកសម្ភាសន៍អាចសួរសំណួរជាក់លាក់បន្ថែម ដើម្បីបញ្ជាក់លើសំណួរមួយចំនួនដែលមិនទាន់ត្រូវបានបញ្ជាក់ច្បាស់ដោយអ្នកត្រូវសម្ភាស ឬមិនទាន់បានសួរអំឡុងពេលសម្ភាស។ វាជាការសំខាន់ណាស់ក្នុងពេលជួបសម្ភាស អ្នកស៊ើបអង្កេតត្រូវសួរសំណួរចំៗតែម្តង។ ប្រភេទសំណួរដែលអ្នកស៊ើបអង្កេតអាចប្រើ ដូចជាសំណួរចំហ សំណួរបញ្ជាក់ និងសំណួរនាំមុខ។

**កំណត់សម្គាល់ :** ក្នុងពេលសម្ភាស អ្នកស៊ើបអង្កេត :

- មិនត្រូវបង្ខំឱ្យអ្នកត្រូវសម្ភាសប្រាប់អត្តសញ្ញាណដាក់ក្នុងកំណត់ហេតុសម្ភាសន៍ (ប្រសិនបើគាត់មិនចង់បញ្ចេញអត្តសញ្ញាណ)
- មិនត្រូវប្រឌិតហេតុការណ៍នានា ដើម្បីព្យាយាមឱ្យអ្នកត្រូវសម្ភាសឆ្លើយនូវចម្លើយដែលខ្លួនចង់បាន
- មិនត្រូវឱ្យអ្នកផ្សេងអង្គុយស្តាប់ដោយគ្មានការអនុញ្ញាតពីអ្នកត្រូវសម្ភាស ឬរំខានដល់ដំណើរការសម្ភាសន៍នោះទេ
- គួរសួរបញ្ជាក់ឡើងវិញនូវចម្លើយដែលបានផ្តល់ដោយរៀបរាប់ឡើងវិញ បន្ទាប់មកសួរសំណួរ.... (ឧទាហរណ៍ លោកបាននិយាយថា លោកបានយកលុយនោះ តើមាននរណាខ្លះចូលរួមសមគំនិតយកលុយនេះ ហើយយកទៅធ្វើអ្វី?)

## ១.៣. ដំណាក់កាលបន្ទាប់ពីសម្ភាសន៍ :

ក្រោយពីបានសួរសំណួរទាំងអស់រួចហើយ ក្រុមស៊ើបអង្កេត :

- អាចស្នើសុំ ឬស្រាវជ្រាវឯកសារដែលសង្ស័យថាមានការពាក់ព័ន្ធ និងអាចប្រើប្រាស់សម្រាប់ជាភស្តុតាង។
- ត្រូវអានកំណត់ត្រាឱ្យអ្នកត្រូវសម្ភាសបានដឹងក្នុងករណីអ្នកត្រូវសម្ភាសមិនអាចអានបាន ឬប្រគល់កំណត់ត្រាសម្ភាសន៍ឱ្យអ្នកត្រូវសម្ភាសអានខ្លួនឯងបើបុគ្គលនោះអាចអានបាន។ ប្រសិនបើអ្នកត្រូវសម្ភាសនោះស្នើសុំកែសម្រួល ហើយក្រុមស៊ើបអង្កេតបានយល់ព្រមលើសំណើនោះ អ្នកកត់ត្រាត្រូវធ្វើការកែប្រែទៅលើអត្ថបទនៃកំណត់ត្រា។

**កំណត់សម្គាល់ :**

- នៅពេលមានភស្តុតាងឯកសារ និងសាក្សីមួយចំនួនដែលប្រមូលបានសម្រាប់ការចោទប្រកាន់ជនត្រូវចោទ គួរត្រូវបានជម្រាបអំពីពាក្យបណ្តឹងដែលបានប្តឹងចោទប្រកាន់ទៅលើរូបគាត់។ ការផ្តល់ដំណឹងនេះមានហេតុផល២គឺ **ទី១ :** ជនត្រូវចោទមានសិទ្ធិដើម្បីទទួលព័ត៌មានអំពី ការចោទប្រកាន់ និងដើម្បីត្រៀមរៀបចំការពារខ្លួនផងដែរ។ **ទី២ :** ជនត្រូវចោទអាចជាប្រភពព័ត៌មានផងដែរ។
- កំណត់ត្រាដែលបានសម្ភាស ត្រូវរក្សាទុកច្បាប់ដើមនៅក្នុងឯកសារសំណុំរឿង។

- ក្រុមស៊ើបអង្កេត ត្រូវស្នើសុំអ្នកដែលត្រូវសម្ភាសផ្តិតមេដៃលើកំណត់ត្រាដើម្បីបញ្ជាក់ថាគាត់បានទទួលស្គាល់បាននិយាយដូច្នេះមែន។ កំណត់ត្រានេះនឹងត្រូវចុះហត្ថលេខាដោយអ្នកស៊ើបអង្កេត។ ប្រសិនបើអ្នកត្រូវសម្ភាសមិនឯកភាពផ្តិតមេដៃលើកំណត់ត្រានោះទេ អ្នកសម្ភាសន៍ត្រូវសួរបញ្ជាក់ និងសរសេរពីមូលហេតុទាំងនោះក្នុងកំណត់ត្រា។
- ក្នុងករណីសម្ភាសន៍ជនត្រូវចោទ បន្ទាប់ពីសម្ភាសរួចត្រូវប្រាប់អំពីសិទ្ធិស្នើសុំចូលស្តាប់របាយការណ៍ស៊ើបអង្កេត និងធ្វើការបំភ្លឺលើបណ្តឹងចោទប្រកាន់នៅក្នុងកិច្ចប្រជុំ ក.គ.ខ។ ក្នុងករណីចាំបាច់ ប្រធាន ក.គ.ខ អាចស្នើឱ្យជនត្រូវចោទធ្វើការបំភ្លឺក្នុងកិច្ចប្រជុំនេះ។

## គ). ការពិនិត្យទីកន្លែងកើតហេតុ

ក្រុមស៊ើបអង្កេតត្រូវចុះពិនិត្យកន្លែងកើតហេតុដើម្បីកសាងភស្តុតាងបន្ថែម។ ការពិនិត្យទីកន្លែងកើតហេតុអាចផ្តល់ឱ្យអ្នកស៊ើបអង្កេតយល់ឃើញរូបភាពនៃព្រឹត្តិការណ៍។ ការពិនិត្យទីកន្លែងកើតហេតុរួមជាមួយនឹងការសម្ភាសជាមួយដើមបណ្តឹង ជនត្រូវចោទ ឬសាក្សីធ្វើឱ្យអ្នកស៊ើបអង្កេតអាចប្រមូលបានពេញលេញនូវភស្តុតាង ចំពោះករណីដែលមានភាពស្មុគស្មាញ។

អ្នកស៊ើបអង្កេតគួរថតរូបទីតាំងដើម្បីជាជំនួយដល់ការស៊ើបអង្កេត ប៉ុន្តែរូបថតទាំងនោះពុំអាចប្រើសម្រាប់ធ្វើបុរេវិនិច្ឆ័យឡើយ។ ក្នុងករណីមានអំណះអំណាងបញ្ជាក់លើរូបថតដោយសាក្សីណាមួយ នោះរូបថតអាចក្លាយជាភស្តុតាងមួយសំខាន់សម្រាប់ធ្វើការវិនិច្ឆ័យ។ អ្នកស៊ើបអង្កេតអាចប្រើរូបថតដាក់បញ្ចូលនៅក្នុងរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួន។ ការពិនិត្យកន្លែងកើតហេតុអាចថតរូបភាពទីតាំង និងសាកសួរអ្នកពាក់ព័ន្ធនៅទីកន្លែងកើតហេតុ។

## ឃ). ការពិគ្រោះយោបល់ជាមួយអ្នកជំនាញ

អាស្រ័យទៅលើប្រធានបទ និងភាពស្មុគស្មាញនៃការស៊ើបអង្កេត អ្នកស៊ើបអង្កេតអាចស្នើអ្នកជំនាញដើម្បីពិគ្រោះយោបល់។ ក្នុងការពិគ្រោះយោបល់ អ្នកស៊ើបអង្កេតអាចស្នើអ្នកជំនាញ (ដូចជាវិស្វករប្រសិនបើពាក្យបណ្តឹងប្តឹងអំពីគុណភាពផ្លូវ និងប្រព័ន្ធលូជាដើម) ឱ្យផ្តល់មតិយោបល់ជាក់លាក់ទៅលើភស្តុតាង និងផ្តល់ព័ត៌មានបច្ចេកទេសទាក់ទងទៅនឹងពាក្យបណ្តឹង ព្រមទាំងផ្តល់ព័ត៌មានបន្ថែមសម្រាប់ជាជំនួយដល់ការវិភាគ។

ដំណើរការពិគ្រោះយោបល់ជាមួយអ្នកជំនាញ  អ្នកស៊ើបអង្កេតកត់ត្រានូវយោបល់ដែលទទួលបានពីអ្នកជំនាញ ដើម្បីដាក់ចូលក្នុងរបាយការណ៍ស៊ើបអង្កេត។

អ្នកស៊ើបអង្កេតអាចពិចារណាស្វែងរកអ្នកជំនាញដែលមានសមត្ថភាព និងទុកចិត្តនៅតាមស្ថាប័នរបស់រដ្ឋាភិបាល ឬឯកជន ប៉ុន្តែត្រូវប្រុងប្រយ័ត្នអំពីទំនាស់ផលប្រយោជន៍។

### ៤.៤.២. ការវិភាគព័ត៌មាន និងភស្តុតាង

ការវិភាគភស្តុតាងនៃអង្គហេតុ គឺជាការបញ្ជាក់ថាតើឯកសារ និងព័ត៌មានដែលប្រមូលបានតាមរយៈដំណើរការស៊ើបអង្កេតអាចបង្កើតជាភស្តុតាងសមហេតុផលសម្រាប់បញ្ជាក់អង្គហេតុបានដែរឬទេ?។ ការវិភាគភស្តុតាងត្រូវបូកសរុបលទ្ធផលនៃការស៊ើបអង្កេត វិភាគលទ្ធផល និងធ្វើការសន្និដ្ឋាន។

១. បន្ទាប់ពីការប្រមូលឯកសារ ការជួបសម្ភាស និងការចុះពិនិត្យដល់ទីកន្លែងរួចមក ក្រុមស៊ើបអង្កេតត្រូវធ្វើការសរុបលទ្ធផលនៃការស៊ើបអង្កេត។

២. ក្រុមស៊ើបអង្កេតត្រូវធ្វើការវិភាគឱ្យបានច្បាស់លាស់ដោយធ្វើការផ្ទៀងផ្ទាត់រវាងអង្គហេតុ និងលទ្ធផលនៃការស៊ើបអង្កេត។ នៅពេលផ្ទៀងផ្ទាត់ អ្នកស៊ើបអង្កេតត្រូវការពិនិត្យគ្រប់ព័ត៌មានទាំងអស់ដូចជា :

- តើភស្តុតាងនេះពេញលេញដែរ ឬទេ?
- តើឯកសារនោះបានបាត់បង់ផ្នែកណា ខ្លះ?
- តើជាឯកសារពិត ឬក្លែងបន្លំ ?

**ឧទាហរណ៍ :**

⇨ បុគ្គលម្នាក់បានថតចម្លងសេចក្តីព្រាងពីឯកសារផ្លូវការណាមួយ ដោយមើលទៅឯកសារនោះដូចឯកសារច្បាប់ដើមដែរ។

⇨ បុគ្គលម្នាក់បានធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីក្លែងក្លាយ។

ប្រសិនបើមានមន្ទិលសង្ស័យអំពីឯកសារក្លែងបន្លំខាងលើ អ្នកស៊ើបអង្កេតត្រូវបដិសេធឯកសារខាងលើដោយមិនអាចយកជាការបាន។

អ្នកស៊ើបអង្កេតត្រូវវិភាគព័ត៌មានអាចយកជាការបាន ដូចជាសេចក្តីថ្លែងការបំភ្លឺរបស់សាក្សីដែលបាននិយាយផ្ទាល់ថា គាត់បានឃើញជនត្រូវចោទបានប្រព្រឹត្តដូចការចោទប្រកាន់មែន។ ព័ត៌មានមិនអាចយកជាការបានដូចជាគាត់និយាយថា គាត់បានឮគេថាជនត្រូវចោទបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

៣. លទ្ធផលនៃការវិភាគភស្តុតាងត្រូវបានឆ្លុះបញ្ចាំងដូចខាងក្រោម :

- អង្គហេតុបានកើតឡើងពិតប្រាកដដោយមានភស្តុតាងគ្រប់គ្រាន់
- អង្គហេតុមិនបានកើតឡើងដោយសារមិនមានភស្តុតាងគ្រប់គ្រាន់ ឬភស្តុតាងផ្ទុយពីការចោទប្រកាន់។

៤. ក្រុមស៊ើបអង្កេតធ្វើការសន្និដ្ឋានដូចខាងក្រោម :

- បញ្ចប់ការស៊ើបអង្កេត(ភស្តុតាងគ្រប់គ្រាន់) និងផ្តល់អនុសាសន៍ដើម្បី ក.ត.ខ ប្រជុំសម្រេច។

– បន្តការស៊ើបអង្កេត (ភស្តុតាងពុំទាន់គ្រប់គ្រាន់)
– បញ្ចប់ការស៊ើបអង្កេត (មិនមានភស្តុតាងគ្រប់គ្រាន់)។

**កំណត់សម្គាល់ :** បន្ទាប់ពីលទ្ធផលការវិភាគភស្តុតាងបានបញ្ជាក់ថា ភស្តុតាងដែលប្រមូលបាននៅពុំមានភាពច្បាស់លាស់ អ្នកស៊ើបអង្កេតត្រូវពិចារណាក្នុងការប្រមូលព័ត៌មានបន្ថែម។ ការស៊ើបអង្កេតបន្ថែមនេះអាចជួយផ្តល់ភស្តុតាងថ្មីទាក់ទិនទៅនឹងអង្គហេតុក្នុងពាក្យបណ្តឹង ឬជាភស្តុតាងបន្ថែមដែលគាំទ្រ ឬអាចជំទាស់ដល់ភស្តុតាងមានស្រាប់លើសំណុំរឿងដែលបានលើកឡើងរួចហើយ។ ក្រុមស៊ើបអង្កេតអាចប្រមូលឯកសារ ឬសម្ភាស ពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងពិនិត្យទីកន្លែងកើតហេតុម្តងទៀត ប៉ុន្តែដំណើរការនេះត្រូវធ្វើឱ្យបានកាន់តែឆាប់កាន់តែប្រសើរ។

## ៤.៤.៣. ការរៀបចំរបាយការណ៍ស៊ើបអង្កេត

នៅពេលបញ្ចប់ការប្រមូលភស្តុតាង ក្រុមស៊ើបអង្កេតត្រូវធ្វើរបាយការណ៍ស៊ើបអង្កេតសម្រាប់ដាក់ជូនកិច្ចប្រជុំ ក.គ.ខ។ របាយការណ៍ស៊ើបអង្កេតត្រូវរៀបចំអាស្រ័យទៅតាមប្រភេទនៃដំណើរការស៊ើបអង្កេត (ទម្រង់ទី៩សម្រាប់ការស៊ើបអង្កេតពេញលេញ ឬទម្រង់ទី១០សម្រាប់ស៊ើបអង្កេតមិនពេញលេញ)។

របាយការណ៍ស៊ើបអង្កេតត្រូវពិពណ៌នាឱ្យបានច្បាស់អំពីភស្តុតាងទាំងឡាយដែលរកឃើញ និងប្រើប្រាស់ព័ត៌មានទាំងនេះសម្រាប់ដាក់បន្ទុក ឬដោះបន្ទុកនៃអង្គហេតុ និងធ្វើសេចក្តីសន្និដ្ឋាន ថាតើសេចក្តីថ្លែងហេតុណាមួយក្នុងពាក្យបណ្តឹងជាការពិត ឬមិនពិត។ ក្រុមស៊ើបអង្កេតមិនត្រូវបញ្ជាក់ទណ្ឌកម្មប្រភេទណាត្រូវដាក់នោះទេ។

ក្នុងការរៀបចំរបាយការណ៍ស៊ើបអង្កេត ក្រុមស៊ើបអង្កេតត្រូវរៀបចំដោយប្រុងប្រយ័ត្នដោយត្រូវសរសេរតាមការពិតនៃដំណើរការស៊ើបអង្កេត និងលទ្ធផលនៃការស៊ើបអង្កេត។ ជាពិសេសត្រូវឆ្លុះបញ្ចាំងអំពីភាពទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាងដែលប្រមូលបាន។ របាយការណ៍ស៊ើបអង្កេតដែលប្រាស់ចាកពីការពិតនៃអង្គហេតុ និងបណ្តាលឱ្យ ក.គ.ខ សម្រេចមិនបានត្រឹមត្រូវ និងមានផលប៉ះពាល់ដល់បូរណភាពបុគ្គលថែមទៀត។

**កំណត់សម្គាល់ :** បុព្វហេតុនាំឱ្យការស៊ើបអង្កេតងាយនឹងបរាជ័យដែលតម្រូវឱ្យអ្នកស៊ើបអង្កេតត្រូវជៀសវាង :

– ការស៊ើបអង្កេតធ្វើឡើងដោយពុំមានគោលបំណងច្បាស់លាស់
– អ្នកស៊ើបអង្កេតមានភាពលំអៀង និងទំនាស់ផលប្រយោជន៍
– ពឹងផ្អែកលើការសន្មតដោយគ្មានភស្តុតាង ឬមិនមានភស្តុតាងគ្រប់គ្រាន់
– ខកខានក្នុងការប្រមូលភស្តុតាងទាំងឡាយដែលមានស្រាប់
– ខកខានក្នុងការវិភាគភស្តុតាងឱ្យបានត្រឹមត្រូវ
– ពុំមានការចងក្រងឯកសារ និងការគ្រប់គ្រងលទ្ធផលនៃការស៊ើបអង្កេតឱ្យបានល្អ
– ខកខានក្នុងការគ្រប់គ្រងឥរិយាបថដែលមិនអាចទទួលយកបាន និងមិនមានហេតុផលត្រឹមត្រូវ ពីសំណាក់ភាគីមួយ ឬច្រើន
– របាយការណ៍ស៊ើបអង្កេតត្រូវបានសន្និដ្ឋានប្រាស់ចាកពីការពិត។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**របាយការណ៍ស៊ើបអង្កេត**
**ស្តីពី**

....................................................................................

**យោង** : - ស្មារតីអង្គប្រជុំរបស់ ក.គ.ខ ចុះថ្ងៃទី........ ខែ............. ឆ្នាំ......... ស្តីពីការវាយតម្លៃពាក្យបណ្តឹង
- សេចក្តីសម្រេចលេខ.......... ចុះថ្ងៃទី........ ខែ.............. ឆ្នាំ......... ស្តីពីការចាត់តាំងក្រុមស៊ើបអង្កេត។

## ១. ដំណើររឿង

ផ្អែកតាមលទ្ធផលនៃការវាយតម្លៃលើពាក្យបណ្តឹងលេខរៀង......... ស្តីពី............................................... ត្រូវបាន ក.គ.ខ សម្រេចឱ្យធ្វើការស៊ើបអង្កេត។ តាមអង្គហេតុនៃបណ្តឹងនេះមានដូចតទៅ :................................. ......................................*(ដំណើររឿងសង្ខេប)*..................................................................។

## ២. លទ្ធផលស៊ើបអង្កេត

### ២.១. ការប្រមូលឯកសារ

កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងផ្តល់ឯកសារ? អ្នកផ្តល់? ឯកសារអ្វី?

### ២.២. ការសម្ភាសជាមួយសាក្សី ដើមបណ្តឹង អ្នកពាក់ព័ន្ធ និងជនត្រូវចោទ

- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងសម្ភាសន៍? ឈ្មោះអ្នកផ្តល់ព័ត៌មាន? ជាដើមបណ្តឹង? ចម្លើយ?.
- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងសម្ភាសន៍? ឈ្មោះអ្នកផ្តល់ព័ត៌មាន? ជាសាក្សី? ចម្លើយ?
- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងសម្ភាសន៍? ឈ្មោះអ្នកផ្តល់ព័ត៌មាន? ជាអ្នកពាក់ព័ន្ធ? ចម្លើយ?
- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងសម្ភាសន៍? ឈ្មោះអ្នកផ្តល់ព័ត៌មាន? ជាជនត្រូវចោទ? ចម្លើយ?
- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងសម្ភាសន៍? ឈ្មោះអ្នកផ្តល់ព័ត៌មាន? ជាអ្នកជំនាញ? ចម្លើយ?

### ២.៣. ការពិនិត្យកន្លែងកើតហេតុ

- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងចុះពិនិត្យ? លទ្ធផលនៃការពិនិត្យ និងការសួរព័ត៌មាន?
- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងចុះពិនិត្យ? លទ្ធផលនៃការពិនិត្យ និងការសួរព័ត៌មាន?
- កាលបរិច្ឆេទ? ពេលវេលា? ទីកន្លែងចុះពិនិត្យ? លទ្ធផលនៃការពិនិត្យ និងការសួរព័ត៌មាន?

### ២.៤. ការវិភាគព័ត៌មាន និងភស្តុតាង

| ការពិណ៌នាអង្គហេតុ | សង្ខេបលទ្ធផលបានរកឃើញ | លទ្ធផលនៃការវិភាគ |
|---|---|---|
| | | |

## ៣. សេចក្តីសន្និដ្ឋាន

ក្រុមស៊ើបអង្កេតធ្វើការសន្និដ្ឋានលើភាពពិតប្រាកដនៃអង្គហេតុដោយត្រូវ :

- បញ្ចប់ការស៊ើបអង្កេត( ភស្តុតាងគ្រប់គ្រាន់) និងផ្តល់អនុសាសន៍ដើម្បី ក.គ.ខ ប្រជុំសម្រេច
- បន្តការស៊ើបអង្កេត ( ភស្តុតាងពុំទាន់គ្រប់គ្រាន់)
- បញ្ចប់ការស៊ើបអង្កេត ( មិនមានភស្តុតាងគ្រប់គ្រាន់) ។

ធ្វើនៅថ្ងៃទី........... ខែ.................... ឆ្នាំ...........

**ប្រធានក្រុមស៊ើបអង្កេត**

ឧទាហរណ៍ : ទម្រង់ទី៩ "របាយការណ៍ស៊ើបអង្កេតពេញលេញ"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍ស៊ើបអង្កេត

# ស្តីពី

# អ្នកទទួលការសាងសង់ស្ពានខុសប្លង់ និងបទដ្ឋានបច្ចេកទេស

**យោង** : - តាមស្មារតីអង្គប្រជុំរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក.ស.រ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការវាយតម្លៃពាក្យបណ្តឹង

- សេចក្តីសម្រេចលេខ ០៩ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការចាត់តាំងក្រុមស៊ើបអង្កេត ។

## ១. ដំណើររឿង

ពាក្យបណ្តឹងលេខរៀង 002/018/09 ស្តីពីការសាងសង់ស្ពានខុសប្លង់ និងបទដ្ឋានបច្ចេកទេស ត្រូវបាន ក.គ.ខ សម្រេចឱ្យធ្វើការស៊ើបអង្កេត។ តាមអង្គហេតុនៃពាក្យបណ្តឹងនេះគឺប្រជាពលរដ្ឋ២០គ្រួសារនៅភូមិ ប.ផ បានប្តឹងអ្នកទទួលការដែលបានចាក់គ្រឹះគល់ស្ពានមិនត្រូវតាមប្លង់បច្ចេកទេសក្នុងការសាងសង់ស្ពានឈើនៅឃុំ ក.ច ។

## ២. ការស៊ើបអង្កេត

### ២.១. ការប្រមូលឯកសារ

- កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង៣:០០រសៀល ក្រុមស៊ើបអង្កេតបានជួបផ្នែកគាំទ្របច្ចេកទេសនៃ គ.ប្រ ស្នើសុំឯកសារពាក់ព័ន្ធគម្រោងសង់ស្ពានឈើនៅឃុំ ក.ច។ ឯកសារដែលទទួលបានរួមមានល័ក្ខខ័ណ្ឌនៃកិច្ចសន្យា សេចក្តីលម្អិតបច្ចេកទេស គំនូសប្លង់ ផែនការអ្នកទទួលការ របាយការណ៍រីកចម្រើន និងបញ្ចប់គម្រោង។
- កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង១០:០០ព្រឹក ក្រុមស៊ើបអង្កេតបានស្នើសុំឯកសារទូទាត់បើកប្រាក់ពីលោក សុខ មេឃុំ ក.ច នៅសាលាឃុំ ព្រមទាំងថតចម្លងព័ត៌មាននៅក្នុងសៀវភៅកំណត់ហេតុការដ្ឋាន។

### ២.២. ការសម្ភាសជាមួយដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ

#### ក). ដើមបណ្តឹង

កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ នៅវេលាម៉ោង៩ព្រឹក ក្រុមស៊ើបអង្កេតបានសម្ភាសផ្ទាល់ជាមួយប្រជាពលរដ្ឋតំណាង១០គ្រួសារដែលបានដាក់ពាក្យបណ្តឹង និងមានទីលំនៅក្នុងភូមិ ប.ផ បានអះអាងថា ពួកគាត់បានពិនិត្យការសាងសង់ស្ពានដែលទទួលធ្វើដោយអ្នកទទួលការឈ្មោះ ម.ម ជារៀងរាល់ថ្ងៃ និងបានឃើញថា អ្នកទទួលការបានកែបន្លំ៣ករណី។ **ទី១** : ប្រើស៊ីម៉ងដ៏ និងខ្សាច់ចាក់គ្រឹះគល់ស្ពានតិចជាងពាក់កណ្តាល បើប្រៀបធៀបនៅក្នុងសេចក្តី

លម្អិតបច្ចេកទេស។ **ទី២ :** ជីករណ្ដៅមានទំហំទទឹងតូចជាងកន្លះម៉ែត្រ និងជម្រៅរាក់ជាងគំនូសប្លង់ពាក់កណ្ដាល។ **ទី៣ :** ប្រើដែកតូចជាងការកំណត់នៅគំនូសប្លង់។ លើសពីនេះទៀត ប្រជាពលរដ្ឋបានលើកឡើងថា ពួកគាត់បានប្រាប់ទៅអ្នកទទួលការ និងរាយការណ៍ជូនមេឃុំដែរ ប៉ុន្តែពុំទទួលបានលទ្ធផលអ្វីនោះទេ គឺអ្នកទទួលការបន្តចាក់គ្រឹះស្ពាននេះរហូតរួចរាល់។

ខ). សាក្សី

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង១១:០០ព្រឹក ក្រុមស៊ើបអង្កេតបានសាកសួរមេភូមិ ប.ផ ដែលជាសាក្សីបានចូលរួមពិនិត្យមើលហេតុការផ្ទាល់ បានបញ្ជាក់ថាពិតជាមានការកែបន្លំសម្ភារនៅពេលចាក់គ្រឹះគល់ស្ពាន ដូចប្រជាពលរដ្ឋបានលើកឡើងមែន។ រូបគាត់ក៏បានរាយការណ៍ផ្ទាល់មាត់ដល់សមាជិកគណៈកម្មការគ្រប់គ្រងគម្រោងដែរ ប៉ុន្តែពុំមានវិធានការទប់ស្កាត់ចំពោះការសាងសង់ទេ។

គ). **អ្នកពាក់ព័ន្ធ**

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង៩:០០ព្រឹក ក្រុមស៊ើបអង្កេតបានជួបប្រធាន និងសមាជិកគណៈកម្មការគ្រប់គ្រងគម្រោង។ ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងបានអះអាងថាគាត់បានទទួលព័ត៌មានពីប្រជាពលរដ្ឋ និងមេភូមិអំពីបញ្ហានេះ ប៉ុន្តែនៅថ្ងៃនោះរូបគាត់ និងសមាជិកក្រុមប្រឹក្សាមួយចំនួនទៀត កំពុងចូលរួមសិក្ខាសាលានៅសាលាខេត្ត។ មេឃុំបានបញ្ជាក់ថា នៅថ្ងៃនោះ គាត់បានទូរស័ព្ទប្រាប់ទៅអ្នកទទួលការ និងបញ្ជាឱ្យបញ្ឈប់ការងារនេះ ប៉ុន្តែអ្នកទទួលការបានលើកហេតុផលជាច្រើនទៅលើការខាតបង់ចំពោះសំណង់ស្ពាននេះ គេមិនបានចំណេញនោះឡើយ។ បន្ទាប់ពីរយៈពេល៣ថ្ងៃក្រោយមក ទើបគណៈកម្មការបានចុះពិនិត្យផ្ទាល់ ហើយឃើញថាគ្រឹះស្ពានត្រូវបានចាក់រួចរាល់ហើយដែរ។ មេឃុំបានប្រាប់ថា ចំពោះការទូទាត់អ្នកទទួលការបានដកប្រាក់ទាំង២លើករួចរាល់ហើយ ព្រោះរបាយការណ៍រីកចម្រើនពុំបានបញ្ជាក់ថា អ្នកទទួលការមិនបានអនុវត្តតាមគំនូសប្លង់ទេ។ មេឃុំក៏បានសារភាពថាគាត់មិនបានប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងនៅការដ្ឋានសាងសង់ ដើម្បីពិនិត្យលើរបាយការណ៍នោះដែរ។

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩ ម៉ោង៤:០០រសៀល ក្រុមស៊ើបអង្កេតបានជួបសម្ភាសជាមួយអ្នកត្រួតពិនិត្យបច្ចេកទេសឈ្មោះ ប.ទ នៅការិយាល័យគណៈកម្មាធិការប្រតិបត្តិ បានសារភាពថារូបគាត់ជាប់រវល់ការងារច្រើន មិនបានចុះពិនិត្យទីតាំងផ្ទាល់ក្នុងអំឡុងពេលរៀបចំរបាយការណ៍រីកចម្រើន។

ឃ). **ជនត្រូវចោទ**

កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង៣រសៀល ក្រុមស៊ើបអង្កេតជួបអ្នកទទួលការឈ្មោះ ម.ម នៅទីតាំងការដ្ឋាន បានសារភាពថាការចាក់គ្រឹះស្ពាននេះពិតជាមិនអនុវត្តតាមគំនូសប្លង់ទេ ពីព្រោះគាត់បានចំណាយច្រើនពេកនៅពេលដឹកសម្ភារៈចូលមកកាន់ទីនេះ ដោយសារផ្លូវខូចខ្លាំងធ្វើឱ្យរថយន្តជាប់ផុង និងក្រឡាប់ចាក់ស៊ីម៉ង់ដីចោល ទៅក្នុងទឹកស្រែ។

## ២.៣. ការពិនិត្យទីកន្លែងកើតហេតុ

បន្ទាប់ពីជួបគណៈកម្មការគ្រប់គ្រងគម្រោងនាពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ក្រុមស៊ើបអង្កេតបានចុះពិនិត្យទីតាំងស្ពានផ្ទាល់ព្រមទាំងបានវាស់ទំហំគ្រឹះស្ពាន និងថតរូបស្ពានបច្ចុប្បន្ន។

### ២.៤. ការពិគ្រោះយោបល់អ្នកជំនាញ

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង៤រសៀល ក្រុមស៊ើបអង្កេតបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង PSDD ដើម្បីផ្ដល់យោបល់បច្ចេកទេស។ ទីប្រឹក្សាបច្ចេកទេសបានបញ្ជាក់ថា បើសិនមានការតែបន្លំដោយប្រើស៊ីម៉ង់ដ៏មិនគ្រប់ចំនួន ជីកគ្រឹះមិនបានជ្រៅ និងទំហំគល់ស្ពានតូច ព្រមទាំងប្រើដែកតូចខុសពីបទដ្ឋានបច្ចេកទេស ដែលបានកំណត់នៅក្នុងកិច្ចសន្យាពិតមែននោះ គុណភាពស្ពាននេះនឹងមិនអាចធានាបានក្នុងការប្រើប្រាស់យូរអង្វែងទេ។ វានឹងបង្កការខូចខាតជាថ្មីនៅពេលរដូវវស្សាដែលមានទឹកហូរខ្លាំង។

### ២.៥. វិភាគព័ត៌មានដែលប្រមូលបានដើម្បីធ្វើការដាក់បន្ទុក

| ការពិពណ៌នាអង្គហេតុ | សង្ខេបលទ្ធផលបានរកឃើញ | លទ្ធផលនៃការវិភាគ |
|---|---|---|
| អ្នកទទួលការបានសាងសង់ស្ពានមិនត្រឹមត្រូវតាមប្លង់ និងបទដ្ឋានបច្ចេកទេស | - ដើមបណ្ដឹងបង្ហាញភស្តុតាងបញ្ជាក់ពីការចាក់គ្រឹះស្ពានពុំត្រឹមត្រូវតាមប្លង់។<br>- សាក្សីរួមមានមេភូមិ និងគណៈកម្មាការគ្រប់គ្រងគម្រោងបានអះអាងថាបានពិនិត្យពេលដំណើរការចាក់គ្រឹះផ្ទាល់ និងឃើញជីកគ្រឹះរាក់ពេកព្រមទាំងប្រើស៊ីម៉ង់ដ៏ស្ដើង និងដែកតូចឆ្មារ។<br>- អ្នកជំនាញ ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធបានបញ្ជាក់ថាបើមានការតែបន្លំសម្ភារៈ និងចាក់គ្រឹះមិនសមស្រប នោះគុណភាពស្ពានមិនធានាបានយូរអង្វែងទេ។<br>- ជនត្រូវចោទជាអ្នកទទួលការបានសារភាពការប្រើសម្ភារៈខុសពីគំនូសប្លង់។ | - ព័ត៌មាននិងឯកសារដែលបានផ្ដល់ឱ្យដោយសាក្សី និងអ្នកពាក់ព័ន្ធ ព្រមទាំងការផ្ដល់យោបល់របស់អ្នកជំនាញបានបញ្ជាក់ការពិតនៃអង្គហេតុ។<br>- លទ្ធផលនៃការសម្ភាសជាមួយជនត្រូវចោទបញ្ជាក់នូវការពិតនៃអង្គហេតុ។ |

## ៣. សេចក្ដីសន្និដ្ឋាន

ក្រុមស៊ើបអង្កេតយល់ឃើញថាការសាងសង់ស្ពានឈើស្ថិតក្នុងឃុំ ក.ច ដែលត្រូវបានអនុវត្តដោយអ្នកទទួលការឈ្មោះ ម.ម ពិតជាមិនត្រឹមត្រូវតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេស ដោយមានភស្តុតាងគ្រប់គ្រាន់ ដូចការចោទប្រកាន់របស់ប្រជាពលរដ្ឋប្រាកដមែន។

ធ្វើនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៩

**ប្រធានក្រុមស៊ើបអង្កេត**

ឧទាហរណ៍ ៖ ទម្រង់ទី១០ "របាយការណ៍ស៊ើបអង្កេតមិនពេញលេញ"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## របាយការណ៍ស៊ើបអង្កេត

## ស្តីពី

## ជនពាលកាប់បំផ្លាញព្រៃជម្រកត្រីពងចំនួន៣០ហិកតានៅបឹងស្នោ

**យោង** ៖ - តាមស្មារតីអង្គប្រជុំរបស់ក្រុមការងារគណនេយ្យភាពខេត្ត............ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការវាយតម្លៃពាក្យបណ្តឹង

- សេចក្តីសម្រេចលេខ ០១៦ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការចាត់តាំងក្រុមស៊ើបអង្កេត ។

### ១. ដំណើររឿង

ពាក្យបណ្តឹងលេខរៀង 034/011/09 ស្តីពីជនពាលក្នុងភូមិធ្វើការកាប់បំផ្លាញព្រៃជម្រកត្រីពងអស់៣០ហិកតា នៅបឹងស្នោ ធ្វើឱ្យប្រជាពលរដ្ឋក្នុងសហគមន៍ព្រួយបារម្ភចំពោះការបាត់បង់ធនធានធម្មជាតិ ។

### ២. ការប្រមូលព័ត៌មាន

កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ក្រុមស៊ើបអង្កេតបានជួបជាមួយប្រជាពលរដ្ឋ និងគណៈកម្មការដឹកនាំសហគមន៍សរុបចំនួន២៥រូបក្នុងភូមិ។ ប្រជាពលរដ្ឋបានអះអាងថារយៈពេល២សប្តាហ៍កន្លងមក មានជនពាលក្នុងឃុំនេះបានកាប់ព្រៃជាជម្រកត្រីពងអស់ប្រហែល៣០ហិកតា នៅបឹងស្នោ។ ប្រជាពលរដ្ឋទាំងនោះបានបង្ហាញ និងផ្តល់ឯកសាររួមមានលិខិតផ្តិតមេដៃរបស់ប្រជាពលរដ្ឋ និងកំណត់ហេតុប្រជុំរបស់គណៈកម្មការ ដឹកនាំសហគមន៍ជាមួយប្រជាពលរដ្ឋ ។

នៅព្រឹកថ្ងៃដដែល ក្រុមស៊ើបអង្កេតបានចុះពិនិត្យទីតាំងនៅក្នុងបឹង និងបានឃើញព្រៃលិចទឹកទទួលរងការកាប់ឆ្ការ និងដុតបំផ្លាញអស់ទំហំយ៉ាងធំដូចមានបង្ហាញជូននៅក្នុងរូបថត។ ប្រជាពលរដ្ឋដែលរស់នៅមាត់បឹង ក៏បានរៀបរាប់ដូចការចោទប្រកាន់ខាងលើដែរ ។

### ៣. សរុបខ្លឹមសារ

ប្រជាពលរដ្ឋមិនសប្បាយចិត្តមែនព្រោះព្រៃជាជម្រកត្រីពងប្រមាណជាង៣០ហិកតា ត្រូវទទួលរងការកាប់បំផ្លាញ ដែលទង្វើនាំឱ្យខូចខាតធនធានធម្មជាតិ និងប្រភពផ្តល់ចំណូលបម្រើជីវភាពប្រជាពលរដ្ឋក្នុងសហគមន៍ទាំងមូល ។

ធ្វើនៅថ្ងៃទី.......... ខែ............ ឆ្នាំ............

**ប្រធានក្រុមស៊ើបអង្កេត**

# ជំពូកទី៥
# ការធ្វើសេចក្តីសម្រេច

## ៥.១. គោលបំណង

ធានានូវការអនុវត្តសមត្ថកិច្ចរបស់ ក.គ.ខ ដោយធ្វើការដោះស្រាយពាក្យបណ្តឹងតាមរយៈការវិនិច្ឆ័យអង្គហេតុផ្អែកលើអង្គច្បាប់។

## ៥.២. គោលការណ៍

ការសម្រេចដាក់វិន័យ ឬទណ្ឌកម្មលើករណីណាមួយ ក.គ.ខ ត្រូវពិចារណា និងផ្អែកលើ ៖

- សមត្ថកិច្ចរបស់ ក.គ.ខ ដែលបានកំណត់ក្នុងចំណុច១.២ (សមត្ថកិច្ចរបស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត) ខាងលើនេះ
- វិធានដាក់វិន័យដែលបានអនុម័តដោយ ក.គ.ខ
- ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ព្រមទាំងកិច្ចសន្យានានា។

រាល់សេចក្តីសម្រេចដោះស្រាយពាក្យបណ្តឹងដែលបានធ្វើឡើងក្នុងកិច្ចប្រជុំ ក.គ.ខ ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

គ្មានសមាជិកណាម្នាក់មានសិទ្ធិធ្វើសេចក្តីសម្រេច ឬណែនាំផ្ទាល់ជំនួសកិច្ចប្រជុំ ក.គ.ខ បានឡើយ។

ជនត្រូវចោទអាចចូលរួមក្នុងកិច្ចប្រជុំ ក.គ.ខ ដើម្បីស្រាយបំភ្លឺការចោទប្រកាន់ ប្រសិនបើមានការស្នើសុំមុនកិច្ចប្រជុំ ដោយបុគ្គលជាជនត្រូវចោទនោះនឹងត្រូវមានការអនុញ្ញាតពីប្រធាន ក.គ.ខ ឬមានការស្នើសុំដោយសមាជិក ក.គ.ខ មួយភាគបីនៃសមាជិក ក.គ.ខ ទាំងមូល។

កិច្ចប្រជុំ ក.គ.ខ មិនអាចកែតម្រូវរបាយការណ៍ស៊ើបអង្កេតដែលបានដាក់ជូនដោយក្រុមស៊ើបអង្កេតបានទេ ប៉ុន្តែសមាជិក ក.គ.ខ អាចពិនិត្យមើលឯកសារភស្តុតាង និងស្នើឱ្យមានការបញ្ជាក់បន្ថែមពីក្រុមស៊ើបអង្កេត ដើម្បីបញ្ជាក់ឱ្យច្បាស់ និងផ្តល់ព័ត៌មានលម្អិត។

## ៥.៣. ដំណើរការ

### ៥.៣.១. កិច្ចប្រជុំរបស់ ក.គ.ខ

១. ក្រុមគាំទ្រត្រូវរៀបចំកិច្ចប្រជុំ ក.គ.ខ ដើម្បីពិនិត្យរបាយការណ៍ស៊ើបអង្កេតពាក្យបណ្តឹងដែលបានដាក់ជូន និងការធ្វើសេចក្តីសម្រេច។

២. ក្រុមស៊ើបអង្កេតត្រូវអានរបាយកាណ៍ស៊ើបអង្កេតពាក្យបណ្តឹងក្នុងកិច្ចប្រជុំរបស់ ក.គ.ខ ឱ្យបានច្បាស់ និងបង្ហាញឯកសារភស្តុតាងទាំងអស់បើចាំបាច់។

៣. កិច្ចប្រជុំ ក.គ.ខ ត្រូវពិចារណាលើអង្គហេតុសម្រាប់ពាក្យបណ្តឹងនីមួយៗ ដោយផ្អែកលើអង្គច្បាប់។ ការពិភាក្សានេះត្រូវយកចិត្តទុកដាក់ និងពិនិត្យលើលទ្ធផលរកឃើញក្នុងដំណើរការស៊ើបអង្កេត។ សេចក្តីសន្និដ្ឋានក្នុងរបាយការណ៍ស៊ើបអង្កេតជាមូលដ្ឋានសំខាន់ក្នុងការពិចារណារបស់ ក.គ.ខ។ ក្នុងករណីមិនច្បាស់លាស់ ក.គ.ខ អាចអញ្ជើញអ្នកជំនាញ ឬអ្នកច្បាប់ចូលរួមបំភ្លឺថែមទៀត។

ក្នុងកិច្ចប្រជុំ ក.គ.ខ ជនត្រូវចោទអាចចូលមកស្តាប់របាយការណ៍ស៊ើបអង្កេត ឬធ្វើការបំភ្លឺដោយជនត្រូវចោទមិនត្រូវបង្កបញ្ហា ដែលជាការរំខានដល់កិច្ចប្រជុំនេះឡើយ។ ប្រធាន ក.គ.ខ ត្រូវគ្រប់គ្រងកិច្ចប្រជុំនេះឱ្យមានសណ្តាប់ធ្នាប់។

៤. ប្រធានអង្គប្រជុំ ក.គ.ខ ត្រូវអញ្ជើញជនត្រូវចោទឱ្យចាកចេញពីកិច្ចប្រជុំ មុននឹងធ្វើការវិនិច្ឆ័យលើសំណុំរឿង។ បន្ទាប់មក កិច្ចប្រជុំ ក.គ.ខ ត្រូវធ្វើការពិភាក្សាទៅលើរបាយការណ៍ស៊ើបអង្កេតដោយ :
   - ពិចារណាផ្អែកទៅលើការសំអាងរបស់ជនត្រូវចោទ ហើយបញ្ជាក់ភាពអាចជឿជាក់បាននៃរបាយការណ៍ស៊ើបអង្កេត
   - ត្រូវធ្វើការថ្លឹងថ្លែងទៅលើភាពដែលអាចជឿជាក់បាននៅក្នុងរបាយការណ៍ស៊ើបអង្កេត។

៥. បន្ទាប់ពីពិចារណាអង្គហេតុច្បាស់លាស់ហើយ កិច្ចប្រជុំ ក.គ.ខ ត្រូវធ្វើការឆ្លុះបញ្ចាំងអំពីអង្គច្បាប់។ ផ្អែកទៅលើភស្តុតាងនៃអង្គហេតុ ក.គ.ខ ត្រូវពិនិត្យ និងសម្រេចថាតើអង្គហេតុបានបំពានទៅលើបទប្បញ្ញត្តិណាខ្លះនៃច្បាប់ ឬលិខិតបទដ្ឋានពាក់ព័ន្ធ។

ទទ្ទឹមនេះ កិច្ចប្រជុំ ក.គ.ខ ត្រូវពិចារណាលើស្ថានភាពនៃការប្រព្រឹត្តិ និងភាពសមហេតុផលសម្រាប់ការពិចារណាការដាក់ទណ្ឌកម្ម។ ក.គ.ខ គួរធ្វើការពិចារណាទៅលើស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសនៅពេលសេចក្តីសម្រេចដាក់ទណ្ឌកម្មលើបុគ្គលណាមួយដែលរកឃើញថាមានកំហុស។ ក.គ.ខ អាច និងដាក់ទណ្ឌកម្មធ្ងន់ ឬស្រាល អាស្រ័យទៅតាមកាលៈទេសៈនៃសំណុំរឿង និងស្ថានភាពបុគ្គលជាជនត្រូវចោទ។

ចំណុចមួយចំនួនសម្រាប់ការពិចារណាស្ថានទម្ងន់ទោស និងស្ថានសម្រាលទោសរួមមានដូចខាងក្រោម :

**ក). ស្ថានទម្ងន់ទោស**

- ជនត្រូវចោទប្រព្រឹត្តដោយចេតនាខុសពីតួនាទីរបស់ខ្លួន ឬកាតព្វកិច្ចជាមន្ត្រីរាជការ ជាសមាជិកក្រុមប្រឹក្សា ជាអ្នកទទួលការ ឬមុខងារផ្សេងទៀត
- ជនត្រូវចោទទទួលផលប្រយោជន៍ផ្ទាល់ខ្លួន
- ជនត្រូវចោទបានធ្វើឱ្យខូចខាត(ហិរញ្ញវត្ថុ ឬកិត្តិយស)ដល់ផលប្រយោជន៍បុគ្គលណាម្នាក់ ឬច្រើននាក់ ឬស្ថាប័នសាធារណៈ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់)
- ការប្រព្រឹត្តកំហុសឆ្លងច្រើនលើក

- ជនត្រូវចោទមិនរាងចាល
- ជនត្រូវចោទបានគំរាម ឬសងសឹកដើមបណ្តឹង ឬសាក្សី
- ជនត្រូវចោទបដិសេធមិនសហការក្នុងការស៊ើបអង្កេត ។

ខ). ស្ថានសម្រាលទោស

- មិនមានប្រព្រឹត្តធ្ងន់ធ្ងរដូចក្នុងស្ថានទម្ងន់ទោសខាងលើ
- ស្ថានភាពស្មារតីមិនសូវល្អជនត្រូវចោទផ្នែកផ្លូវចិត្ត និងអារម្មណ៍
- ជនត្រូវចោទមិនទាន់មានបទពិសោធន៍ក្នុងការងារ (ទើបចូលបម្រើការងារ)
- ជនត្រូវចោទបានបម្រើការងារយូរឆ្នាំ និងមានប្រវត្តិការងារល្អ ។

កិច្ចប្រជុំ ក.គ.ខ មិនត្រូវប្រញាប់ប្រញាល់ក្នុងការសម្រេចចិត្ត ។ ក.គ.ខ គួរទុកពេលសម្រាប់ការពិចារណាឱ្យបានសមស្រប ។

៦. ក.គ.ខ អាចធ្វើការសម្រេច ដូចខាងក្រោម :

- **បិទសំណុំរឿង ឬបន្តការស៊ើបអង្កេត :** ក្នុងករណីដែលអង្គប្រជុំ ក.គ.ខ ពិនិត្យឃើញថាភស្តុតាងនៃអង្គហេតុមិនអាចជឿជាក់បាន ឬអង្គហេតុមិនមានភស្តុតាងគ្រប់គ្រាន់ ។
- **ដាក់ទណ្ឌកម្ម :** ក្នុងករណីដែលអង្គប្រជុំ ក.គ.ខ ពិនិត្យឃើញថាភស្តុតាងនៃអង្គហេតុមានភាពជឿជាក់ និងមានភស្តុតាងគ្រប់គ្រាន់ ។ ការដាក់វិន័យ ឬទណ្ឌកម្មនេះត្រូវផ្អែកលើវិធានការដាក់វិន័យ ឬទណ្ឌកម្មដែលអនុម័តដោយ ក.គ.ខ សាមី ។
- **បញ្ជូនសំណុំរឿងទៅអង្គភាព ឬស្ថាប័នពាក់ព័ន្ធ :** ក្នុងករណីដែលអង្គប្រជុំ ក.គ.ខ ពិនិត្យឃើញថាអង្គហេតុមានព័ត៌មានបញ្ជាក់សមស្រប (សម្រាប់របាយការណ៍ស៊ើបអង្កេតមិនពេញលេញ) ។

៧. អង្គប្រជុំត្រូវចាត់តាំងសមាជិកណាមួយរបស់ ក.គ.ខ ឱ្យតាមដានការអនុវត្តសេចក្តីសម្រេចនោះ ។ ក្រុមគាំទ្រនៃ ក.គ.ខ ត្រូវជួយសមាជិក ក.គ.ខ រូបនោះក្នុងការតាមដានរបស់មន្ទីរ ឬអង្គភាព ។

**កំណត់សម្គាល់ :**

- ក្នុងកិច្ចប្រជុំ ក.គ.ខ អាចមានការលើកឡើងនូវបញ្ហាផ្សេងៗទៀត ប្រធាន ក.គ.ខ ត្រូវគ្រប់គ្រងស្ថានការណ៍ក្នុងកិច្ចប្រជុំពិភាក្សា ដើម្បីឱ្យកិច្ចប្រជុំដំណើរការប្រកបដោយសណ្តាប់ធ្នាប់
- កិច្ចប្រជុំ ក.គ.ខ ត្រូវមានកំណត់ហេតុដោយត្រូវកត់ត្រាឱ្យបានត្រឹមត្រូវអំពីដំណើរការការប្រជុំនេះ ។

### ៥.៣.២. បន្ទាប់ពីកិច្ចប្រជុំរបស់ ក.គ.ខ

១. ផ្អែកលើសេចក្ដីសម្រេចនៃកិច្ចប្រជុំ ក.គ.ខ ក្រុមគាំទ្រត្រូវរៀបចំនូវសេចក្ដីព្រាងសេចក្ដីសម្រេចដោះស្រាយពាក្យបណ្ដឹង ដើម្បីដាក់ជូនប្រធាន ក.គ.ខ ពិនិត្យ និងចុះហត្ថលេខា។

២. សេចក្ដីសម្រេចដោះស្រាយពាក្យបណ្ដឹងដោយដាក់បញ្ចូលនូវ ៖

- ការបរិយាយសង្ខេបអង្គហេតុ
- សម្រេចចោទប្រកាន់លើបុគ្គលដែលបានប្រព្រឹត្ត ផ្អែកលើច្បាប់ ឬលិខិតបទដ្ឋានពាក់ព័ន្ធ
- ការដាក់ទណ្ឌកម្មដោយយោងលើវិធានការដាក់វិន័យ ឬទណ្ឌកម្ម (ករណីពាក្យបណ្ដឹងស៊ើបអង្កេតពេញលេញ)
- ការបញ្ជូនពាក្យបណ្ដឹងនេះទៅស្ថាប័នពាក់ព័ន្ធត្រូវដោះស្រាយតាមនីតិវិធី។

៣. ប្រសិនបើ ក.គ.ខ សម្រេចដាក់ទណ្ឌកម្មលើករណីណាមួយ ក.គ.ខ ត្រូវផ្ញើសេចក្ដីសម្រេចនោះក្នុងរយៈពេល ០៥ថ្ងៃទៅមន្ទីរ ឬអង្គភាពដែលមានសមត្ថកិច្ចលើជនត្រូវចោទឱ្យអនុវត្តទណ្ឌកម្ម។

ទម្រង់ទី១១ : សេចក្តីសម្រេចដាក់ទណ្ឌកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត:..........

លេខ :..........

# សេចក្តីសម្រេច

## ស្តីពី

## ការដោះស្រាយពាក្យបណ្តឹងលេខ...................

## ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត..........................

– យោងសេចក្តីណែនាំលេខ ០១៤ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង
– យោងសេចក្តីសម្រេចលេខ......... ចុះថ្ងៃទី........ ខែ............ ឆ្នាំ......... ស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត..................
– យោងសេចក្តីសម្រេចលេខ.........ស.ស.រ/គ.អ.ជ.ប ចុះថ្ងៃទី.......... ខែ............. ឆ្នាំ.......... របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹងរបស់ក្រុមការងារគណនេយ្យភាព
– យោងស្មារតីអង្គប្រជុំធ្វើនៅថ្ងៃទី........... ខែ................. ឆ្នាំ........... របស់ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត........*(ឈ្មោះរាជធានី ខេត្ត)*........

## ស ម្រេ ច

**ប្រការ ១.–**

.......................................................................................................................................................
..........................................................................................................................។

**ប្រការ ២.–**

.......................................................................................................................................................
..........................................................................................................................។

**ប្រការ ៣.–**

.................................................................ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃទី.......... ខែ................. ឆ្នាំ..............

**ជ.ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត**................

**ប្រធាន**

*ចម្លងជូន*

- ក្រុមការងារគណនេយ្យភាពជាតិ
- ដូចប្រការ......
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ឧទាហរណ៍ : ទម្រង់ទី១១: សេចក្តីសម្រេចដាក់ទណ្ឌកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត : ក.ស.រ

លេខ : ០២ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការដោះស្រាយពាក្យបណ្តឹងលេខ 002/018/09

## ក្រុមការងារគណនេយ្យភាពខេត្ត ក.ស.រ

- យោងសេចក្តីណែនាំលេខ ០១៤ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្តីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង
- យោងសេចក្តីសម្រេចលេខ ០៦ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក.ស.រ
- យោងសេចក្តីសម្រេចលេខ........ ស.ស.រ/គ.អ.ជ.ប ចុះថ្ងៃទី......... ខែ.......... ឆ្នាំ........ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្តីពីការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹងរបស់ក្រុមការងារគណនេយ្យភាព
- យោងស្មារតីអង្គប្រជុំធ្វើនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ របស់ក្រុមការងារគណនេយ្យភាពខេត្ត ក.ស.រ ។

## ស ម្រេ ច

**ប្រការ ១.–**

បណ្តឹងលេខ 002/018/09 ដែលប្តឹងដោយប្រជាពលរដ្ឋចំនួន២០គ្រួសារលើអ្នកទទួលការឈ្មោះ ម.ម អំពីការសាងសង់ស្ពានឈើខុសប្លង់ និងបទដ្ឋានបច្ចេកទេសដែលបានកើតឡើងនៅភូមិ ប.ផ ក្នុងឃុំ ក.ច ស្រុក ក.ទ ខេត្ត ក.ស.រ បានបំពានលើបទបញ្ញត្តិនៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

**ប្រការ ២.–**

មន្ទីរ និងអង្គភាពសាមីត្រូវអនុវត្តវិធានការដាក់វិន័យចំពោះជនត្រូវចោទករណីខាងលើដូចខាងក្រោម :

ក). គណៈកម្មាធិការប្រតិបត្តិត្រូវលុបឈ្មោះអ្នកទទួលការឈ្មោះ ម.ម ចេញពីបញ្ជីឈ្មោះអ្នកទទួលការរបស់ខេត្ត **ក.ស.រ** ដោយសារតែអ្នកទទួលការរូបនេះមិនបានអនុវត្តតាមគំនូសប្លង់ និងកិច្ចសន្យាក្នុងការសាងសង់ស្ពានឈើនៅក្នុងឃុំ ក.ច។ អ្នកទទួលការឈ្មោះ ម.ម មិនត្រូវបានអនុញ្ញាតឱ្យចូលដេញថ្លៃគ្រប់គម្រោងទាំងអស់ដែលប្រើថវិកាស្ថិតនៅក្រោមផែនការ និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត។

ខ). គណៈកម្មាធិការប្រតិបត្តិត្រូវបញ្ចប់កិច្ចសន្យាមន្ត្រីត្រួតពិនិត្យបច្ចេកទេសឈ្មោះ ប.ទ របស់ខ្លួន ដែលបានរៀបចំរបាយការណ៍រីកចម្រើន និងរបាយការណ៍បញ្ចប់គម្រោង ដោយមិនបានចុះពិនិត្យទីតាំងជាក់ស្តែង។

គ). អភិបាលខេត្តត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរចំពោះមេឃុំ ក.ច ដែលមិនបានប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងដើម្បីពិនិត្យ និងយល់ព្រមលើរបាយការណ៍រីកចម្រើន ដែលមន្ត្រីត្រួតពិនិត្យបច្ចេកទេសបានដាក់ជូន។

**ប្រការ ៣.-**

គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍជនបទខេត្ត សាលាខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងរយៈពេល១៥ថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេចក្តីសម្រេចនេះ។

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៩

**ជ.ក្រុមការងារគណនេយ្យភាពខេត្ត** ក.ស.រ

**ប្រធាន**

***ចម្លងជូន***

- ក្រុមការងារគណនេយ្យភាពជាតិ
- ដូចប្រការ១

  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ជំពូកទី ៦
# ការអនុវត្តសេចក្ដីសម្រេច និងតាមដាន

## ៦.១. គោលបំណង

ការអនុវត្ត និងតាមដានសេចក្ដីសម្រេចដាក់វិន័យ ឬទណ្ឌកម្មមានគោលបំណងដើម្បី :

- ធានាថាមន្ទីរ ឬអង្គភាពសាមី ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ដាក់វិន័យ ឬទណ្ឌកម្មចំពោះជនត្រូវចោទដែលបានរកឃើញថាបានប្រព្រឹត្ត ឬពាក់ព័ន្ធនឹងភាពមិនប្រក្រតី
- ជំរុញការអនុវត្តវិធានការដាក់វិន័យ ឬទណ្ឌកម្ម ដែលត្រូវអនុវត្តដោយមន្ទីរ ឬអង្គភាព ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធឱ្យមានប្រសិទ្ធភាពខ្ពស់។

## ៦.២. គោលការណ៍

ក.គ.ខ មិនមែនជាស្ថាប័នដែលត្រូវអនុវត្តការដាក់ទណ្ឌកម្មទេ។ មន្ទីរ ឬអង្គភាពសាមីដែលពាក់ពន្ធ័ត្រូវអនុវត្តសេចក្ដីសម្រេចដែល ក.គ.ខ បានដាក់ចេញ។

មន្ទីរ ឬអង្គភាពសាមី និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធត្រូវអនុវត្តវិធានការដាក់វិន័យដោយខ្លួនឯង ឬចាត់វិធានការដោះស្រាយទៅតាមនីតិវិធី និងគោលការណ៍នានានៅអំឡុងពេល**១៥ថ្ងៃធ្វើការ** បន្ទាប់ពី ក.គ.ខ បានផ្ញើសេចក្ដីសម្រេចទៅមន្ទីរ ឬអង្គភាព និងអង្គការនោះ។

ក.គ.ខ ធ្វើសេចក្ដីសម្រេចដាក់វិន័យ ឬទណ្ឌកម្មចំពោះមន្ត្រីណាមួយ ត្រូវផ្អែកលើវិធានការដាក់វិន័យ ឬទណ្ឌកម្មរបស់ ក.គ.ខ សាមី ដែលបានប្រជុំអនុម័ត។

វិធានការដាក់វិន័យ ឬទណ្ឌកម្មរបស់ ក.គ.ខ សាមីត្រូវស្របទៅនឹងគំរូវិធានការដាក់វិន័យ ឬទណ្ឌកម្ម ដែលបានចែងនៅក្នុងសេចក្ដីណែនាំលេខ ០១៤ ស.ណ.ន/គ.ជ.វ.វ ស្ដីពីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។

ការតាមដានលើការអនុវត្តសេចក្ដីសម្រេចរបស់ ក.គ.ខ ត្រូវធ្វើជាប្រចាំ បន្ទាប់ពីសេចក្ដីសម្រេចរបស់ ក.គ.ខ បានផ្ញើជូនមន្ទីរ ឬអង្គភាពសាមីនោះ។

## ៦.៣. ដំណើរការ

- ក្នុងរយៈពេលយ៉ាងយូរ**៥ថ្ងៃធ្វើការ**បន្ទាប់ពិកិច្ចប្រជុំ ក.គ.ខ ក្រុមគាំទ្រនៃ ក.គ.ខ ត្រូវផ្ញើរសេចក្ដីសម្រេចរបស់ ក.គ.ខ ស្នើសុំដាក់វិន័យ ឬទណ្ឌកម្មចំពោះមន្ត្រីទៅឱ្យមន្ទីរ ឬអង្គភាព ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។
- មន្ទីរ ឬអង្គភាព ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ អនុវត្តសេចក្ដីសម្រេចដាក់ទណ្ឌកម្មរបស់ ក.គ.ខ។ ការអនុវត្តសេចក្ដីសម្រេចនោះមាន២ករណី។ **ករណីទី១ :** ការអនុវត្តទណ្ឌកម្មដែល ក.គ.ខ បានកំណត់

វិធានការដាក់វិន័យ ឬទណ្ឌកម្ម។ **ករណីទី២ :** មន្ទីរ ឬអង្គភាព ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ អាចចាត់វិធានការបន្ថែមតាមនីតិវិធីពាក់ព័ន្ធទៅនឹងការប្រព្រឹត្តរបស់មន្ត្រីរូបនោះ។

- សមាជិក ក.គ.ខ ដែលបានចាត់តាំងដោយកិច្ចប្រជុំ ក.គ.ខ ត្រូវទទួលខុសត្រូវក្នុងការតាមដានការអនុវត្ត សេចក្តីសម្រេចរបស់មន្ទីរ ឬអង្គភាពសាមី ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។ ក្រុមគាំទ្រនៃ ក.គ.ខ ត្រូវជួយដល់សមាជិក ក.គ.ខ ដែលបានចាត់តាំងក្នុងការតាមដានការអនុវត្តសេចក្តីសម្រេចរបស់ ក.គ.ខ។ ក្រុមគាំទ្រត្រូវរៀបចំតារាងសម្រាប់ធ្វើការតាមដានការអនុវត្តសេចក្តីសម្រេច ដោយប្រើប្រាស់ទម្រង់ទី១២ (តារាងតាមដានការអនុវត្តសេចក្តីសម្រេច)។
- ក្រុមគាំទ្រត្រូវប្រមូលរបាយការណ៍ពីសមាជិក ដែលបានចាត់តាំងឱ្យតាមដានលើការអនុវត្តវិធានការ ដាក់វិន័យ និងត្រូវរាយការណ៍ជាទៀតទាត់អំពីលទ្ធផលនៃអនុវត្តសេចក្តីសម្រេចរបស់មន្ទីរ ឬអង្គភាព ឬអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធតាមរយៈកិច្ចប្រជុំ ក.គ.ខ។
- ក.គ.ខ ពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដានខាងលើ ព្រមទាំងចាត់វិធានការក្នុងករណីចាំបាច់។ វិធានការបន្ថែមទាំងនោះមានដូចជា :
  - អញ្ជើញប្រធានមន្ទីរ ឬអង្គភាពមកស្រាយបំភ្លឺអំពីការខកខានមិនបានអនុវត្តសេចក្តីសម្រេច
  - ធ្វើរបាយការណ៍បញ្ជូនទៅ ក.គ.ជ ក្នុងករណីចាំបាច់។

ទម្រង់ទី១២ : តារាងតាមដានការអនុវត្តសេចក្តីសម្រេច

## តារាងតាមដានការអនុវត្តសេចក្តីសម្រេច

| ល.រ | លេខរៀងបណ្តឹង | សេចក្តីសម្រេចរបស់ ក.គ.ខ | កាលបរិច្ឆេទបញ្ជូន | ឈ្មោះមន្ទីរ/អង្គភាព | អនុវត្ត (បាទ/ទេ ) | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# ជំពូកទី៧
# ការផ្តល់ព័ត៌មានត្រឡប់

## ៧.១. គោលបំណង

ការផ្តល់ព័តិមានត្រឡប់មានគោលបំណងដើម្បី ៖

- ធានាថាប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធបានដឹងពីលទ្ធផលនៃការដំណោះស្រាយពាក្យបណ្តឹង
- បង្កើនជំនឿទុកចិត្ត និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការដោះស្រាយពាក្យបណ្តឹង ។

## ៧.២. គោលការណ៍

ក.គ.ខ ត្រូវផ្តល់ព័តិមានត្រឡប់អំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងរាជធានី ខេត្ត ។

ការផ្តល់ព័តិមានត្រឡប់អំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹង ត្រូវគោរពតាមគោលការណ៍រក្សាការសម្ងាត់ដោយមិនត្រូវបង្ហាញអត្តសញ្ញាណនៃគ្រប់ភាគីទាំងអស់នៅក្នុងដំណើរការដោះស្រាយពាក្យបណ្តឹង ។

## ៧.៣. ដំណើរការ

- ក្រុមគាំទ្រត្រូវរៀបចំលិខិតផ្សព្វផ្សាយដល់សាធារណជន ដោយប្រើប្រាស់ទម្រង់ផ្តល់ព័តិមានត្រឡប់ (ទម្រង់ទី១៣) ។
- ក្រុមគាំទ្រត្រូវផ្ញើលិខិតទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។ ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋរបស់ខ្លួននូវសេចក្តីជូនដំណឹងខាងលើ ដែលទទួលបានពី ក.គ.ខ ជាពិសេសការអនុវត្តវិធានការដាក់វិន័យ ឬទណ្ឌកម្ម និងសំណើរបស់ ក.គ.ខ ក្នុងការបញ្ជូនបញ្ហាទៅមន្ទីរ ឬអង្គភាពពាក់ព័ន្ធ ដើម្បីដោះស្រាយ ។
- ក្រុមគាំទ្រត្រូវថតចម្លងលិខិតនេះទៅឱ្យសមាជិកអង្គការមិនមែនរដ្ឋាភិបាល អ្នកទទួលការ សមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅរាជធានី ខេត្ត ក្រុមប្រឹក្សានិងគណៈអភិបាលនៃក្រុង ស្រុក ខណ្ឌ សម្រាប់ការផ្សព្វផ្សាយជាសាធារណៈអំពីលទ្ធផលដោះស្រាយពាក្យបណ្តឹងរបស់ ក.គ.ខ ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ។

ទម្រង់ទី១៣ : ការផ្តល់ព័ត៌មានត្រឡប់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត:..........

លេខ :..........

ថ្ងៃទី..... ខែ......... ឆ្នាំ.....

**ជម្រាបជូន**

**ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត**.................

**កម្មវត្ថុ :** ស្តីពីលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងគិតត្រឹមថ្ងៃទី......... ខែ................. ឆ្នាំ............ ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបមកប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានជ្រាបថា កន្លងមកក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត .................... បានដោះស្រាយពាក្យបណ្តឹងដោយទទួលលទ្ធផលដូចខាងក្រោម :

- (សង្ខេបលទ្ធផលដែលបានដោះស្រាយ).....................................................................
- (សង្ខេបលទ្ធផលដែលកំពុងដោះស្រាយ)...................................................................

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ។

សូមលោក លោកស្រីទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ជ.ក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត**................

**ប្រធាន**

# ដំណាក់កាលនៃដំណើរការដោះស្រាយពាក្យបណ្តឹង

## ការប្រមូលពាក្យបណ្តឹង

- ➲ ក្រុមសម្របសម្រួលប្រមូលពាក្យបណ្តឹងពីប្រអប់សំបុត្រត្រូវ :
  - បំពេញលើខ្នងស្រោមសំបុត្រធំនូវឈ្មោះក្រុង ស្រុក ខណ្ឌ លេខសម្គាល់ប្រអប់សំបុត្រ ទីតាំងប្រអប់សំបុត្រ និងកាលបរិច្ឆេទ
  - បើកប្រអប់សំបុត្រនៅចំពោះមុខអ្នកចូលរួម
  - ពិនិត្យស្ថានភាពពាក្យបណ្តឹង និងរាប់ចំនួនពាក្យបណ្តឹង ប៉ុន្តែមិនត្រូវអានខ្លឹមសារឡើយ
  - ធ្វើកំណត់ហេតុបើកប្រអប់សំបុត្រ
  - ច្រកពាក្យបណ្តឹងក្នុងស្រោមសំបុត្រធំ បិទស្រោមសំបុត្រធំ និងអ្នកចូលរួមត្រូវចុះហត្ថលេខាលើស្រោមសំបុត្រធំ
  - យកស្រោមសំបុត្រធំ និងកំណត់ហេតុប្រគល់ឱ្យក្រុមគាំទ្រ ។
- ➲ ក្រុមគាំទ្រកត់ត្រាការទទួលស្រោមសំបុត្រធំ និងពាក្យបណ្តឹងទទួលបានប្រភពផ្សេងទៀត ។
- ➲ សមាជិក គ.គ.ខ និងមន្ត្រីជំនួយការប្រគល់កំណត់ហេតុពាក្យបណ្តឹងទៅក្រុមគាំទ្រ ។

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី២
- ទម្រង់ទី៣

## ដំណាក់កាលទី១: ការសម្រាំងពាក្យបណ្តឹង

- ➲ ការសម្រាំងពាក្យបណ្តឹង :
  - គ.គ.ខ ចាត់តាំងក្រុមសម្រាំង ( សមាជិក គ.គ.ខ ០២រូប + ក្រុមគាំទ្រ ) ។
  - សមាជិក គ.គ.ខ ដែលបានចាត់តាំងពិនិត្យស្ថានភាពស្រោមសំបុត្រធំ ។
  - សមាជិក គ.គ.ខ ដែលបានចាត់តាំងប្រគល់ស្រោមសំបុត្រដែលបើករួចឱ្យក្រុមគាំទ្រ ។
  - ក្រុមគាំទ្របង់លេខរៀងលើពាក្យបណ្តឹង ។
  - ក្រុមគាំទ្រអានខ្លឹមសារពាក្យបណ្តឹង ពិនិត្យអង្គហេតុ និងកត់ត្រាខ្លឹមសារពាក្យបណ្តឹង ។
  - កំណត់ពាក្យបណ្តឹងត្រូវដោះស្រាយ និងមិនត្រូវដោះស្រាយ ។
  - ចាត់អាទិភាពចំពោះពាក្យបណ្តឹងត្រូវដោះស្រាយ ។
  - ក្រុមគាំទ្រធ្វើសេចក្តីព្រាងរបាយការណ៍សម្រាំងជូនកិច្ចប្រជុំ គ.គ.ខ ។
- ➲ កិច្ចប្រជុំ គ.គ.ខ សម្រេច :
  - ករណីត្រូវដោះស្រាយ និងចាត់អាទិភាព
  - ករណីមិនត្រូវដោះស្រាយ

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី៤

## ដំណាក់កាលទី២: ការវាយតម្លៃ

- ➲ ដំណាក់កាលត្រៀមរៀបចំ :
  - ក្រុមគាំទ្រពិនិត្យអង្គច្បាប់ចំពោះពាក្យបណ្តឹងដែលត្រូវដោះស្រាយ ។
  - ក្រុមគាំទ្រធ្វើរបាយការណ៍សម្រាំងពាក្យបណ្តឹង ។
  - លេខាធិការរៀបចំកិច្ចប្រជុំ គ.គ.ខ ។
- ➲ កិច្ចប្រជុំ គ.គ.ខ ត្រូវ :
  - ពិនិត្យអង្គច្បាប់លើករណីត្រូវដោះស្រាយ
  - ធ្វើសេចក្តីសម្រេច :
    - + ស៊ើបអង្កេតពេញលេញ
    - + ស៊ើបអង្កេតមិនពេញលេញ
    - + បិទសំណុំរឿង
  - ចាត់តាំងក្រុមស៊ើបអង្កេត ( យ៉ាងតិច៣រូប )
  - ចាត់ចែងឱ្យផ្តល់ព័ត៌មានត្រឡប់ ។
- ➲ ក្រុមគាំទ្រត្រូវ :
  - រៀបចំលិខិតតែងតាំងក្រុមស៊ើបអង្កេត
  - ធ្វើលិខិតបញ្ជូនព័ត៌មានត្រលប់

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី៥
- ទម្រង់ទី៦
- ទម្រង់ទី៧

## ដំណាក់កាលទី៣: ផែនការស៊ើបអង្កេត

- ➲ ក្រុមស៊ើបអង្កេតត្រូវរៀបចំផែនការស៊ើបអង្កេតគ្រប់ពាក្យបណ្តឹងត្រូវដោះស្រាយ
- ➲ ក្រុមស៊ើបអង្កេតសិក្សាអង្គហេតុ និងអង្គច្បាប់លើពាក្យបណ្តឹង
- ➲ កំណត់អំពីភស្តុតាងដែលត្រូវបង្ហាញ
- ➲ កំណត់សកម្មភាពប្រមូលភស្តុតាង
  - ការប្រមូលឯកសារ
  - ការសម្ភាស
  - ពិនិត្យទីតាំងកើតហេតុ
  - ពិគ្រោះយោបល់ជាមួយអ្នកជំនាញ
- ➲ កំណត់ពេលវេលាដើម្បីចុះអនុវត្តស្របតាមសកម្មភាពនីមួយៗ ។

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី៨

**កំណត់សម្គាល់ :** កិច្ចប្រជុំ គ.គ.ខ ក្នុងការសម្រាំងពាក្យបណ្តឹង និងការវាយតម្លៃអាចធ្វើក្នុងពេលជាមួយគ្នា ។

**ជំហានទី៤: ការស៊ើបអង្កេត**

- ក្រុមស៊ើបអង្កេតប្រមូលភស្តុតាង :
  - ប្រមូលឯកសារ
  - សម្ភាសន៍ ដើមបណ្តឹង សាក្សី អ្នកពាក់ព័ន្ធ និងជនត្រូវចោទ
  - ការពិនិត្យកន្លែងកើតហេតុ
  - ពិគ្រោះយោបល់ជាមួយអ្នកជំនាញ
- ធ្វើការវិភាគភស្តុតាងដែលប្រមូលបាន
  - ផ្ទៀងផ្ទាត់ព័ត៌មានប្រមូលបាន
  - វិភាគភស្តុតាង
  - ធ្វើការសន្និដ្ឋាន :
    + បញ្ចប់ការស៊ើបអង្កេត( ភស្តុតាងគ្រប់គ្រាន់) និងផ្តល់អនុសាសន៍ ដើម្បី ក.គ.ខ ប្រជុំសម្រេច
    + បន្តការស៊ើបអង្កេត ( ភស្តុតាងពុំទាន់គ្រប់គ្រាន់)
    + បញ្ចប់ការស៊ើបអង្កេត ( មិនមានភស្តុតាងគ្រប់គ្រាន់)
- ធ្វើរបាយការណ៍ស៊ើបអង្កេត

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី៩
- ទម្រង់ទី១០

**ជំហានទី៥: ការធ្វើសេចក្តីសម្រេច**

- ក្រុមគាំទ្រ ត្រូវរៀបចំកិច្ចប្រជុំ ក.គ.ខ ។
- កិច្ចប្រជុំ ក.គ.ខ :
  - ក្រុមស៊ើបអង្កេតអានរបាយការណ៍ស៊ើបអង្កេតជូន ក.គ.ខ
  - ក.គ.ខ ពិភាក្សាអង្គហេតុផ្អែកអង្គច្បាប់
  - ការឆ្លើយបំភ្លឺរបស់ជនត្រូវចោទ( បើមាន)
  - ក.គ.ខ ធ្វើសេចក្តីសម្រេច :
    + បិទសំណុំរឿង ឬបន្តស៊ើបអង្កេត ក្នុងករណីភស្តុតាងនៃអង្គហេតុ មិនអាចជឿជាក់បាន ឬមិនមានភស្តុតាងគ្រប់គ្រាន់ ។
    + ដាក់ទណ្ឌកម្ម ក្នុងករណីអង្គហេតុមានភាពជឿជាក់ និងមានភស្តុតាងគ្រប់គ្រាន់
    + បញ្ជូនសំណុំរឿងទៅអង្គភាព ឬស្ថាប័នពាក់ព័ន្ធ ក្នុងករណីអង្គហេតុមានព័ត៌មានបញ្ជាក់សមស្រប ( សម្រាប់របាយការណ៍ស៊ើបអង្កេតមិនពេញលេញ) ។
  - ចាត់តាំងសមាជិក ក.គ.ខ ដើម្បីតាមដានការអនុវត្តសេចក្តីសម្រេច
- បន្ទាប់ពីកិច្ចប្រជុំក.គ.ខ
  - រៀបចំសេចក្តីសម្រេចរបស់ ក.គ.ខ
  - ផ្ញើសេចក្តីសម្រេចទៅមន្ទីរ ឬអង្គភាព ។

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី១១

**ជំហានទី៦: ការអនុវត្ត និងតាមដាន**

- ក្រុមគាំទ្រប្រគល់ជូនសេចក្តីសម្រេចដាក់ចេញដោយ ក.គ.ខ ឱ្យមន្ទីរ ឬអង្គភាពសាមី ។
- មន្ទីរ ឬអង្គភាពអនុវត្តវិធានការដាក់វិន័យនៅអំឡុងពេល១៥ថ្ងៃធ្វើការ បន្ទាប់ពី ក.គ.ខ បានចេញសេចក្តីសម្រេច ។
- មន្ទីរ ឬអង្គភាពសាមីធ្វើរបាយការណ៍ជូន ក.គ.ខ អំពីការអនុវត្តសេចក្តីសម្រេច ។
- ក.គ.ខ ចាត់តាំងសមាជិកឱ្យតាមដានការអនុវត្តសេចក្តីសម្រេច ។
- ក្រុមគាំទ្រប្រមូលរបាយការណ៍ពីសមាជិកដែលបានចាត់តាំងឱ្យតាមដាន ។
- ក.គ.ខ ពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដានខាងលើ ។

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី១២

**ជំហានទី៧: ការផ្តល់ព័ត៌មានត្រលប់**

- ក្រុមគាំទ្រត្រូវរៀបចំលិខិតផ្សព្វផ្សាយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ។
- ក្រុមគាំទ្រថតចម្លងលិខិតទៅសមាជិកអង្គការមិនមែនរដ្ឋាភិបាល សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ សម្រាប់ធ្វើការផ្សព្វផ្សាយ ។
- តំណាងអង្គការ និងអ្នកទទួលការដែលជាសមាជិក ក.គ.ខ ត្រូវផ្សព្វផ្សាយអំពីដំណើរការរបស់ ក.គ.ខ ដល់ប្រជាពលរដ្ឋ ។

ទម្រង់ត្រូវប្រើ :
- ទម្រង់ទី១៣